# JOHN - យ៉ូហាន 1

1កាលពីដើមដំបូងបង្អស់ ព្រះបន្ទូលមានព្រះជន្មគង់នៅ។ ព្រះបន្ទូលគង់នៅជាមួយ ព្រះជាម្ចាស់
ហើយព្រះបន្ទូលជាព្រះជាម្ចាស់។ 2ព្រះបន្ទូលគង់នៅជាមួយព្រះជាម្ចាស់ កាលពីដើមដំបូងបង្អស់។ 3អ្វីៗសព្វសារពើសុទ្ធតែកើតឡើង
ដោយសារព្រះបន្ទូល គឺក្នុងបណ្ដាអ្វីៗដែលកើតមក គ្មានអ្វីមួយកើតមកក្រៅពីព្រះអង្គបង្កើតនោះឡើយ។ 4ព្រះបន្ទូលជាប្រភពនៃជីវិត
ហើយជីវិតនោះជាពន្លឺបំភ្លឺមនុស្សលោក។ 5ពន្លឺភ្លឺក្នុងសេចក្ដីងងឹត តែសេចក្ដីងងឹតពុំបានទទួលពន្លឺទេ។ 6ព្រះជាម្ចាស់ បានចាត់បុរសម្នាក់
ឈ្មោះយ៉ូហានអោយមក។ 7លោកបានមកធ្វើជាបន្ទាល់ផ្ដល់សក្ខីភាពអំពីពន្លឺ ដើម្បីអោយមនុស្សទាំងអស់ជឿ
ដោយសារលោក។ 8លោកយ៉ូហានមិនមែនជាពន្លឺទេ
គឺលោកគ្រាន់តែមកផ្ដល់សក្ខីភាពអំពីពន្លឺប៉ុណ្ណោះ។9ព្រះបន្ទូលជាពន្លឺដ៏ពិតប្រាកដតែមួយដែលមកក្នុងពិភពលោកហើយបំភ្លឺមនុស្សគ្រប់ៗរូប។ 10ព្រះបន្ទូ
លបានគង់ក្នុងពិភពលោក ហើយពិភពលោកកើតឡើង ដោយសារព្រះអង្គ ប៉ុន្ដែ
ពិភពលោកពុំបានទទួលស្គាល់ព្រះអង្គទេ។ 11ព្រះបន្ទូលបានយាងមកគង់ជាមួយប្រជារាស្ដ្ររបស់ព្រះអង្គផ្ទាល់
តែប្រជារាស្ដ្រនោះពុំបានទទួលព្រះអង្គឡើយ។ 12រីឯអស់អ្នកដែលបានទទួលព្រះអង្គ គឺអស់អ្នកដែលជឿលើព្រះនាមព្រះអង្គ
ព្រះអង្គប្រទានអោយគេអាចទៅជាបុត្ររបស់ព្រះជាម្ចាស់។ 13អ្នកទាំងនោះពុំមែនកើតពីលោហិតពីចំណង់តណ្ហា ឬ ពីបំណងមនុស្សឡើយ
គឺកើតពីព្រះជាម្ចាស់វិញ។ 14ព្រះបន្ទូលបានកើតមកជាមនុស្ស ហើយគង់នៅក្នុងចំណោមយើងរាល់គ្នា យើងបានឃើញសិរីរុងរឿងរបស់ព្រះអង្គ
ជាសិរីរុងរឿងនៃព្រះបុត្រាតែមួយគត់ដែលមកពីព្រះបិតា ព្រះអង្គពោរពេញទៅដោយព្រះគុណ និង

សេចក្ដីពិត។ 15លោកយ៉ូហានបានផ្ដល់សក្ខីភាពអំពីព្រះអង្គ ដោយប្រកាសថា៖ «គឺលោកនេះហើយដែលខ្ញុំនិយាយថា "អ្នកមកក្រោយខ្ញុំ ប្រសើរជាងខ្ញុំ
ដ្បិតលោកមានជីវិតមុនខ្ញុំ"»។ 16យើងទាំងអស់គ្នាបានទទួលព្រះគុណមិនចេះអស់មិនចេះហើយ
ពីគ្រប់លក្ខណសម្បត្តិរបស់ព្រះអង្គ 17ដ្បិតព្រះអង្គប្រទានក្រឹត្យវិន័យតាមរយៈលោកម៉ូសេ ហើយព្រះគុណ និង
សេចក្ដីពិតតាមរយៈព្រះយេស៊ូគ្រិស្ដ។ 18ពុំដែលមាននរណាម្នាក់បានឃើញព្រះជាម្ចាស់ឡើយ មានតែព្រះបុត្រាមួយព្រះអង្គប៉ុណ្ណោះ
ដែលបាននាំយើងអោយស្គាល់ព្រះអង្គ ដ្បិតព្រះបុត្រាមានព្រះជន្មរួមជាមួយព្រះបិតា។ 19ជនជាតិយូដាចាត់ពួកបូជាចារ្យ និង ពួកលេវីពីក្រុងយេរូសាឡឹម
អោយទៅជួបលោកយ៉ូហាន ដើម្បីសួរថា៖ «លោកជានរណា?»។ 20លោកយ៉ូហានប្រកាសប្រាប់គេ ដោយពុំលាក់លៀមអ្វីឡើយ
គឺលោកបានបញ្ជាក់យ៉ាងច្បាស់ថា៖ «ខ្ញុំមិនមែនជាព្រះគ្រិស្ដទេ»។21ពួកគេសួរលោកថា៖ «ដូច្នេះតើលោកជានរណា?
តើលោកជាព្យាការីអេលីយ៉ាឬ?»។ លោកឆ្លើយថា៖ «ទេ មិនមែនទេ!»។ គេក៏សួរទៀតថា៖ «តើលោកជាព្យាការីដែលយើងរង់ចាំ នោះឬ?»។
លោកឆ្លើយថា៖ «មិនមែនទេ!»។ 22គេសួរលោកទៀតថា៖ «តើលោកជានរណា? ដ្បិតយើងខ្ញុំចង់បានចម្លើយ
យកទៅជំរាបអស់លោកដែលចាត់យើងខ្ញុំអោយមក តើលោកថាខ្លួនលោកជា នរណា!»។ 23លោកយ៉ូហានមានប្រសាសន៍ថា៖
«ខ្ញុំជាសំឡេងបុរសម្នាក់ដែលស្រែក នៅវាលរហោស្ថានថា: "ចូរតំរង់ផ្លូវថ្វាយព្រះអម្ចាស់"
ត្រូវនឹងសេចក្ដីដែលព្យាការីអេសាយបានថ្លែងទុកមក»។ 24អ្នកដែលគេចាត់អោយមកនោះ
ជាពួកខាងគណៈផារីស៊ី។ 25គេសួរលោកយ៉ូហានទៀតថា៖ «បើលោកមិនមែនជាព្រះគ្រិស្ដ មិនមែនជាព្យាការីអេលីយ៉ា
ហើយក៏មិនមែនជាព្យាការីដែលយើងរង់ចាំនោះទេ ហេតុដូចម្ដេចបានជាលោកធ្វើពិធីជ្រមុជទឹកដូច្នេះ?»។ 26លោកយ៉ូហានឆ្លើយទៅគេថា៖

«ខ្ញុំធ្វើពិធីជ្រមុជក្នុងទឹកមែន ប៉ុន្តែ ក្នុងចំណោមអ្នករាល់គ្នាមានម្នាក់ដែលអ្នករាល់គ្នាពុំស្គាល់ 27លោកមកក្រោយខ្ញុំ លោកមានឋានៈខ្ពង់ខ្ពស់ណាស់
សូម្បីតែអោយខ្ញុំស្រាយខ្សែស្បែកជើងជូនលោក ក៏មិនសមនឹងឋានៈរបស់លោកផង»។ 28ហេតុការណ៍នេះកើតមាន នៅភូមិបេតថានី
ខាងនាយទន្លេយ័រដាន់ ត្រង់កន្លែងលោកយ៉ូហានធ្វើពិធីជ្រមុជទឹក។ 29នៅថ្ងៃបន្ទាប់ លោកយ៉ូហានឃើញព្រះយេស៊ូយាងតំរង់មករកលោក
លោកក៏មានប្រសាសន៍ថា៖ «មើលហ្ន៎! លោកនេះហើយជាកូនចៀមរបស់ព្រះជាម្ចាស់ ដែលដកបាបចេញពីមនុស្សលោក 30គឺលោកនេះហើយ
ដែលខ្ញុំបានប្រាប់អ្នករាល់គ្នាថា "អ្នកដែលមកក្រោយខ្ញុំប្រសើរជាងខ្ញុំ ដ្បិតលោកមានជីវិតមុនខ្ញុំ"។ 31កាលពីដើម ខ្ញុំពុំស្គាល់ឋានៈរបស់លោកទេ ប៉ុន្តែ
ខ្ញុំមកធ្វើពិធីជ្រមុជក្នុងទឹក ដើម្បីអោយលោកបង្ហាញខ្លួនអោយប្រជារាស្ត្រអ៊ីស្រាអែលស្គាល់»។32លោកយ៉ូហានបានផ្ដល់សក្ខីភាពថា៖
«ខ្ញុំបានឃើញព្រះវិញ្ញាណ យាងចុះពីស្ថានបរមសុខ ដូចសត្វព្រាប មកសណ្ឋិតលើលោក។ 33ពីមុនខ្ញុំពុំស្គាល់ឋានៈលោកទេ ប៉ុន្តែ
ព្រះជាម្ចាស់ដែលបានចាត់ខ្ញុំអោយមកធ្វើពិធីជ្រមុជក្នុងទឹក ទ្រង់មានព្រះបន្ទូលមកខ្ញុំថា "អ្នកឃើញព្រះវិញ្ញាណ យាងចុះមកសណ្ឋិតលើអ្នកណា
គឺអ្នកនោះហើយ ដែលធ្វើពិធីជ្រមុជក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ"។ 34ខ្ញុំបានឃើញដូច្នោះមែនហើយខ្ញុំសូមបញ្ជាក់ថា
លោកនេះពិតជាព្រះបុត្រារបស់ព្រះជាម្ចាស់មែន»។ 35ថ្ងៃបន្ទាប់មកទៀត លោកយ៉ូហាននៅទីនោះដដែល
ហើយមានសិស្សរបស់លោកពីរនាក់នៅជាមួយផង។ 36លោកសំឡឹងមើលព្រះយេស៊ូយាងកាត់តាមនោះ ក៏មានប្រសាសន៍ថា៖
«មើលហ្ន៎!លោកនេះហើយជាកូនចៀមរបស់ព្រះជាម្ចាស់»។37កាលសិស្សទាំងពីរបានឮពាក្យនេះ
គេនាំគ្នាដើរតាមព្រះយេស៊ូទៅ។38ព្រះយេស៊ូងាកមកក្រោយ ទតឃើញអ្នកទាំងពីរដើរតាម ព្រះអង្គក៏មានព្រះបន្ទូលសួរថា៖ «អ្នកទាំងពីរមករកអ្វី?»។
គេទូលព្រះអង្គថា៖ «រ៉ាបី! (ពាក្យ"រ៉ាប៊ី"នេះប្រែថា"លោកគ្រូ")

តើលោកនៅកន្លែងណា?»។ 39ព្រះអង្គមានព្រះបន្ទូលទៅគេវិញថា៖«សុំអញ្ជើញមក អ្នកនឹងបានឃើញ!»។
គេក៏ទៅឃើញកន្លែងដែលព្រះអង្គគង់នៅ ហើយគេក៏នៅជាមួយព្រះអង្គនៅថ្ងៃនោះ
(ពេលនោះប្រហែលជាម៉ោងបួនរសៀល)។ 40ក្នុងចំណោមសិស្សទាំងពីរដែលបានឮពាក្យរបស់លោកយ៉ូហាន ហើយតាមព្រះយេស៊ូទៅនោះ
មានម្នាក់ឈ្មោះអនទ្រេ ជាប្អូនរបស់លោកស៊ីម៉ូនពេត្រុស។ 41គាត់ទៅជួបលោកស៊ីម៉ូន ជាបងមុនគេប្រាប់ថា៖ «យើងបានរកព្រះមេស្ស៊ីឃើញហើយ!»
(ពាក្យ"មេស្ស៊ី"នេះ ប្រែថា"ព្រះគ្រិស្ត")។ 42គាត់ក៏នាំលោកស៊ីម៉ូនទៅគាល់ព្រះយេស៊ូ។ ព្រះយេស៊ូសំឡឹងមើលលោកស៊ីម៉ូន ក៏មានព្រះបន្ទូលថា៖
«អ្នកឈ្មោះស៊ីម៉ូន ជាកូនរបស់លោកយ៉ូហាន អំណើះតទៅ អ្នកត្រូវមានឈ្មោះថា"កេផាស" (ពាក្យ"កេផាស" នេះ ប្រែថា
ពេត្រុស)។ 43លុះថ្ងៃបន្ទាប់មកទៀត ព្រះយេស៊ូសព្វព្រះហឫទ័យយាងទៅស្រុកកាលីឡេ។ ព្រះអង្គបានជួបលោកភីលីព
ហើយមានព្រះបន្ទូលទៅគាត់ថា៖«សូមអញ្ជើញមកតាមខ្ញុំ»។ 44លោកភីលីពជាអ្នកភូមិបេតសៃដាដូចលោកអនទ្រេ និង
លោកពេត្រុសដែរ។ 45លោកភីលីពទៅជួបលោកណាថាណែល ប្រាប់គាត់ថា៖«ព្រះអង្គដែលលោកម៉ូសេបានចារទុកក្នុងគម្ពីរវិន័យ
ហើយគម្ពីរព្យាការីក៏មានចែងទុកដែរនោះ ឥឡូវនេះយើងបានជួបហើយ ព្រះអង្គមាននាមថាយេស៊ូជាអ្នកភូមិណាសារ៉ែតជាបុត្ររបស់
លោកយ៉ូសែប»។ 46លោកណាថាណែលពោលតបទៅលោកភីលីពវិញថា៖ «ពុំដែលមានអ្វីល្អ
អាចចេញពីភូមិណាសារ៉ែតបានឡើយ»។47លោកភីលីពប្រាប់គាត់ថា៖ «សូមអញ្ជើញមកអ្នកនឹងបានឃើញ!»។
កាលព្រះយេស៊ូទតឃើញលោកណាថាណែលដើរមករកព្រះអង្គ ព្រះអង្គមានព្រះបន្ទូលអំពីគាត់ថា៖ «អ្នកនេះជាជាតិអ៊ីស្រាអែលដ៏ពិតប្រាកដមែន
ដ្បិតគាត់គ្មានពុតត្បុតអ្វីក្នុងខ្លួនសោះ»។ 48លោកណាថាណែលទូលសួរព្រះអង្គថា៖ «តើលោកគ្រូដែលស្គាល់ខ្ញុំពីអង្កាល់?»។

ព្រះយេស៊ូមានព្រះបន្ទូលតបថា៖ «ខ្ញុំបានឃើញអ្នក កាលអ្នកនៅក្រោមដើមឧទុម្ពរ
មុនភីលីពហៅអ្នកទៅទៀត»។ 49លោកណាថាណែលទូលព្រះអង្គថា៖ «ព្រះគ្រូ! ព្រះអង្គពិតជាព្រះបុត្រារបស់ព្រះជាម្ចាស់
ហើយពិតជាព្រះមហាក្សត្ររបស់ជនជាតិអ៊ីស្រាអែលមែន»។ 50ព្រះយេស៊ូមានព្រះបន្ទូលទៅគាត់ថា៖ «អ្នកបានជឿមកពីឮខ្ញុំនិយាយថា
ខ្ញុំបានឃើញអ្នកនៅក្រោមដើមឧទុម្ពរ"ថ្ងៃក្រោយ អ្នកមុខតែឃើញការអស្ចារ្យលើសនេះទៅទៀត»។ 51ព្រះអង្គមានព្រះបន្ទូលថែមទៀតថា៖
«ខ្ញុំសុំប្រាប់អោយអ្នករាល់គ្នាដឹងច្បាស់ថា អ្នករាល់គ្នានឹងឃើញ ផ្ទៃមេឃបើកចំហ ហើយមានពួកទេវតារបស់ព្រះជាម្ចាស់ចុះឡើងនៅពីលើបុត្រមនុស្ស»។

# JOHN - យ៉ូហាន 2

1បីថ្ងៃក្រោយមក មានគេរៀបពិធីមង្គលការនៅភូមិកាណា ក្នុងស្រុកកាលីឡេ។ មាតាព្រះយេស៊ូនៅទីនោះ 2ហើយគេក៏បានយាងព្រះយេស៊ូ និង
អញ្ជើញពួកសិស្សរបស់ព្រះអង្គ ទៅចូលរួមក្នុងពិធីមង្គលការនោះដែរ។3ពេលនោះ គេខ្វះស្រាទំពាំងបាយជូរ។ មាតាព្រះយេស៊ូទូលព្រះអង្គថា៖
«គេអស់ស្រាទំពាំងបាយជូរហើយ!»។ 4ព្រះយេស៊ូមានព្រះបន្ទូលទៅមាតាថា៖ «អ្នកម្ដាយអើយ! កុំរវល់នឹងរឿងនេះអី
ពេលកំណត់របស់ខ្ញុំពុំទាន់មកដល់នៅឡើយទេ»។ 5មាតារបស់ព្រះអង្គប្រាប់ទៅពួកអ្នកបំរើថា៖ «បើលោកប្រាប់អោយធ្វើអ្វី
ចូរធ្វើតាមទៅ»។ 6នៅទីនោះមានពាងប្រាំមួយដែលជនជាតិយូដាដាក់ទឹក សំរាប់ធ្វើពិធីជំរះកាយ។
ពាងនីមួយៗមានចំណុះប្រមាណជាពីរបីអំរែក។ 7ព្រះយេស៊ូមានព្រះបន្ទូលទៅអ្នកបំរើថា៖ «សុំដងទឹកមកចាក់អោយពេញពាងទាំងនេះទៅ»។
គេក៏ដងទឹកចាក់ពេញពាង។ 8ព្រះអង្គមានព្រះបន្ទូលថា៖ «ឥឡូវនេះ សុំដងយកទៅជូនលោកចៅមហាទៅ»

គេក៏ដងយកទៅជូន។ 9លោកចៅមហាភ្លក់ទឹក ដែលបានប្រែមកជាស្រាទំពាំងបាយជូរ។ គាត់មិនដឹងថា គេបានស្រានេះមកពីណាឡើយ
មានតែពួកអ្នកបំរើដែលបានដងទឹក មកចាក់ពាងទើបដឹង។10គាត់ហៅកូនកំលោះមកនិយាយថា៖ «អ្នកផងទាំងពួងតែងយកស្រាទំពាំងបាយជូរឆ្ងាញ់
មកជូនភ្ញៀវជាមុន លុះភ្ញៀវពិសាច្រើនហើយ ទើបគេយកស្រាមិនសូវឆ្ងាញ់មកជូនតាមក្រោយ។ រីឯអ្នកវិញ
ម្ដេចក៏ទុកស្រាឆ្ងាញ់មកទល់ឥឡូវដូច្នេះ!»។ 11នេះជាទីសំគាល់ដំបូងបង្អស់ ដែលព្រះយេស៊ូបានធ្វើនៅភូមិកាណាក្នុងស្រុកកាលីឡេ។
ព្រះអង្គបានសំដែងសិរីរុងរឿងរបស់ព្រះអង្គ ហើយពួកសិស្សក៏បានជឿលើព្រះអង្គ។ 12បន្ទាប់មក ព្រះអង្គយាងចុះទៅក្រុងកាពើណិម ជាមួយមាតា
ព្រមទាំងបងប្អូន និង សិស្សរបស់ព្រះអង្គ ហើយស្នាក់នៅទីនោះមួយរយៈពេលខ្លី។ 13បុណ្យចម្លងរបស់ជនជាតិយូដាជិតមកដល់ហើយ
ព្រះយេស៊ូក៏យាងឡើងទៅក្រុងយេរូសាឡឹម។ 14នៅក្នុងបរិវេណព្រះវិហារ ព្រះអង្គឃើញអ្នកលក់គោ លក់ចៀម លក់ព្រាប និង
អ្នកអង្គុយដូរប្រាក់។ 15ព្រះអង្គយកខ្សែធ្វើរំពាត់ដេញអ្នកទាំងនោះ ព្រមទាំងចៀម និង
គោរបស់គេចេញពីបរិវេណព្រះវិហារព្រះអង្គបាចប្រាក់អ្នកដូរប្រាក់ចោល ហើយផ្កាប់តុរបស់គេផង។16ព្រះអង្គមានព្រះបន្ទូលទៅអ្នកលក់ព្រាបថា៖
«ចូរយករបស់ទាំងអស់នេះចេញទៅ
កុំយកដំណាក់ព្រះបិតាខ្ញុំធ្វើជាកន្លែងលក់ដូរដូច្នេះឡើយ»។17ពួកសិស្សនឹកឃើញសេចក្ដីដែលមានចែងទុកក្នុងគម្ពីរថា៖
«មកពីទូលបង្គំស្រឡាញ់ព្រះដំណាក់របស់ព្រះអង្គ បានជាគេប្រហារជីវិតទូលបង្គំ»។18ពេលនោះ ជនជាតិយូដាទូលសួរព្រះអង្គថា៖
«តើលោកមានទីសំគាល់អ្វី បង្ហាញអោយយើងដឹងថាលោកមានសិទ្ធិធ្វើការទាំងនេះ?»។ 19ព្រះយេស៊ូមានព្រះបន្ទូលឆ្លើយទៅគេថា៖
«ចូររុះព្រះវិហារនេះចោលទៅ ខ្ញុំនឹងសង់ឡើងវិញក្នុងរវាងបីថ្ងៃ»។ 20ជនជាតិយូដាតបថា៖ «គេបានចំណាយពេលសែសិបប្រាំមួយឆ្នាំ

ដើម្បីសង់ព្រះវិហារនេះ រីឯលោក លោកនឹងសង់ឡើងវិញក្នុងរវាងតែបីថ្ងៃប៉ុណ្ណោះឬ?»។ 21តាមពិត
ព្រះយេស៊ូមានព្រះបន្ទូលសំដៅទៅលើព្រះវិហារដែលជារូបកាយរបស់ព្រះអង្គវិញឯណោះទេ។22ពេលព្រះអង្គមានព្រះជន្មរស់ឡើងវិញ
ពួកសិស្សនឹកឃើញថាព្រះអង្គមានព្រះបន្ទូលដូច្នេះ គេក៏ជឿព្រះគម្ពីរ
ព្រមទាំងជឿព្រះបន្ទូលរបស់ព្រះយេស៊ូដែរ។ 23ពេលព្រះយេស៊ូគង់នៅក្រុងយេរូសាឡឹម ក្នុងឱកាសបុណ្យចម្លង
មានមនុស្សជាច្រើនបានជឿលើព្រះនាមព្រះអង្គ ដោយឃើញទីសំគាល់ដែលព្រះអង្គបានធ្វើ។ 24ប៉ុន្តែ ព្រះយេស៊ូពុំទុកចិត្តគេទេ
ដ្បិតព្រះអង្គស្គាល់ចិត្តគំនិតអ្នកទាំងនោះ 25មិនបាច់មាននរណាពន្យល់ព្រះអង្គអំពីចិត្តមនុស្សឡើយ
ព្រោះព្រះអង្គឈ្វេងយល់អ្វីៗទាំងអស់នៅក្នុងចិត្តមនុស្ស។

# JOHN - យ៉ូហាន 3

1មាននាម៉ឺនជាតិយូដាម្នាក់ ឈ្មោះនីកូដេម លោកនៅខាងគណៈផារីស៊ី។2លោកបានមកគាល់ព្រះយេស៊ូទាំងយប់ហើយទូលថា៖
«លោកគ្រូយើងខ្ញុំដឹងថាព្រះជាម្ចាស់បានចាត់លោកគ្រូអោយមកបង្រៀនយើងខ្ញុំ ដ្បិតគ្មាននរណាអាចធ្វើទីសំគាល់ដូចលោកគ្រូបានឡើយ
វៀរលែងតែព្រះជាម្ចាស់គង់ជាមួយអ្នកនោះ»។ 3ព្រះយេស៊ូមានព្រះបន្ទូលទៅគាត់ថា៖ «ខ្ញុំសូមជំរាបលោកអោយដឹងច្បាស់ថា
ប្រសិនបើមនុស្សមិនកើតជាថ្មី ទេ គេមិនអាចឃើញព្រះរាជ្យរបស់ព្រះជាម្ចាស់បានឡើយ»។4លោកនីកូដេមទូលសួរព្រះអង្គថា៖
«ចុះបើមនុស្សមានវ័យចាស់ទៅហើយ ធ្វើដូចម្ដេចអាចកើតម្ដងទៀតបាន? តើគេអាចចូលទៅក្នុងផ្ទៃម្ដាយ

ហើយកើតម្ដងទៀតបានឬ?»។ 5ព្រះយេស៊ូមានព្រះបន្ទូលតបថា៖ «ខ្ញុំសូមជំរាបលោកអោយដឹងច្បាស់ថា ប្រសិនបើមនុស្សមិនកើតពីទឹក និង
ពីព្រះវិញ្ញាណទេ គេពុំអាចចូលក្នុងព្រះរាជ្យព្រះជាម្ចាស់បានឡើយ។ 6អ្នកណាកើតមកជាមនុស្ស អ្នកនោះនៅតែជាមនុស្សដដែល
រីឯអ្នកដែលកើតពីព្រះវិញ្ញាណវិញមានព្រះវិញ្ញាណក្នុងខ្លួន។ 7ពេលខ្ញុំជំរាបលោកថា
"អ្នករាល់គ្នាត្រូវកើតជាថ្មី"សូមកុំឆ្ងល់អោយសោះ។ 8ខ្យល់ចង់បក់ទៅទិសណាក៏បាន លោកឮស្នូរវា តែលោកពុំដឹងថាខ្យល់បក់មកពីទីណា
ទៅទីណាឡើយ រីឯអ្នកដែលកើតមកពីព្រះវិញ្ញាណ ក៏ដូច្នោះដែរ»។ 9លោកនីកូដេមទូលសួរព្រះអង្គថា៖
«តើការទាំងនេះអាចនឹងកើតឡើងដូចម្ដេចបាន?»។10ព្រះយេស៊ូមានព្រះបន្ទូលថា៖ «លោកជាគ្រូរបស់ជនជាតិអ៊ីស្រាអែល
ម្ដេចក៏លោកមិនជ្រាបសេចក្ដីទាំងនេះ? 11ខ្ញុំសូមជំរាបលោកអោយដឹងច្បាស់ថា យើងនិយាយអំពីសេចក្ដីណាដែលយើងដឹង
ហើយយើងធ្វើជាបន្ទាល់បញ្ជាក់នូវហេតុការណ៍ណាដែលយើងបានឃើញ
តែអ្នករាល់គ្នាមិនទទួលសក្ខីភាពរបស់យើងទេ។ 12ពេលខ្ញុំនិយាយអំពីហេតុការណ៍នៅលើផែនដី អ្នករាល់គ្នាមិនជឿទៅហើយ
ចុះទំរាំបើខ្ញុំនិយាយអំពីហេតុការណ៍នៅស្ថានបរមសុខវិញ តើអ្នករាល់គ្នានឹងជឿដូចម្ដេចបាន!។ 13ពុំដែលមាននរណាបានឡើងទៅស្ថានបរមសុខឡើយ
គឺមានតែបុត្រមនុស្សប៉ុណ្ណោះ ដែលបានយាងចុះពីស្ថានបរមសុខមក។ 14កាលនៅវាលរហោស្ថាន លោកម៉ូសេបានលើកពស់ឡើងយ៉ាងណា
បុត្រមនុស្សនឹងត្រូវគេលើកឡើង យ៉ាងនោះដែរ 15ដើម្បីអោយអស់អ្នកដែលជឿលើព្រះអង្គ
មានជីវិតអស់កល្បជានិច្ច។ 16ព្រះជាម្ចាស់ស្រឡាញ់មនុស្សលោកខ្លាំងណាស់ ហេតុនេះហើយបានជាព្រះអង្គប្រទានព្រះបុត្រាតែមួយរបស់ព្រះអង្គមក
ដើម្បីអោយអស់អ្នកដែលជឿលើព្រះបុត្រា មានជីវិតអស់កល្បជានិច្ច គឺមិនអោយគេវិនាសឡើយ។ 17ព្រះជាម្ចាស់បានចាត់ព្រះបុត្រារបស់ព្រះអង្គ

អោយយាងមកក្នុងលោកនេះ ពុំមែនដើម្បីដាក់ទោសមនុស្សលោកទេ គឺដើម្បីសង្គ្រោះមនុស្សលោក ដោយសារព្រះបុត្រាវិញ។ 18អ្នកជឿលើព្រះបុត្រា
មិនត្រូវទទួលទោសទេរីឯអ្នកមិនជឿ បានទទួលទោសរួចស្រេចទៅហើយ
ព្រោះគេពុំបានជឿលើព្រះនាមព្រះបុត្រាតែមួយរបស់ព្រះជាម្ចាស់។19ហេតុដែលបណ្ដាលអោយមានទោសនោះ គឺពន្លឺបានយាងមកក្នុងពិភពលោក ប៉ុន្តែ
មនុស្សលោកចូលចិត្តភាពងងឹតជាងពន្លឺ ដ្បិតអំពើរបស់គេសុទ្ធតែអាក្រក់។ 20អស់អ្នកដែលប្រព្រឹត្តអំពើអាក្រក់តែងតែស្អប់ពន្លឺ
ហើយមិនចូលមករកពន្លឺឡើយ ព្រោះខ្លាចគេឃើញអំពើដែលខ្លួនប្រព្រឹត្ត។21ផ្ទុយទៅវិញ អស់អ្នកដែលប្រព្រឹត្តតាមសេចក្ដីពិត តែងតែចូលមករកពន្លឺ
ដើម្បីអោយគេឃើញថា អំពើដែលខ្លួនប្រព្រឹត្តនោះ ស្របតាមព្រះជាម្ចាស់មែន»។ 22បន្ទាប់មក ព្រះយេស៊ូយាងទៅស្រុកយូដាជាមួយពួកសិស្ស។
ព្រះអង្គស្នាក់នៅទីនោះជាមួយគេព្រមទាំងជ្រមុជទឹកអោយបណ្ដាជនផង។ 23រីឯលោកយ៉ូហានវិញ លោកក៏ជ្រមុជទឹកអោយគេ នៅអេណូន
ក្បែរភូមិសាលីមដែរ ព្រោះនៅទីនោះមានទឹកច្រើន។ មនុស្សម្នានាំគ្នាមករកលោក
ហើយលោកជ្រមុជទឹកអោយ។ 24កាលណោះលោកយ៉ូហានមិនទាន់ជាប់ឃុំឃាំងនៅឡើយទេ។ 25ពេលនោះ ពួកសិស្សរបស់លោកយ៉ូហាន និង
ជនជាតិយូដាម្នាក់ ជជែកគ្នាអំពីពិធីជំរះកាយអោយបានបរិសុទ្ធ។ 26គេនាំគ្នាទៅជួបលោកយ៉ូហាន ជំរាបថា៖ «លោកគ្រូ! បុរសដែលនៅជាមួយលោក
ខាងនាយទន្លេយ័រដាន់ ពីថ្ងៃមុន ហើយដែលលោកផ្ដល់សក្ខីភាពអោយនោះ ឥឡូវនេះ គាត់កំពុងតែជ្រមុជទឹកអោយគេ
មនុស្សទាំងអស់នាំគ្នាទៅរកគាត់»។ 27លោកយ៉ូហានមានប្រសាសន៍តបទៅគេថា៖ «បើព្រះជាម្ចាស់មិនប្រទានអោយទេ
គ្មាននរណាម្នាក់អាចធ្វើអ្វីកើតឡើយ។ 28អ្នករាល់គ្នាជាបន្ទាល់ស្រាប់ហើយ ខ្ញុំបាននិយាយថា ខ្ញុំមិនមែនជាព្រះគ្រិស្ដទេ
គឺព្រះជាម្ចាស់បានចាត់ខ្ញុំអោយមកមុនព្រះអង្គ។29នៅក្នុងពិធីមង្គលការ កូនក្រមុំរៀបការនឹងអ្នកណា អ្នកនោះហើយជាស្វាមី។ រីឯមិត្តសំឡាញ់របស់ស្វាមី

គេឈរស្ដាប់នៅក្បែរគាត់ និង មានចិត្តត្រេកអរក្រៃលែងដោយបានឮសំឡេងរបស់គាត់។
ខ្ញុំក៏ពោរពេញដោយអំណរដូច្នោះដែរ។ 30ព្រះអង្គត្រូវតែចំរើនឡើង រីឯខ្ញុំវិញ ខ្ញុំត្រូវតែអន់ថយ។31ព្រះអង្គដែលយាងពីស្ថានបរមសុខមក
ទ្រង់មានឋានៈធំលើសគេទាំងអស់។ អ្នកដែលកើតពីលោកីយ៍នៅតែជាលោកីយ៍ដដែល ហើយនិយាយតែពីរឿងលោកីយ៍។
ព្រះអង្គដែលយាងពីស្ថានបរមសុខមកទ្រង់មានឋានៈធំលើសគេទាំងអស់។ 32ព្រះអង្គធ្វើជាបន្ទាល់បញ្ជាក់ពីអ្វីៗទាំងអស់ ដែលទ្រង់បានឃើញ និង បានឮ
ប៉ុន្តែ គ្មាននរណាទទួលសក្ខីភាពរបស់ព្រះអង្គទេ។ 33អ្នកដែលទទួលសក្ខីភាពរបស់ព្រះអង្គ បានបញ្ជាក់ថា
ព្រះជាម្ចាស់បានសំដែងសេចក្ដីពិតមែន។ 34ព្រះអង្គដែលព្រះជាម្ចាស់ចាត់អោយយាងមក ថ្លែងព្រះបន្ទូលរបស់ព្រះជាម្ចាស់
ព្រោះព្រះជាម្ចាស់ប្រទានព្រះវិញ្ញាណមកព្រះអង្គ យ៉ាងបរិបូណ៌។ 35ព្រះបិតាស្រឡាញ់ព្រះបុត្រា ហើយបានប្រគល់អ្វីៗទាំងអស់
អោយនៅក្រោមអំណាចរបស់ព្រះបុត្រា។36អ្នកណាជឿលើព្រះបុត្រា អ្នកនោះមានជីវិតអស់កល្បជានិច្ច។ អ្នកណាមិនព្រមជឿលើព្រះបុត្រា
អ្នកនោះមិនបានទទួលជីវិតឡើយ គឺគេត្រូវទទួលទោសពីព្រះជាម្ចាស់»។

# JOHN - យ៉ូហាន 4

1ព្រះយេស៊ូជ្រាបថាពួកខាងគណៈផារីស៊ីបានឮគេនិយាយថា ព្រះអង្គមានសិស្សច្រើនជាងលោកយ៉ូហាន និង
បានជ្រមុជទឹកអោយមនុស្សច្រើនជាងដែរ។ 2តាមពិត ព្រះយេស៊ូពុំបានជ្រមុជទឹកអោយគេផ្ទាល់ព្រះអង្គឡើយ
គឺពួកសិស្សវិញទេដែលជាអ្នកជ្រមុជទឹក។ 3ព្រះអង្គក៏យាងចាកចេញពីស្រុកយូដា

ត្រឡប់ទៅស្រុកកាលីឡេវិញ 4ហើយត្រូវយាងកាត់តាមស្រុកសាម៉ារី។ 5ព្រះអង្គបានយាងមកដល់ភូមិមួយរបស់ជនជាតិសាម៉ារី ឈ្មោះភូមិស៊ីខារ
នៅជិតចំការដែលលោកយ៉ាកុបបានចែកអោយលោកយ៉ូសែបជាកូន។ 6នៅទីនោះមានអណ្ដូងទឹកមួយឈ្មោះ "អណ្ដូងលោកយ៉ាកុប"។
ព្រះយេស៊ូអស់កម្លាំងក្នុងការធ្វើដំណើរ ក៏គង់នៅមាត់អណ្ដូង ពេលនោះប្រហែលជាថ្ងៃត្រង់។ 7មានស្ដ្រីសាសន៍សាម៉ារីម្នាក់មកដងទឹក
ព្រះយេស៊ូមានព្រះបន្ទូលទៅនាងថា៖ «ខ្ញុំសុំទឹកទទួលទានបន្ដិច»។8(សិស្សនាំគ្នាទៅរកទិញស្បៀងអាហារនៅឯភូមិ)។ 9ស្ដ្រីសាម៉ារីទូលព្រះអង្គថា៖
«លោកជាសាសន៍យូដា ម្ដេចក៏លោកមកសុំទឹកនាងខ្ញុំ ជាស្ដ្រីសាសន៍សាម៉ារីពិសាដូច្នេះ?» (ដ្បិតសាសន៍យូដា និង
សាសន៍សាម៉ារីមិនត្រូវគ្នាទេ)។ 10ព្រះយេស៊ូមានព្រះបន្ទូលតបទៅនាងថា៖ «ប្រសិនបើនាងស្គាល់ព្រះអំណោយទានរបស់ព្រះជាម្ចាស់ និង
ស្គាល់អ្នកដែលនិយាយទៅកាន់នាងថា "ខ្ញុំសុំទឹកទទួលទានបន្ដិច" នោះនាងមុខជាសុំទឹកពីលោកវិញពុំខាន ហើយលោកនឹងអោយទឹកដល់នាង
គឺជាទឹកដែលផ្ដល់ជីវិត»។11នាងទូលព្រះអង្គថា៖ «លោកម្ចាស់!លោកគ្មានអ្វីដងទឹកសោះ រីឯអណ្ដូងសោតក៏ជ្រៅទៀតផង
តើលោកបានទឹកដែលផ្ដល់ជីវិតនោះពីណាមក?។ 12តើលោកមានឋានៈធំជាងលោកយ៉ាកុប ជាបុព្វបុរសរបស់យើង
ដែលបានទុកអណ្ដូងនេះអោយយើងឬ?។ លោកយ៉ាកុប និង កូនចៅរបស់លោកបានពិសាទឹកអណ្ដូងនេះហើយសត្វរបស់លោក
ក៏បានផឹកទឹកអណ្ដូងនេះដែរ»។ 13ព្រះយេស៊ូមានព្រះបន្ទូលទៅនាងថា៖ «អស់អ្នកដែលពិសាទឹកនេះ
នៅតែស្រេកតទៅមុខទៀត 14រីឯអ្នកដែលពិសាទឹកខ្ញុំអោយនោះ នឹងមិនស្រេកទៀតសោះឡើយ ដ្បិតទឹកខ្ញុំអោយនឹងបានទៅជាប្រភពទឹក
ដែលផុសឡើងផ្ដល់ជីវិតអស់កល្បជានិច្ច»។ 15ស្ដ្រីនោះទូលព្រះអង្គថា៖ «លោកម្ចាស់! សូមមេត្តាផ្ដល់ទឹកនោះមកនាងខ្ញុំផងកុំអោយនាងខ្ញុំស្រេក និង
កុំអោយវរល់មកដងទឹកអណ្ដូងនេះទៀត»។ 16ព្រះអង្គមានព្រះបន្ទូលទៅនាងថា៖ «សុំអញ្ជើញទៅហៅប្ដីនាង

រួចត្រឡប់មកវិញ»។17ស្ត្រីនោះទូលព្រះអង្គថា៖ «នាងខ្ញុំគ្មានប្ដីទេ»។ ព្រះយេស៊ូមានព្រះបន្ទូលថា៖ «នាងនិយាយថា នាងគ្មានប្ដីដូច្នេះ
ត្រូវមែន 18ព្រោះនាងធ្លាប់មានប្ដីប្រាំមកហើយ រីឯបុរសដែលនៅជាមួយនាងសព្វថ្ងៃ មិនមែនជាប្ដីរបស់នាងទេ
នាងនិយាយត្រង់មែន»។ 19នាងទូលព្រះអង្គថា៖ «លោកម្ចាស់
នាងខ្ញុំយល់ថាលោកពិតជាព្យាការីមែន។ 20បុព្វបុរសរបស់យើងនាំគ្នាថ្វាយបង្គំព្រះជាម្ចាស់នៅលើភ្នំនេះ
តែពួកលោកជាសាសន៍យូដាតែងនិយាយថាត្រូវថ្វាយបង្គំព្រះអង្គនៅក្រុងយេរូសាឡឹមវិញ»។ 21ព្រះយេស៊ូមានព្រះបន្ទូលទៅនាងថា៖
«នាងអើយជឿខ្ញុំចុះ ដល់ពេលកំណត់ មិនមែននៅលើភ្នំនេះឬ នៅក្រុងយេរូសាឡឹមទៀតទេ
ដែលអ្នករាល់គ្នានឹងថ្វាយបង្គំព្រះបិតា។ 22អ្នករាល់គ្នាមិនស្គាល់ព្រះអង្គដែលអ្នករាល់គ្នាថ្វាយបង្គំទេ រីឯយើងវិញ យើងស្គាល់ព្រះអង្គដែលយើងថ្វាយបង្គំ
ដ្បិតការសង្គ្រោះចេញមកពីជនជាតិយូដា។ 23ប៉ុន្តែ ដល់ពេលកំណត់ គឺឥឡូវហ្នឹងហើយ អ្នកថ្វាយបង្គំដ៏ពិតប្រាកដ នឹងថ្វាយបង្គំព្រះបិតាតាមវិញ្ញាណ
និង តាមសេចក្ដីពិត ដ្បិតព្រះបិតាសព្វព្រះហឫទ័យនឹងអ្នកថ្វាយបង្គំបែបនេះឯង។24ព្រះជាម្ចាស់ជាវិញ្ញាណ ហេតុនេះអស់អ្នកដែលថ្វាយបង្គំព្រះអង្គ
ត្រូវតែថ្វាយបង្គំតាមវិញ្ញាណ និង តាមសេចក្ដីពិត»។ 25ស្ត្រីនោះទូលព្រះអង្គថា៖ «នាងខ្ញុំដឹងហើយថា ព្រះមេស្ស៊ីហៅព្រះគ្រិស្ដនឹងយាងមក។
កាលណាព្រះអង្គយាងមកដល់ ទ្រង់នឹងប្រទានអោយយើងដឹងសព្វគ្រប់ទាំងអស់»។26ព្រះយេស៊ូមានព្រះបន្ទូលទៅនាងថា៖ «ខ្ញុំនេះហើយ
គឺខ្ញុំដែលកំពុងតែនិយាយជាមួយនាង»។ 27ពេលនោះ ពួកសិស្សត្រឡប់មកដល់ ឃើញព្រះអង្គកំពុងនិយាយជាមួយស្ត្រីដូច្នេះ គេងឿងឆ្ងល់ជាខ្លាំង
តែគ្មាននរណាទូលសួរព្រះអង្គ ថាព្រះអង្គសួររកអ្វីឬ ហេតុដូចម្ដេចក៏មានព្រះបន្ទូលជាមួយនាងឡើយ។ 28ស្ត្រីនោះទុកក្អមចោល រត់ចូលទៅក្នុងភូមិ
ប្រាប់អ្នកស្រុកថា៖ 29«សុំមកមើលបុរសម្នាក់ លោកមានប្រសាសន៍ប្រាប់ខ្ញុំ នូវអំពើទាំងប៉ុន្មានដែលខ្ញុំបានប្រព្រឹត្ត។

លោកនោះជាព្រះគ្រិស្ដហើយមើលទៅ!»។30អ្នកស្រុកនាំគ្នាចេញពីភូមិ ទៅរកព្រះយេស៊ូ។ 31ក្នុងពេលជាមួយគ្នានោះ ពួកសិស្សទូលព្រះអង្គថា៖

«លោកគ្រូសូមអញ្ជើញពិសា!»។32ព្រះអង្គមានព្រះបន្ទូលទៅគេថា៖ «ខ្ញុំមានអាហារបរិភោគហើយ

ជាអាហារដែលអ្នករាល់គ្នាពុំស្គាល់»។ 33ពួកសិស្សក៏និយាយគ្នាថា៖

«ប្រហែលជាមាននរណាម្នាក់យកអាហារមកជូនលោកហើយទេដឹង?»។34ព្រះយេស៊ូមានព្រះបន្ទូលទៅគេថា៖ «អាហាររបស់ខ្ញុំ

គឺធ្វើតាមព្រះហឫទ័យរបស់ព្រះអង្គ ដែលបានចាត់ខ្ញុំអោយមក ព្រមទាំងបង្ហើយកិច្ចការរបស់ព្រះអង្គអោយបានសំរេច។ 35អ្នករាល់គ្នាតែងពោលថា

"បួនខែទៀតដល់រដូវចំរូត"។ រីឯខ្ញុំវិញ ខ្ញុំសុំប្រាប់អ្នករាល់គ្នាថា ចូរមើលទៅវាលស្រែមើល៍ស្រូវទុំល្អមច្រូតហើយ។ 36អ្នកច្រូតបានប្រាក់ឈ្នួលរបស់ខ្លួន

ហើយកំពុងប្រមូលផលទុកសំរាប់ជីវិតអស់កល្បជានិច្ច ដូច្នេះអ្នកសាបព្រោះ និង

អ្នកច្រូតកាត់បានសប្បាយរួមជាមួយគ្នា 37ស្របតាមពាក្យចាស់លោកថាៈ"ម្នាក់ព្រោះ ម្នាក់ទៀតច្រូត"។ 38ខ្ញុំបានចាត់អ្នករាល់គ្នាអោយទៅច្រូត

នៅក្នុងស្រែដែលអ្នករាល់គ្នាពុំបានធ្វើការនឿយហត់ គឺអ្នកផ្សេងទៀតបានធ្វើការនឿយហត់

ហើយអ្នករាល់គ្នាទទួលផលពីការនឿយហត់របស់អ្នកទាំងនោះ»។ 39ក្នុងភូមិនោះ មានអ្នកស្រុកសាម៉ារីជាច្រើនបានជឿលើព្រះយេស៊ូ

ដោយសារពាក្យដែលស្ត្រីនោះបានបញ្ជាក់ប្រាប់ថា "លោកមានប្រសាសន៍ប្រាប់ខ្ញុំនូវអំពើទាំងប៉ុន្មានដែលខ្ញុំបានប្រព្រឹត្ត"។ 40ហេតុនេះហើយបានជា

កាលជនជាតិសាម៉ារីទៅគាល់ព្រះអង្គ គេអង្វរសូមព្រះអង្គគង់នៅជាមួយគេ ព្រះអង្គយល់ព្រមគង់នៅទីនោះពីរថ្ងៃ។ 41មានមនុស្សច្រើនជាងនោះ

ទៅទៀតបានជឿលើព្រះអង្គ ដោយបានឮព្រះបន្ទូលព្រះអង្គផ្ទាល់។ 42ពួកគេនិយាយទៅកាន់ស្ត្រីនោះថា៖ «ឥឡូវនេះ

យើងជឿមិនមែនត្រឹមតែឮពាក្យនាងប៉ុណ្ណោះទេ គឺមកពីយើងបានឮព្រះអង្គមានព្រះបន្ទូលផ្ទាល់នឹងត្រចៀកថែមទៀតផង

ហើយយើងដឹងថាព្រះអង្គពិតជាព្រះសង្គ្រោះរបស់មនុស្សលោកមែន»។43ពីរថ្ងៃក្រោយមក
ព្រះយេស៊ូយាងចាកចេញពីទីនោះឆ្ពោះទៅកាន់ស្រុកកាលីឡេ។ 44ព្រះអង្គមានព្រះបន្ទូលថា៖
«គ្មានព្យាការីណាម្នាក់ត្រូវគេគោរពក្នុងស្រុកកំណើតរបស់ខ្លួនផ្ទាល់ឡើយ»។ 45លុះព្រះអង្គយាងទៅដល់ស្រុកកាលីឡេ អ្នកស្រុកនាំគ្នាទទួលព្រះអង្គ
ព្រោះគេបានឃើញការអស្ចារ្យទាំងប៉ុន្មាន ដែលព្រះអង្គបានសំដែង ក្នុងឱកាសពិធីបុណ្យចម្លងនៅក្រុងយេរូសាឡឹម
ដ្បិតគេក៏បានទៅចូលរួមពិធីបុណ្យនោះដែរ។ 46ព្រះអង្គយាងត្រឡប់ទៅភូមិកាណា ក្នុងស្រុកកាលីឡេម្តងទៀត
ជាភូមិដែលព្រះអង្គបានធ្វើអោយទឹកទៅជាស្រាទំពាំងបាយជូរ។ នៅទីនោះ មានអ្នករាជការម្នាក់ មកពីក្រុងកាពើណិម
កូនប្រុសរបស់លោកមានជំងឺ។ 47កាលលោកជ្រាបថា ព្រះយេស៊ូបានយាងពីស្រុកយូដាមកស្រុកកាលីឡេនេះ លោកក៏ទៅរកព្រះអង្គ
ទូលអង្វរសូមព្រះអង្គយាងទៅប្រោសកូនរបស់លោកដែលកំពុងតែឈឺជិតផុតដង្ហើមនោះ
អោយបានជាសះស្បើយ។48ព្រះយេស៊ូមានព្រះបន្ទូលទៅគាត់ថា៖ «ប្រសិនបើអ្នករាល់គ្នាមិនបានឃើញទីសំគាល់ និង ឫទ្ធិបាដិហារិយ៍ទេ
អ្នករាល់គ្នាមុខជាមិនជឿឡើយ»។49មន្ត្រីនោះទូលព្រះអង្គថា៖ «លោកម្ចាស់អើយ សូមលោកអញ្ជើញមក
ក្រែងកូនរបស់ខ្ញុំប្របាទស្លាប់»។ 50ព្រះយេស៊ូមានព្រះបន្ទូលទៅគាត់ថា៖ «អញ្ជើញទៅចុះ កូនរបស់លោករស់ហើយ»។
បុរសនោះជឿព្រះបន្ទូលរបស់ព្រះយេស៊ូក៏ចេញដំណើរទៅ។ 51ពេលលោកកំពុងតែដើរតាមផ្លូវត្រឡប់ទៅផ្ទះវិញ ពួកបំរើរបស់លោកនាំគ្នាចេញមកជំរាបថា
កូនរបស់លោករស់ហើយ។ 52លោកក៏សួរអ្នកបំរើអោយដឹងថាកូនរបស់លោកបានធូរស្បើយពីថ្មើរណា។ គេតបថា៖
«កូនរបស់លោកបាត់គ្រុនពីម្សិលមិញ វេលាម៉ោងមួយរសៀល»។ 53ឪពុកដឹងថា គឺនៅម៉ោងនោះឯង

ដែលព្រះយេស៊ូមានព្រះបន្ទូលមកគាត់ថា "កូនរបស់លោករស់ហើយ!"។ លោកជឿលើព្រះយេស៊ូ ហើយក្រុមគ្រួសាររបស់លោកទាំងមូល
ក៏ជឿលើព្រះអង្គដែរ។54នេះជាទីសំគាល់លើកទីពីរដែលព្រះយេស៊ូបានធ្វើ នៅពេលដែលព្រះអង្គវិលត្រឡប់ពីស្រុកយូដាមកស្រុកកាលីឡេវិញ។

## JOHN - យ៉ូហាន 5

1ក្រោយមកទៀត មានពិធីបុណ្យមួយរបស់ជនជាតិយូដា ព្រះយេស៊ូយាងឡើងទៅក្រុងយេរូសាឡឹម។ 2នៅក្រុងយេរូសាឡឹម ជិតខ្លោងទ្វារឈ្មោះ
«ទ្វារចៀម» មានស្រះមួយដែលគេហៅជាភាសាហេប្រឺថា «ស្រះបេថែសដា» ក្បែរស្រះនោះ មានថែវប្រាំ។ 3មានអ្នកជំងឺ មនុស្សខ្វាក់មនុស្សខ្វិន
មនុស្សខ្វចជើង និង មនុស្សស្លាប់ដៃស្លាប់ជើងជាច្រើន ដេកនៅតាមថែវទាំងនោះ [រង់ចាំទឹកកំរើក 4ដ្បិតយូរៗម្តង មានទេវតាមួយរូប
ចុះមកធ្វើអោយទឹកស្រះកំរើក អ្នកណាចុះទៅក្នុងទឹកកំរើកបានមុនគេអ្នកនោះនឹងបានជា ទោះបីមានជំងឺអ្វីក៏ដោយ]។ 5នៅទីនោះ
មានបុរសម្នាក់ពិការតាំងពីសាមសិបប្រាំបីឆ្នាំមកហើយ។ 6ព្រះយេស៊ូទតឃើញគាត់ដេកដូច្នេះ ព្រះអង្គជ្រាបថា គាត់នៅទីនោះជាយូរមកហើយ
ទ្រង់មានព្រះបន្ទូលសួរគាត់ថា៖ «តើអ្នកចង់ជាឬទេ?»។ 7អ្នកនោះទូលព្រះអង្គថា៖ «លោកម្ចាស់អើយ ពេលទឹកកំរើក
គ្មាននរណាយកខ្ញុំទៅដាក់ក្នុងស្រះសោះ ហើយពេលណាខ្ញុំទៅដល់មានម្នាក់ចុះទៅមុនខ្ញុំស្រេចទៅហើយ»។ 8ព្រះយេស៊ូមានព្រះបន្ទូលទៅគាត់ថា៖
«ចូរក្រោកឡើង យកគ្រែស្នែងរបស់អ្នក ហើយដើរទៅចុះ»។ 9ពេលនោះស្រាប់តែបុរសនោះបានជាភ្លាម
គាត់ក៏យកគ្រែស្នែងរបស់គាត់ដើរទៅ។ 10រីឯថ្ងៃនោះ ជាថ្ងៃសប្ប័ទ ជនជាតិយូដាស្តីអោយបុរសដែលបានជានោះថា៖ «ថ្ងៃនេះជាថ្ងៃសប្ប័ទ

អ្នកគ្មានសិទ្ធិលីគ្រែស្នែងរបស់អ្នកដូច្នេះឡើយ»។ 11គាត់ឆ្លើយទៅគេថា៖ «លោកដែលបានធ្វើអោយខ្ញុំជា ប្រាប់ខ្ញុំថា
"ចូរយកគ្រែស្នែងរបស់អ្នកដើរទៅចុះ!"»។ 12គេសួរគាត់ថា៖ «តើលោកណាប្រាប់អ្នកអោយយកគ្រែស្នែងដើរទៅដូច្នេះ?»។13ប៉ុន្តែ
បុរសដែលបានជាមិនដឹងថានរណា បានប្រោសគាត់អោយជាឡើយ
ដ្បិតព្រះយេស៊ូបានយាងចេញពីបណ្ដាជនដែលនៅកន្លែងនោះផុតទៅហើយ។ 14ក្រោយមក ព្រះយេស៊ូជួបគាត់ក្នុងព្រះវិហារក៏មានព្រះបន្ទូលទៅគាត់ថា៖
«ឥឡូវនេះ អ្នកបានជាហើយ កុំប្រព្រឹត្តអំពើបាបទៀតអោយសោះ ក្រែងលោកើតការអាក្រក់ដល់អ្នក
លើសមុនទៅទៀត»។15បុរសនោះចេញទៅប្រាប់ជនជាតិយូដាអោយដឹងថា
គឺព្រះយេស៊ូដែលបានប្រោសគាត់អោយជា។ 16ហេតុនេះហើយបានជាជនជាតិយូដានាំគ្នាបៀតបៀនព្រះយេស៊ូ
ព្រោះព្រះអង្គធ្វើការនោះនៅថ្ងៃសប្ប័ទ។17ព្រះយេស៊ូមានព្រះបន្ទូលទៅគេថា៖«ព្រះបិតារបស់ខ្ញុំធ្វើការរហូតមកទល់សព្វថ្ងៃ
ខ្ញុំក៏ធ្វើការដូចព្រះអង្គដែរ»។ 18កាលឮព្រះបន្ទូលនេះ ជនជាតិយូដារឹតតែចង់ធ្វើគុតព្រះអង្គខ្លាំងឡើងៗ មិនមែនមកពីព្រះអង្គមិនបានគោរពតាមវិន័យ
សំរាប់ថ្ងៃសប្ប័ទប៉ុណ្ណោះទេ គឺមកពីព្រះអង្គមានព្រះបន្ទូលថា ព្រះជាម្ចាស់ជាព្រះបិតារបស់ព្រះអង្គផ្ទាល់ថែមទៀត
ព្រះអង្គលើកខ្លួនឡើងស្មើនឹងព្រះជាម្ចាស់។ 19ព្រះយេស៊ូមានព្រះបន្ទូលទៅគេថា៖ «ខ្ញុំសុំប្រាប់អោយអ្នករាល់គ្នាដឹងច្បាស់ថា
ព្រះបុត្រាពុំអាចធ្វើអ្វីដោយព្រះអង្គផ្ទាល់បានឡើយ គឺព្រះបុត្រាធ្វើតែកិច្ចការណា ដែលទ្រង់បានឃើញព្រះបិតាធ្វើប៉ុណ្ណោះ។ កិច្ចការអ្វីដែលព្រះបិតាធ្វើ
ព្រះបុត្រាក៏ធ្វើកិច្ចការនោះដែរ។ 20ព្រះបិតាមានព្រះហឫទ័យស្រឡាញ់ព្រះបុត្រា និង បង្ហាញអោយព្រះបុត្រាឃើញគ្រប់កិច្ចការដែលព្រះអង្គធ្វើ
ព្រះបិតានឹងបង្ហាញអោយព្រះបុត្រាឃើញកិច្ចការធំជាងនេះទៅទៀត

ដើម្បីអោយអ្នករាល់គ្នាងឿងឆ្ងល់។21ដូចព្រះបិតាប្រោសមនុស្សស្លាប់អោយមានជីវិតរស់ឡើងវិញ ព្រះបុត្រាប្រទានជីវិតអោយនរណាក៏បាន
ស្រេចតែនឹងព្រះហឫទ័យរបស់ព្រះអង្គ។22ព្រះបិតាមិនដាក់ទោសនរណាឡើយ
គឺព្រះអង្គបានប្រគល់អំណាចដាក់ទោសទាំងអស់អោយព្រះបុត្រាវិញ 23ដើម្បីអោយមនុស្សគ្រប់ៗគ្នាគោរពព្រះបុត្រា ដូចគេគោរពព្រះបិតា។
អ្នកណាមិនគោរពព្រះបុត្រាទេអ្នកនោះក៏មិនគោរពព្រះបិតា ដែលបានចាត់ព្រះបុត្រាអោយយាងមកនោះដែរ។24ខ្ញុំសុំប្រាប់អោយអ្នករាល់គ្នាដឹងច្បាស់ថា
អ្នកណាស្ដាប់សេចក្ដីដែលខ្ញុំនិយាយហើយជឿលើព្រះអង្គដែលបានចាត់ខ្ញុំអោយមក អ្នកនោះមានជីវិតអស់កល្បជានិច្ច គេមិនត្រូវទទួលទោសឡើយ
គឺបានឆ្លងផុតពីសេចក្ដីស្លាប់ទៅរកជីវិត។ 25ខ្ញុំសុំប្រាប់អោយអ្នករាល់គ្នាដឹងច្បាស់ថា ដល់ពេលកំណត់គឺឥឡូវនេះហើយ
មនុស្សស្លាប់នឹងឮព្រះសូរសៀងព្រះបុត្រារបស់ព្រះជាម្ចាស់
ហើយអស់អ្នកដែលឮព្រះសូរសៀងនោះនឹងមានជីវិតរស់នៅ26ដ្បិតព្រះបិតាជាប្រភពនៃជីវិតយ៉ាងណា
ព្រះអង្គក៏ប្រទានអោយព្រះបុត្រាធ្វើជាប្រភពនៃជីវិតយ៉ាងនោះដែរ 27ហើយព្រះបិតាក៏ប្រទានអោយព្រះបុត្រាមានអំណាចដាក់ទោស
ថែមទៀតផងព្រោះព្រះបុត្រាជាបុត្រមនុស្ស។ 28សុំកុំងឿងឆ្ងល់ឡើយ ដ្បិតដល់ពេលកំណត់
មនុស្សស្លាប់ទាំងប៉ុន្មាននឹងឮព្រះសូរសៀងរបស់ព្រះបុត្រា 29ហើយចេញពីផ្នូរមក។ អ្នកដែលបានប្រព្រឹត្តអំពើល្អនឹងរស់ឡើងវិញ ដើម្បីទទួលជីវិត
រីឯអ្នកដែលបានប្រព្រឹត្តអំពើអាក្រក់នឹងរស់ឡើងវិញ ដើម្បីទទួលទោស»។ 30«ខ្ញុំមិនអាចធ្វើអ្វីដោយអំណាចខ្ញុំផ្ទាល់បានឡើយ
ខ្ញុំវិនិច្ឆ័យគ្រប់ការទាំងអស់ តាមសេចក្ដីដែលព្រះបិតាមានព្រះបន្ទូលមកខ្ញុំ ហើយការវិនិច្ឆ័យរបស់ខ្ញុំត្រឹមត្រូវ ព្រោះខ្ញុំមិនប្រាថ្នាធ្វើតាមបំណងចិត្តខ្ញុំឡើយ
គឺធ្វើតាមព្រះហឫទ័យរបស់ព្រះអង្គដែលបានចាត់អោយខ្ញុំមកនោះវិញ។ 31ប្រសិនបើខ្ញុំធ្វើជាបន្ទាល់អោយខ្លួនខ្ញុំផ្ទាល់សក្ខីភាពរបស់ខ្ញុំមិនពិតទេ។ 32ប៉ុ

ន្តែ មានម្នាក់ទៀតធ្វើជាបន្ទាល់អោយខ្ញុំ ហើយខ្ញុំដឹងថាសក្ខីភាពដែលអ្នកនោះថ្លែងអំពីខ្ញុំ
ស្របតាមសេចក្ដីពិត។ 33អ្នករាល់គ្នាបានចាត់គេអោយទៅសួរលោកយ៉ូហាន លោកក៏ផ្ដល់សក្ខីភាពអំពីសេចក្ដីពិត។ 34ចំពោះខ្ញុំ
ខ្ញុំមិនត្រូវការសក្ខីភាពពីមនុស្សណាឡើយតែខ្ញុំពោលដូច្នេះ
ដើម្បីអោយអ្នករាល់គ្នាទទួលការសង្គ្រោះ។ 35លោកយ៉ូហាននេះប្រៀបបាននឹងចង្កៀងដែលកំពុងឆេះបំភ្លឺ ហើយអ្នករាល់គ្នាក៏ចង់រីករាយនឹងពន្លឺនោះ
មួយស្របក់ដែរ។ 36រីឯខ្ញុំវិញ ខ្ញុំមានសក្ខីភាពមួយប្រសើរជាងសក្ខីភាពរបស់លោកយ៉ូហានទៅទៀត។
ព្រះបិតាប្រទានអោយខ្ញុំបង្ហើយកិច្ចការទាំងអំបាលម៉ាន គឺកិច្ចការដែលខ្ញុំធ្វើនេះហើយ ជាសក្ខីភាពបញ្ជាក់ថា
ព្រះអង្គបានចាត់ខ្ញុំអោយមកមែន។ 37ព្រះបិតាដែលបានចាត់ខ្ញុំអោយមក ក៏បានធ្វើជាបន្ទាល់អោយខ្ញុំដែរ
តែអ្នករាល់គ្នាមិនដែលបានឮព្រះសូរសៀងរបស់ព្រះអង្គ
ហើយក៏មិនដែលបានឃើញព្រះភ័ក្ត្ររបស់ព្រះអង្គផង។ 38អ្នករាល់គ្នាគ្មានព្រះបន្ទូលរបស់ព្រះអង្គនៅក្នុងចិត្តទេ ព្រោះអ្នករាល់គ្នា
ពុំជឿអ្នកដែលព្រះបិតាបានចាត់អោយមក។39អ្នករាល់គ្នាខំពិនិត្យពិច័យមើលគម្ពីរ ព្រោះនឹកស្មានថា នឹងបានជីវិតអស់កល្បជានិច្ច
ដោយសារគម្ពីរទាំងនេះ គឺគម្ពីរនេះហើយធ្វើជាបន្ទាល់អោយខ្ញុំ40ប៉ុន្តែ
អ្នករាល់គ្នាមិនចង់មករកខ្ញុំដើម្បីអោយបានជីវិតឡើយ។ 41ខ្ញុំមិនចង់ទទួលសិរីរុងរឿងពីមនុស្សទេ។ 42ម្យ៉ាងទៀតខ្ញុំស្គាល់ចិត្តអ្នករាល់គ្នា
ហើយអ្នករាល់គ្នាគ្មានចិត្តស្រឡាញ់ព្រះជាម្ចាស់សោះ។ 43ខ្ញុំមក ក្នុងព្រះនាមព្រះបិតាខ្ញុំ តែអ្នករាល់គ្នាមិនទទួលខ្ញុំឡើយ។
ប្រសិនបើមានម្នាក់ទៀតមកក្នុងនាមខ្លួនគេផ្ទាល់
អ្នករាល់គ្នាមុខជាទទួលគេមិនខាន! 44តើអោយអ្នករាល់គ្នាអាចជឿដូចម្ដេចបានបើអ្នករាល់គ្នាចូលចិត្តទទួលសិរីរុងរឿងតែពីគ្នាទៅវិញទៅមកដូច្នេះ

ហើយពុំស្វែងរកសិរីរុងរឿងពីព្រះជាម្ចាស់តែមួយគត់សោះនោះ? 45កុំនឹកស្មានថាខ្ញុំនឹងចោទប្រកាន់អ្នករាល់គ្នា នៅចំពោះព្រះភ័ក្ត្រព្រះបិតាឡើយ
គឺលោកម៉ូសេជាទីសង្ឃឹមរបស់អ្នករាល់គ្នាវិញទេ ដែលនឹងចោទប្រកាន់។ 46ប្រសិនបើអ្នករាល់គ្នាជឿពាក្យលោកម៉ូសេ អ្នករាល់គ្នាមុខជាជឿខ្ញុំមិនខាន
ព្រោះលោកបានសរសេរទុកក្នុងគម្ពីរស្ដីអំពីខ្ញុំ 47ប៉ុន្តែ បើអ្នករាល់គ្នាមិនជឿសេចក្ដីដែលលោកបានសរសេរទុកទៅហើយនោះ
ធ្វើម្ដេចនឹងអោយអ្នករាល់គ្នាជឿពាក្យរបស់ខ្ញុំបាន!»។

# JOHN - យ៉ូហាន 6

1បន្ទាប់មក ព្រះយេស៊ូយាងទៅត្រើយខាងនាយសមុទ្រកាលីឡេ ដែលមានឈ្មោះថាសមុទ្រទីបេរាស។ 2មានបណ្ដាជនច្រើនកុះករមកតាមព្រះអង្គ
ព្រោះគេបានឃើញទីសំគាល់ដែលព្រះអង្គបានធ្វើ ដោយប្រោសអ្នកជំងឺអោយជា។ 3ព្រះយេស៊ូយាងឡើងទៅលើភ្នំ
ហើយគង់នៅទីនោះជាមួយពួកសិស្ស។ 4ពេលនោះ បុណ្យចម្លង ជាបុណ្យរបស់ជនជាតិយូដា
កាន់តែខិតជិតណាស់ហើយ។ 5ព្រះយេស៊ូទតឃើញបណ្ដាជនមកតាមព្រះអង្គច្រើនកុះករយ៉ាងនេះ
ទ្រង់មានព្រះបន្ទូលទៅលោកភីលីពថា៖«តើយើងទៅរកទិញអាហារឯណាមកចែកអោយអ្នកទាំងនេះបរិភោគបាន?»។6ព្រះអង្គមានព្រះបន្ទូលដូច្នេះ
ដើម្បីល្បងមើលចិត្តលោកភីលីព តាមពិត ព្រះអង្គជ្រាបអំពីកិច្ចការដែលព្រះអង្គបម្រុងនឹងធ្វើស្រេចទៅហើយ។7លោកភីលីពទូលថា៖
«ទោះបីយើងយកប្រាក់ពីររយដួងទៅទិញនំប៉័ងក៏មិនគ្រាន់ដែរ សូម្បីតែម្នាក់មួយដុំតូចៗក៏មិនបានផង»។ 8មានសិស្សម្នាក់ឈ្មោះអនទ្រេ

ជាប្អូនរបស់លោកស៊ីម៉ូនពេត្រុសទូលព្រះអង្គថា៖ 9«នៅទីនេះ ក្មេងប្រុសម្នាក់មាននំបុ័ងប្រាំដុំ និង ត្រីតូចៗពីរកន្ទុយ។ ប៉ុន្តែ
បើមានតែប៉ុណ្ណឹងធ្វើម្ដេចនឹងអោយគ្រាន់សំរាប់មនុស្សដ៏ច្រើនយ៉ាងនេះ?»។10ព្រះយេស៊ូមានព្រះបន្ទូលថា៖«សុំអោយគេអង្គុយចុះ»។
នៅទីនោះមានស្មៅច្រើន បណ្ដាជនក៏នាំគ្នាអង្គុយមានមនុស្សប្រុសទាំងអស់ប្រមាណប្រាំពាន់នាក់។ 11ព្រះយេស៊ូយកនំបុ័ងមកកាន់
អរព្រះគុណព្រះជាម្ចាស់រួចប្រទានអោយអ្នកអង្គុយនៅទីនោះ។ រីឯត្រីវិញព្រះអង្គក៏ធ្វើដូច្នោះដែរ ទ្រង់ប្រទានអោយគេ
តាមតែម្នាក់ៗចង់បាន។ 12លុះគេបានបរិភោគឆ្អែតហើយព្រះយេស៊ូមានព្រះបន្ទូលទៅពួកសិស្សថា៖ «ចូរប្រមូលនំបុ័ងដែលនៅសល់
កុំអោយមានបាត់មួយដុំសោះឡើយ»។ 13ពួកសិស្សនាំគ្នារើសសំណល់នំបុ័ងទាំងប្រាំដុំ ដែលបណ្ដាជនបរិភោគសល់
ប្រមូលដាក់បានពេញដប់ពីរល្អី?។ 14កាលមនុស្សម្នាឃើញទីសំគាល់ដែលព្រះយេស៊ូបានធ្វើនោះ ក៏ពោលថា៖ «លោកនេះពិតជាព្យាការី
ដែលត្រូវមកក្នុងពិភពលោកមែន»។15ព្រះយេស៊ូជ្រាបថាគេបំរុងនឹងចាប់ព្រះអង្គយកទៅតែងតាំងជាស្ដេចដូច្នេះ
ព្រះអង្គក៏យាងចាកចេញពីគេឡើងទៅលើភ្នំសាជាថ្មី តែមួយព្រះអង្គឯង។ 16លុះដល់ល្ងាច
ពួកសិស្សនាំគ្នាចុះទៅមាត់សមុទ្រ។ 17គេជិះទូកឆ្លងទៅក្រុងកាពើណិម នៅត្រើយម្ខាង។ ពេលនោះ ងងឹតហើយ
តែព្រះយេស៊ូពុំទាន់យាងមករកគេនៅឡើយទេ 18ខ្យល់បក់បោកមកយ៉ាងខ្លាំងបណ្ដាលអោយទឹកសមុទ្រមានរលកធំៗ។ 19កាលគេចែវទូកបានចម្ងាយ
ប្រមាណជាប្រាំ ឬ ប្រាំមួយគីឡូម៉ែត្រ ស្រាប់តែគេឃើញព្រះយេស៊ូយាងលើសមុទ្រ ចូលមកជិតទូកគេភ័យខ្លាចជាខ្លាំង។ 20ប៉ុន្តែ
ព្រះយេស៊ូមានព្រះបន្ទូលទៅគេថា៖ «ខ្ញុំទេតើ កុំខ្លាចអី»។ 21ពួកសិស្សចង់យាងព្រះអង្គចូលមកក្នុងទូក រំពេចនោះ ទូកក៏ទៅដល់ត្រើយ
ចំកន្លែងដែលគេបំរុងនឹងទៅ។ 22ថ្ងៃបន្ទាប់មកទៀត បណ្ដាជនដែលនៅត្រើយខាងនាយសមុទ្រ សង្កេតឃើញថា នៅកន្លែងនោះមានទូកតែមួយគត់

ហើយថាព្រះយេស៊ូពុំបានយាងចុះទូកជាមួយពួកសិស្សទេ គឺមានតែពួកសិស្សប៉ុណ្ណោះដែលបានជិះទូកចេញទៅ។ 23ប៉ុន្តែ
មានទូកឯទៀតៗមកពីភូមិទីបេរាសចតនៅជិតកន្លែងដែលគេបានបរិភោគនំប៉័ង
ក្រោយពីព្រះអម្ចាស់បានអរព្រះគុណ។ 24កាលបណ្ដាជនពុំឃើញព្រះយេស៊ូ និង
ពួកសិស្សនៅទីនោះទៀតគេក៏នាំគ្នាចុះទូកទាំងនោះឆ្លងទៅក្រុងកាពើណិមតាមរកព្រះអង្គ។ 25បណ្ដាជនបានជួបព្រះអង្គនៅត្រើយម្ខាង
គេទូលសួរព្រះអង្គថា៖ «លោកគ្រូ! តើលោកមកដល់ពីអង្កាល់?»។ 26ព្រះយេស៊ូមានព្រះបន្ទូលទៅគេថា៖ «ខ្ញុំសុំប្រាប់អោយអ្នករាល់គ្នាដឹងច្បាស់ថា
អ្នករាល់គ្នាតាមរកខ្ញុំ មិនមែនមកពីអ្នករាល់គ្នាបានឃើញទីសំគាល់ទេ គឺមកពីអ្នករាល់គ្នាបានបរិភោគអាហារឆ្អែតតែប៉ុណ្ណោះ។ 27កុំធ្វើកិច្ចការ
ដើម្បីអោយគ្រាន់តែបានអាហារ ដែលតែងរលួយខូចនោះឡើយ គឺអោយបានអាហារដែលនៅស្ថិតស្ថេរ និង ផ្ដល់ជីវិតអស់កល្បជានិច្ចវិញ
ជាអាហារដែលបុត្រមនុស្សនឹងប្រទានអោយអ្នករាល់គ្នា ដ្បិតបុត្រមនុស្សនេះហើយ
ដែលព្រះជាម្ចាស់ជាព្រះបិតាបានដៅសញ្ញាសំគាល់»។ 28គេនាំគ្នាទូលសួរព្រះអង្គថា៖
«តើអោយយើងខ្ញុំប្រព្រឹត្តដូចម្ដេចដើម្បីនឹងធ្វើកិច្ចការរបស់ព្រះជាម្ចាស់?»។ 29ព្រះយេស៊ូមានព្រះបន្ទូលថា៖«កិច្ចការរបស់ព្រះជាម្ចាស់គឺអោយអ្នករាល់
គ្នាជឿលើអ្នក ដែលព្រះអង្គបានចាត់អោយមក»។30គេទូលសួរព្រះអង្គទៀតថា៖ «តើលោកធ្វើការអ្វីជាទីសំគាល់អោយយើងខ្ញុំឃើញ និង
ជឿលោក?តើលោកធ្វើកិច្ចការអ្វីខ្លះ?។ 31បុព្វបុរសរបស់យើងបានបរិភោគនំម៉ាណា នៅវាលរហោស្ថានដូចមានសេចក្ដីចែងទុកក្នុងគម្ពីរថា
"ព្រះអង្គបានប្រទានអោយគេបរិភោគនំប៉័ង ដែលធ្លាក់ពីស្ថានបរមសុខមក"»។ 32ព្រះយេស៊ូមានព្រះបន្ទូលទៅគេថា៖
«ខ្ញុំសុំប្រាប់អោយអ្នករាល់គ្នាដឹងច្បាស់ថា មិនមែនលោកម៉ូសេទេ ដែលបានផ្ដល់អាហារ ពីស្ថានបរមសុខមកនោះ គឺព្រះបិតារបស់ខ្ញុំទេតើ

ដែលប្រទានអាហារដ៏ពិតប្រាកដពីស្ថានបរមសុខ មកអោយអ្នករាល់គ្នា 33ដ្បិតអាហារដែលព្រះជាម្ចាស់ប្រទានអោយនោះ
គឺអ្នកដែលចុះពីស្ថានបរមសុខមក ហើយផ្ដល់ជីវិតអោយមនុស្សលោក»។ 34គេនាំគ្នាទូលព្រះអង្គថា៖ «លោកម្ចាស់អើយ!
សូមលោកប្រទានអាហារនោះអោយយើងខ្ញុំ រហូតតទៅ»។35ព្រះយេស៊ូមានព្រះបន្ទូលថា៖ «ខ្ញុំនេះហើយជាអាហារដែលផ្ដល់ជីវិត។ អ្នកណាមករកខ្ញុំ
លែងឃ្លានទៀតហើយ អ្នកណាជឿលើខ្ញុំ ក៏លែងស្រេកទៀតដែរ។ 36ប៉ុន្ដែ ខ្ញុំបាននិយាយប្រាប់អ្នករាល់គ្នារួចហើយថា "អ្នករាល់គ្នាបានឃើញខ្ញុំ
តែអ្នករាល់គ្នាមិនជឿទេ"។ 37អស់អ្នកដែលព្រះបិតាប្រទានមកខ្ញុំតែងតែមករកខ្ញុំ
ហើយខ្ញុំមិនបោះបង់ចោលអ្នកដែលមករកខ្ញុំជាដាច់ខាត 38ដ្បិតខ្ញុំចុះពីស្ថានបរមសុខមក
ដើម្បីធ្វើតាមព្រះហឫទ័យរបស់ព្រះអង្គដែលបានចាត់ខ្ញុំអោយមក គឺពុំមែនធ្វើតាមបំណងចិត្តរបស់ខ្ញុំទេ។39រីឯព្រះអង្គដែលបានចាត់ខ្ញុំអោយមកនោះ
ទ្រង់មិនសព្វព្រះហឫទ័យអោយនរណាម្នាក់ ក្នុងបណ្ដាអស់អ្នកដែលព្រះអង្គប្រទានមកខ្ញុំត្រូវវិនាសអន្ដរាយឡើយ
តែព្រះអង្គសព្វព្រះហឫទ័យអោយខ្ញុំប្រោសគេ អោយមានជីវិតរស់ឡើងវិញ
នៅថ្ងៃចុងក្រោយបំផុត។ 40ព្រះបិតារបស់ខ្ញុំសព្វព្រះហឫទ័យអោយអស់អ្នកដែលបានឃើញព្រះបុត្រា ហើយជឿលើព្រះអង្គមានជីវិតអស់កល្បជានិច្ច។
ខ្ញុំនឹងប្រោសអ្នកនោះអោយមានជីវិតរស់ឡើងវិញ នៅថ្ងៃចុងក្រោយបំផុតផង»។ 41ជនជាតិយូដារអ៊ូរទាំពីព្រះយេស៊ូ ព្រោះព្រះអង្គមានព្រះបន្ទូលថា
"ខ្ញុំជាអាហារដែលចុះមកពីស្ថានបរមសុខ"។42គេពោលថា៖ «អ្នកនេះឈ្មោះយេស៊ូជាកូនរបស់លោកយ៉ូសែបទេតើ! យើងស្គាល់ទាំងឪពុកទាំងម្ដាយ
ម្ដេចក៏គាត់ពោលថាគាត់ចុះមកពីស្ថានបរមសុខដូច្នេះ?»។ 43ព្រះយេស៊ូមានព្រះបន្ទូលទៅគេថា៖
«ឈប់នាំគ្នារអ៊ូរទាំទៅ!។ 44ប្រសិនបើព្រះបិតាដែលចាត់ខ្ញុំអោយមកមិនទាក់ទាញចិត្តគេទេ គ្មាននរណាម្នាក់អាចមករកខ្ញុំបានឡើយ។

រីឯខ្ញុំខ្ញុំនឹងប្រោសអ្នកនោះអោយមានជីវិតរស់ឡើងវិញ នៅថ្ងៃចុងក្រោយបំផុត។ 45ក្នុងគម្ពីរព្យាការី
មានចែងទុកមកថា "ព្រះជាម្ចាស់នឹងប្រៀនប្រដៅមនុស្សទាំងអស់"។ អស់អ្នកដែលបានស្ដាប់ព្រះបិតា ហើយទទួលយកការប្រៀនប្រដៅរបស់ព្រះអង្គ
មុខជាមករកខ្ញុំពុំខាន។ 46សេចក្ដីនេះពុំមែនមានន័យថា មាននរណាម្នាក់បានឃើញព្រះបិតាឡើយ
លើកលែងតែអ្នកមកពីព្រះជាម្ចាស់ប៉ុណ្ណោះគឺអ្នកនោះហើយដែលបានឃើញព្រះអង្គ។ 47ខ្ញុំសុំប្រាប់អោយអ្នករាល់គ្នាដឹងច្បាស់ថា អ្នកណាជឿ
អ្នកនោះមានជីវិតអស់កល្បជានិច្ច។ 48ខ្ញុំនេះហើយជាអាហារដែលផ្ដល់ជីវិត។ 49បុព្វបុរសរបស់អ្នករាល់គ្នាបានបរិភោគនំម៉ាណា នៅវាលរហោស្ថាន
ហើយទទួលមរណភាពអស់ទៅ។50រីឯអាហារដែលចុះមកពីស្ថានបរមសុខ មានប្រសិទ្ធភាពបែបនេះ
គឺអ្នកណាបរិភោគអ្នកនោះមិនស្លាប់ឡើយ។ 51ខ្ញុំនេះហើយជាអាហារដែលមានជីវិត ចុះមកពីស្ថានបរមសុខ។ អ្នកណាបរិភោគអាហារនេះ
នឹងរស់នៅអស់កល្បជានិច្ច។ អាហារដែលខ្ញុំនឹងអោយនោះ គឺខ្លួនខ្ញុំ
ផ្ទាល់ដែលត្រូវបូជាសំរាប់អោយមនុស្សលោកមានជីវិត»។ 52ជនជាតិយូដាទាស់ទែងគ្នាយ៉ាងខ្លាំង ហើយគេនិយាយថា៖
«តើអ្នកនេះអាចអោយខ្លួនគាត់ផ្ទាល់ មកយើងបរិភោគដូចម្ដេចកើត?»។ 53ព្រះយេស៊ូមានព្រះបន្ទូលទៅគេថា៖
«ខ្ញុំសុំប្រាប់អោយអ្នករាល់គ្នាដឹងច្បាស់ថា ប្រសិនបើអ្នករាល់គ្នាមិនពិសាសាច់ និង លោហិតរបស់បុត្រមនុស្សទេ
អ្នករាល់គ្នាគ្មានជីវិតក្នុងខ្លួនឡើយ។54អ្នកណាពិសាសាច់ និង លោហិតរបស់ខ្ញុំ អ្នកនោះមានជីវិតអស់កល្បជានិច្ច
ហើយខ្ញុំក៏នឹងប្រោសគេអោយមានជីវិតរស់ឡើងវិញ នៅថ្ងៃចុងក្រោយបំផុតផង។ 55សាច់របស់ខ្ញុំជាអាហារដ៏ពិតប្រាកដ
លោហិតរបស់ខ្ញុំក៏ជាភេសជ្ជៈដ៏ពិតប្រាកដដែរ។ 56អ្នកណាពិសាសាច់ និង លោហិតរបស់ខ្ញុំ អ្នកនោះស្ថិតនៅក្នុងខ្ញុំ

ហើយខ្ញុំក៏ស្ថិតនៅក្នុងអ្នកនោះដែរ។ 57ព្រះបិតាដែលបានចាត់ខ្ញុំអោយមក ទ្រង់មានព្រះជន្មរស់
ហើយខ្ញុំមានជីវិតដោយសារព្រះអង្គយ៉ាងណាអ្នកបរិភោគខ្ញុំ ក៏នឹងមានជីវិតរស់
ដោយសារខ្ញុំយ៉ាងនោះដែរ។ 58អាហារដែលបានចុះពីស្ថានបរមសុខមកមានប្រសិទ្ធភាពខុសពីអាហារដែលបុព្វបុរសរបស់អ្នករាល់គ្នាបានបរិភោគ
ដ្បិតលោកទទួលមរណភាពអស់ទៅហើយ។ រីឯអ្នកដែលបរិភោគអាហារនេះនឹងរស់នៅអស់កល្បជានិច្ច»។ 59ព្រះយេស៊ូមានព្រះបន្ទូលទាំងនេះ
នៅពេលព្រះអង្គបង្រៀនគេក្នុងសាលាប្រជុំ នៅក្រុងកាពើណិម។ 60ក្រោយពីបានស្ដាប់ព្រះបន្ទូលរបស់ព្រះអង្គហើយ ក្នុងចំណោមសិស្ស
មានគ្នាច្រើនពោលថា៖ «ពាក្យទាំងនេះទាស់ត្រចៀកណាស់ តើនរណាអាចទ្រាំស្ដាប់បាន?»។ 61ព្រះយេស៊ូឈ្វេងយល់ថា
ពួកសិស្សរអ៊ូរទាំពីពាក្យទាំងនេះ ព្រះអង្គមានព្រះបន្ទូលទៅគេថា៖ «តើពាក្យទាំងនេះនាំអោយអ្នករាល់គ្នារវាតចិត្ត
បាត់ជំនឿឬ? 62ចុះបើអ្នករាល់គ្នាឃើញបុត្រមនុស្សឡើងទៅស្ថានដែលលោកនៅពីមុនវិញ
តើចិត្តអ្នករាល់គ្នានឹងទៅជាយ៉ាងណា?។63មានតែព្រះវិញ្ញាណទេដែលផ្ដល់ជីវិត និស្ស័យលោកីយ៍គ្មានប្រយោជន៍អ្វីឡើយ។
រីឯពាក្យទាំងប៉ុន្មានដែលខ្ញុំបាននិយាយប្រាប់អ្នករាល់គ្នា សុទ្ធតែចេញមកពីព្រះវិញ្ញាណដែលផ្ដល់ជីវិត។ 64ប៉ុន្តែក្នុងចំណោមអ្នករាល់គ្នា
អ្នកខ្លះគ្មានជំនឿទេ»។ តាំងពីដើមដំបូងមក ព្រះយេស៊ូស្គាល់អស់អ្នកដែលគ្មានជំនឿ ព្រមទាំងស្គាល់អ្នកដែលនឹងក្បត់ព្រះអង្គ
រួចស្រេចទៅហើយ។65ព្រះអង្គមានព្រះបន្ទូលទៀតថា៖ «ហេតុនេះបានជាខ្ញុំប្រាប់អ្នករាល់គ្នារួចមកហើយថា ប្រសិនបើព្រះបិតាមិនប្រោសប្រទានទេ
នោះគ្មាននរណាអាចមករកខ្ញុំបានឡើយ»។ 66ចាប់ពីពេលនោះមក ក្នុងចំណោមសិស្ស មានគ្នាច្រើនដកខ្លួនថយ
ឈប់តាមព្រះអង្គទៀត។ 67ព្រះយេស៊ូក៏មានព្រះបន្ទូលសួរសិស្សទាំងដប់ពីររូបថា៖ «ចុះអ្នករាល់គ្នាវិញ

តើអ្នករាល់គ្នាចង់ចេញទៅដែរឬ?»។ 68លោកស៊ីម៉ូនពេត្រុសទូលព្រះអង្គថា៖ «បពិត្រព្រះអម្ចាស់ តើអោយយើងខ្ញុំទៅរកនរណាវិញ?
ព្រះបន្ទូលរបស់ព្រះអង្គផ្តល់ជីវិតអស់កល្បជានិច្ច។ 69យើងខ្ញុំជឿហើយដឹងថា ព្រះអង្គពិតជាព្រះដ៏វិសុទ្ធដែលព្រះជាម្ចាស់ចាត់អោយមក
»។ 70ព្រះយេស៊ូមានព្រះបន្ទូលទៅគេថា៖ «គឺខ្ញុំផ្ទាល់ដែលបានជ្រើសរើសអ្នកទាំងដប់ពីរមក ក៏ប៉ុន្តែ
ក្នុងចំណោមអ្នករាល់គ្នាមានម្នាក់ជាមារ»។ 71ព្រះអង្គមានព្រះបន្ទូលសំដៅទៅលើយូដាស ជាកូនលោកស៊ីម៉ូនអ៊ីស្ការីយ៉ុត។
យូដាសនេះហើយដែលនឹងក្បត់ព្រះអង្គ ទោះបីគាត់ជាសិស្សមួយរូប ក្នុងចំណោមសិស្សទាំងដប់ពីរក៏ដោយ។

# JOHN - យ៉ូហាន 7

1ក្រោយមក ព្រះយេស៊ូយាងចុះឡើងកាត់ស្រុកកាលីឡេ ដ្បិតព្រះអង្គមិនសព្វព្រះហឫទ័យយាងទៅស្រុកយូដាឡើយ
ព្រោះជនជាតិយូដារកធ្វើគុតព្រះអង្គ។ 2ពេលនោះ ជិតដល់ថ្ងៃបុណ្យមួយរបស់ជនជាតិយូដា ឈ្មោះបុណ្យបារាំ។ 3បងប្អូនព្រះយេស៊ូទូលព្រះអង្គថា៖
«សូមបងចាកចេញពីទីនេះទៅស្រុកយូដាទៅ
ដើម្បីអោយសិស្សរបស់បងឃើញកិច្ចការដែលបងធ្វើ។ 4អ្នកដែលចង់អោយគេស្គាល់ខ្លួនមិនធ្វើការអ្វីដោយលាក់កំបាំងឡើយ។
បើបងធ្វើការអស្ចារ្យយ៉ាងនេះត្រូវបង្ហាញអោយមនុស្សលោកឃើញផង»។ 5បងប្អូនរបស់ព្រះយេស៊ូពុំជឿលើព្រះអង្គទេ។ 6ព្រះយេស៊ូមានព្រះបន្ទូលទៅ
គេថា៖ «ពេលកំណត់របស់បងមិនទាន់មកដល់នៅឡើយទេ។ រីឯប្អូនៗវិញ ចង់ធ្វើអ្វីពេលណាក៏បាន។ 7មនុស្សលោកមិនអាចស្អប់ប្អូនៗបានឡើយ ប៉ុន្តែ

គេស្អប់បង ព្រោះបងបានបញ្ជាក់ប្រាប់ថា អំពើដែលគេប្រព្រឹត្ត សុទ្ធតែអាក្រក់។ 8ចូរប្អូនៗឡើងទៅចូលរួមក្នុងពិធីបុណ្យទៅ បងមិនឡើងទៅទេ
ព្រោះពេលកំណត់របស់បងមិនទាន់មកដល់នៅឡើយ»។ 9ព្រះយេស៊ូមានព្រះបន្ទូលដូច្នោះហើយព្រះអង្គក៏គង់នៅក្នុងស្រុកកាលីឡេតទៅទៀត។ 10កា
លប្អូនៗរបស់ព្រះយេស៊ូធ្វើដំណើរទៅចូលរួមពិធីបុណ្យផុតអស់ទៅ ព្រះអង្គក៏យាងឡើងទៅដែរ ប៉ុន្តែ
ទ្រង់យាងទៅស្ងាត់ៗមិនអោយនរណាឃើញឡើយ។ 11ក្នុងឱកាសបុណ្យនោះ
ជនជាតិយូដាតាមរកព្រះយេស៊ូគេសួរគ្នាថា៖«តើលោកនៅឯណា?»។12បណ្ដាជនខ្សឹបខ្សៀវគ្នាជាច្រើនស្ដីអំពីព្រះអង្គ
ខ្លះថា«លោកនោះជាមនុស្សល្អ» ខ្លះទៀតថា «ទេ អ្នកនោះជាអ្នកបញ្ឆោតបណ្ដាជន»។ 13ប៉ុន្តែ
គ្មាននរណាហ៊ាននិយាយអំពីព្រះអង្គដោយចំហឡើយ ព្រោះគេខ្លាចសាសន៍យូដា។ 14លុះដល់ពាក់កណ្ដាលពិធីបុណ្យព្រះយេស៊ូយាងឡើងទៅព្រះវិហារ
ហើយបង្រៀនបណ្ដាជន។ 15ជនជាតិយូដាងឿងឆ្ងល់ជាខ្លាំង គេពោលថា៖«អ្នកនេះមិនបានរៀនសូត្រអ្វីសោះ
ចុះម្ដេចបានជាគាត់ចេះដឹងជ្រៅជ្រះដូច្នេះ?»។ 16ព្រះយេស៊ូមានព្រះបន្ទូលឆ្លើយថា៖ «សេចក្ដីដែលខ្ញុំបង្រៀនមិនមែនចេញពីខ្ញុំទេ
គឺចេញពីព្រះជាម្ចាស់ដែលបានចាត់ខ្ញុំអោយមក។ 17អ្នកដែលចង់ធ្វើតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់មុខជាដឹងថា សេចក្ដីដែលខ្ញុំបង្រៀននេះ
មកពីព្រះអង្គ ឬមកពីខ្ញុំផ្ទាល់មិនខាន។18អ្នកណានិយាយដោយសំអាងលើខ្លួនផ្ទាល់អ្នកនោះរកកិត្តិយសសំរាប់តែខ្លួនឯងប៉ុណ្ណោះ។
រីឯអ្នកដែលរកតែសិរីរុងរឿងរបស់ព្រះអង្គដែលចាត់ខ្លួនអោយមកនិយាយតែសេចក្ដីពិតឥតកុហកឡើយ។ 19លោកម៉ូសេប្រគល់ក្រឹត្យវិន័យទុកអោយអ្នករា
ល់គ្នារួចស្រេចហើយ ប៉ុន្តែ ក្នុងចំណោមអ្នករាល់គ្នាគ្មាននរណាម្នាក់ប្រតិបត្តិតាមក្រឹត្យវិន័យនោះទេ។
ហេតុអ្វីបានជាអ្នករាល់គ្នារកសម្លាប់ខ្ញុំដូច្នេះ?»។ 20បណ្ដាជនតបទៅព្រះអង្គថា៖ «លោកពិតជាមានអារក្សចូលហើយ បានជានិយាយដូច្នេះ

តើនរណារកសម្លាប់លោក?»។21ព្រះយេស៊ូមានព្រះបន្ទូលទៅគេថា៖ «ខ្ញុំបានធ្វើកិច្ចការតែមួយ
ហើយអ្នកទាំងអស់គ្នាបែរជាងឿងឆ្ងល់ទៅវិញ។ 22លោកម៉ូសេបានបង្គាប់អ្នករាល់គ្នាអោយធ្វើពិធីកាត់ស្បែក (តាមពិត
គឺបុព្វបុរសរបស់អ្នករាល់គ្នាឯណោះ ជាអ្នកបង្គាប់អោយធ្វើពិធីនេះមិនមែនលោកម៉ូសេទេ)
ហើយអ្នករាល់គ្នាធ្វើពិធីកាត់ស្បែកនៅថ្ងៃសប្ប័ទ។ 23បើអ្នករាល់គ្នាធ្វើពិធីកាត់ស្បែកនៅថ្ងៃសប្ប័ទ តែឥតបំពានលើវិន័យរបស់លោកម៉ូសេទេនោះ
ចុះហេតុដូចម្ដេចបានជាអ្នករាល់គ្នាខឹងខ្ញុំដែលបានប្រោសមនុស្សម្នាក់មួយទាំងមូលអោយបានជា
នៅថ្ងៃសប្ប័ទដូច្នេះ? 24កុំនាំគ្នាវិនិច្ឆ័យដោយគ្រាន់តែឃើញផ្នែកខាងក្រៅនោះឡើយ
ចូរវិនិច្ឆ័យអោយបានត្រឹមត្រូវវិញ»។ 25មានអ្នកក្រុងយេរូសាឡឹមខ្លះពោលថា៖ «លោកនេះហើយដែលគេរកសម្លាប់ 26ឥឡូវនេះ
លោកនិយាយដោយចេញមុខ ចុះម្ដេចបានជាគ្មាននរណាថាអ្វីលោកដូច្នេះ?។ ប្រហែលអ្នកដឹកនាំរបស់យើងទទួលស្គាល់ថា
លោកពិតជាព្រះគ្រិស្ដទេដឹង27ប៉ុន្ដែ ពេលព្រះគ្រិស្ដយាងមក គ្មាននរណាដឹងថាទ្រង់យាងមកពីណាទេ។ រីឯលោកនេះវិញ
យើងដឹងហើយថាគាត់មកពីណា»។ 28ពេលនោះ ព្រះយេស៊ូបង្រៀនបណ្ដាជនក្នុងព្រះវិហារព្រះអង្គបន្លឺព្រះសូរសៀងខ្លាំងៗថា៖
«អ្នករាល់គ្នាថាស្គាល់ខ្ញុំ ហើយដឹងថាខ្ញុំមកពីណាទៀត!។ ក៏ប៉ុន្ដែ ខ្ញុំមិនមែនមកក្នុងនាមខ្ញុំឡើយ ព្រះអង្គដែលចាត់ខ្ញុំអោយមក ទ្រង់សំដែងសេចក្ដីពិត
តែអ្នករាល់គ្នាមិនស្គាល់ព្រះអង្គទេ។ 29រីឯខ្ញុំវិញ ខ្ញុំស្គាល់ព្រះអង្គ ព្រោះខ្ញុំចេញមកពីព្រះអង្គ ហើយទ្រង់បានចាត់ខ្ញុំអោយមក»។30ពេលនោះ
ពួកគេរកចាប់ព្រះយេស៊ូ ប៉ុន្ដែ គ្មាននរណាហ៊ានលូកដៃចាប់ព្រះអង្គទេ ព្រោះពេលកំណត់របស់ព្រះអង្គ
ពុំទាន់បានមកដល់នៅឡើយ។31ក្នុងចំណោមបណ្ដាជន មាននមនុស្សជាច្រើនបានជឿលើព្រះយេស៊ូគេពោលថា៖ «ពេលព្រះគ្រិស្ដយាងមក

តើព្រះអង្គនឹងសំដែងទីសំគាល់ច្រើនជាងលោកនេះឬ?»។ 32ពួកខាងគណៈផារីស៊ីបានដឹងសេចក្ដីទាំងអស់ដែលបណ្ដាជនខ្សឹបខ្សៀវគ្នាអំពីព្រះយេស៊ូ។
ពេលនោះពួកនាយកបូជាចារ្យ និង ពួកខាងគណៈផារីស៊ី ក៏ចាត់កងរក្សាព្រះវិហារអោយមកចាប់ព្រះអង្គ។33ព្រះយេស៊ូមានព្រះបន្ទូលថា៖
«ខ្ញុំនៅជាមួយអ្នករាល់គ្នាតែមួយរយៈពេលដ៏ខ្លីទៀតប៉ុណ្ណោះ បន្ទាប់មក
ខ្ញុំនឹងទៅឯព្រះអង្គដែលបានចាត់ខ្ញុំអោយមកនោះវិញហើយ។ 34អ្នករាល់គ្នានឹងតាមរកខ្ញុំ តែរកមិនឃើញទេ
ដ្បិតអ្នករាល់គ្នាពុំអាចទៅកន្លែងដែលខ្ញុំនៅនោះ បានឡើយ»។ 35ជនជាតិយូដាសួរគ្នាថា៖ «តើគាត់បំរុងទៅណា
បានជាយើងពុំអាចនឹងរកគាត់ឃើញដូច្នេះ? តើគាត់គិតទៅនៅជាមួយជនជាតិយូដាដែលខ្ចាត់ខ្ចាយក្នុងចំណោមជនជាតិក្រិក
ហើយបង្រៀនពួកក្រិកឬ? 36គាត់មានប្រសាសន៍ថា "អ្នករាល់គ្នានឹងតាមរកខ្ញុំតែរកមិនឃើញទេ
ដ្បិតអ្នករាល់គ្នាពុំអាចទៅកន្លែងដែលខ្ញុំនៅនោះបានឡើយ" តើមានន័យដូចម្ដេច?»។ 37នៅថ្ងៃបញ្ចប់ពិធីបុណ្យ ជាថ្ងៃឱឡារិកបំផុត
ព្រះយេស៊ូឈរនៅមុខបណ្ដាជន បន្លឺព្រះសូរសៀងយ៉ាងខ្លាំងថា៖ «អ្នកណាស្រេកទឹក សុំអញ្ជើញមករកខ្ញុំ ហើយពិសាចុះ។38អ្នកណាជឿលើខ្ញុំ
នឹងមានទន្លេបង្ហូរទឹកផ្ដល់ជីវិត ចេញពីអ្នកនោះមក
ដូចមានចែងទុកក្នុងគម្ពីរមកស្រាប់»។ 39ព្រះអង្គមានព្រះបន្ទូលដូច្នេះសំដៅទៅលើព្រះវិញ្ញាណដែលអស់អ្នកជឿលើព្រះអង្គនឹងត្រូវទទួលដ្បិតពេលនោះ
ព្រះជាម្ចាស់ពុំទាន់បានប្រទានព្រះវិញ្ញាណមកទេ ពីព្រោះព្រះយេស៊ូពុំទាន់សំដែងសិរីរុងរឿង នៅឡើយ។ 40ក្រោយពីបានឮព្រះបន្ទូលរបស់ព្រះអង្គហើយ
ក្នុងចំណោមបណ្ដាជន
មានអ្នកខ្លះពោលថា៖«លោកនេះពិតជាព្យាការីដែលយើងរង់ចាំនោះមែន!»។ 41អ្នកខ្លះទៀតពោលថា៖«លោកនេះជាព្រះគ្រិស្ដ»។ ប៉ុន្តែ

មានអ្នកផ្សេងទៀតពោលជំទាស់ថា៖ «ព្រះគ្រិស្ដមិនមែនមកពីស្រុកកាលីឡេទេ 42ដ្បិតមានចែងទុកក្នុងគម្ពីរថា
"ព្រះគ្រិស្ដជាព្រះរាជវង្សរបស់ព្រះបាទដាវីឌ ហើយព្រះអង្គនឹងយាងមកពីភូមិបេថ្លេហិម ជាភូមិកំណើតរបស់ព្រះបាទដាវីឌ"
»។ 43បណ្ដាជនក៏បាក់បែកគ្នា ព្រោះតែព្រះអង្គ។ 44ក្នុងចំណោមបណ្ដាជន មានអ្នកខ្លះចង់ចាប់ព្រះអង្គ ប៉ុន្តែ
គ្មាននរណាហ៊ានចាប់ព្រះអង្គឡើយ។ 45កងរក្សាព្រះវិហារ វិលទៅជួបពួកនាយកបូជាចារ្យ និង ពួកខាងគណៈផារីស៊ីវិញ លោកទាំងនោះសួរពួកគេថា៖
«ហេតុដូចម្ដេចបានជាអ្នករាល់គ្នាមិនចាប់គាត់នាំយកមក?»។ 46កងរក្សាព្រះវិហារឆ្លើយថា៖
«ពុំដែលមាននរណានិយាយដូចលោកនោះឡើយ»។ 47ពួកខាងគណៈផារីស៊ីពោលទៅគេវិញថា៖
«អ្នករាល់គ្នាចាញ់បោកអ្នកនោះដែរឬ! 48ក្នុងចំណោមអ្នកដឹកនាំ និង ក្នុងចំណោមពួកខាងគណៈផារីស៊ី
គ្មាននរណាជឿលើអ្នកនោះសោះ49មានតែបណ្ដាជនដែលមិនស្គាល់ក្រឹត្យវិន័យទេ ដែលជឿ។
ពួកនោះសុទ្ធតែត្រូវបណ្ដាសា!»។ 50ក្នុងចំណោមពួកខាងគណៈផារីស៊ី មានបុរសម្នាក់ឈ្មោះ នីកូដេម ជាអ្នកដែលបានទៅគាល់ព្រះយេស៊ូកាលពីមុន
មានប្រសាសន៍ថា៖ 51«តាមច្បាប់របស់យើង យើងមិនអាចដាក់ទោសនរណាម្នាក់បានឡើយ ដរាបណាមិនទាន់បានឮពាក្យរបស់គេ
ហើយមិនបានដឹងអំពីកិច្ចការដែលគេបានប្រព្រឹត្តសិនទេនោះ»។ 52ពួកគេតបទៅលោកវិញថា៖ «តើលោកជាពួកកាលីឡេដែរឬ?
សុំលោកពិចារណាមើល៍ពុំដែលមានព្យាការីណាម្នាក់កើតពីស្រុកកាលីឡេឡើយ»។ [ 53បន្ទាប់មក ម្នាក់ៗក៏វិលត្រឡប់ទៅផ្ទះរៀងៗខ្លួនវិញ។

# JOHN - យ៉ូហាន 8

1ព្រះយេស៊ូយាងទៅភ្នំដើមអូលីវ 2លុះព្រលឹមឡើង ព្រះអង្គវិលត្រឡប់ទៅព្រះវិហារជាថ្មីម្តងទៀត ប្រជាជនទាំងមូលនាំគ្នាមកគាល់ព្រះអង្គ
ព្រះអង្គក៏គង់បង្រៀនពួកគេ។ 3ពេលនោះ ពួកអាចារ្យ និង ពួកខាងគណៈផារីស៊ីនាំស្ត្រីម្នាក់ ដែលគេទាន់កំពុងតែរួមសហាយស្មន់។
គេយកនាងនោះមកដាក់កណ្តាលចំណោមប្រជុំជន 4ហើយទូលព្រះយេស៊ូថា៖ «លោកគ្រូ យើងចាប់ស្ត្រីនេះបាន
ក្នុងពេលកំពុងរួមសហាយស្មន់។ 5ក្នុងក្រឹត្យវិន័យ លោកម៉ូសេបានបង្គាប់អោយយើងយកដុំថ្ម គប់ស្ត្រីប្រភេទនេះសម្លាប់ចោល។ ចុះលោកគ្រូវិញ
តើលោកគ្រូគិតយ៉ាងណា?»។ 6ពួកគេទូលដូច្នេះ ដោយមានបំណងរកលេសចោទប្រកាន់ព្រះអង្គ។ ប៉ុន្តែ
ព្រះយេស៊ូឱនព្រះកាយចុះហើយយកព្រះអង្គុលីគូសវាសលើដី។ 7ដោយពួកគេចេះតែសួរព្រះអង្គខ្លាំងពេក ព្រះអង្គងើបព្រះភ័ក្ត្រឡើង
មានព្រះបន្ទូលទៅគេថា៖ «ក្នុងចំណោមអ្នករាល់គ្នា សុំអោយអ្នកដែលគ្មានបាបសោះយកដុំថ្មគប់នាងមុនគេទៅ!»។ 8បន្ទាប់មក
ព្រះអង្គឈ្ងោកព្រះភ័ក្ត្រចុះហើយគូសវាសលើដីសាជាថ្មី។ 9ពួកគេបានឮព្រះបន្ទូលរបស់ព្រះអង្គដូច្នេះ
ក៏នាំគ្នាដកខ្លួនថយម្នាក់ម្តងៗចាប់ផ្តើមពីអ្នកមានវ័យចាស់ជាងគេទៅ នៅសល់តែព្រះយេស៊ូ និង ស្ត្រីនោះប៉ុណ្ណោះ។ 10ពេលនោះ
ព្រះយេស៊ូងើបព្រះភ័ក្ត្រឡើង មានព្រះបន្ទូលទៅនាងថា៖«នាងអើយ ពួកគេទៅណាអស់ហើយ
គ្មាននរណាដាក់ទោសនាងទេឬ?»។ 11នាងទូលព្រះអង្គថា៖ «គ្មានទេលោកម្ចាស់!»។
ព្រះយេស៊ូមានព្រះបន្ទូលទៅនាងថា៖«ខ្ញុំក៏មិនដាក់ទោសនាងដែរ សុំអញ្ជើញទៅចុះ តែពីពេលនេះតទៅ កុំប្រព្រឹត្តអំពើបាបទៀតឡើយ»។
] 12ព្រះយេស៊ូមានព្រះបន្ទូលទៅកាន់បណ្តាជនសាជាថ្មីថា៖ «ខ្ញុំជាពន្លឺបំភ្លឺពិភពលោក អ្នកណាមកតាមខ្ញុំអ្នកនោះនឹងមិនដើរក្នុងសេចក្តីងងឹតឡើយ
គឺគេមានពន្លឺនាំគេទៅកាន់ជីវិត»។13ពួកខាងគណៈផារីស៊ីទូលព្រះអង្គថា៖ «លោកធ្វើជាបន្ទាល់អោយខ្លួនលោកផ្ទាល់

សក្ខីភាពរបស់លោកមិនពិតទេ»។ 14ព្រះយេស៊ូមានព្រះបន្ទូលតបទៅគេថា៖ «ទោះបីខ្ញុំធ្វើជាបន្ទាល់អោយខ្លួនខ្ញុំផ្ទាល់ក៏ដោយ
ក៏សក្ខីភាពរបស់ខ្ញុំនៅតែពិតដែរ ដ្បិតខ្ញុំដឹងថាខ្ញុំមកពីណា ហើយទៅណាផង។ រីឯអ្នករាល់គ្នាវិញ អ្នករាល់គ្នាពុំដឹងថា
ខ្ញុំមកពីណាហើយទៅណាឡើយ។15អ្នករាល់គ្នាវិនិច្ឆ័យតាមរបៀបលោកីយ៍។ រីឯខ្ញុំវិញ ខ្ញុំមិនវិនិច្ឆ័យទោសនរណាទេ 16ប្រសិនបើខ្ញុំវិនិច្ឆ័យទោស
ការវិនិច្ឆ័យរបស់ខ្ញុំក៏ស្របតាមសេចក្ដីពិតដែរ ព្រោះខ្ញុំមិនវិនិច្ឆ័យតែម្នាក់ខ្ញុំឡើយ
គឺមានព្រះបិតាដែលបានចាត់ខ្ញុំអោយមកវិនិច្ឆ័យជាមួយខ្ញុំ។ 17ក្នុងវិន័យរបស់អ្នករាល់គ្នាមានចែងទុកមកថា បើមានពីរនាក់ធ្វើជាបន្ទាល់
ទើបសក្ខីភាពយកជាការបាន។18ខ្ញុំនេះហើយជាបន្ទាល់សំរាប់ខ្លួនខ្ញុំផ្ទាល់
ហើយព្រះបិតាដែលបានចាត់ខ្ញុំអោយមកក៏ធ្វើជាបន្ទាល់អោយខ្ញុំដែរ»។ 19ពួកគេទូលសួរព្រះអង្គថា៖ «តើព្រះបិតារបស់លោកនៅឯណា?»។
ព្រះយេស៊ូមានព្រះបន្ទូលតបទៅគេថា៖ «អ្នករាល់គ្នាមិនស្គាល់ខ្ញុំ ហើយក៏មិនស្គាល់ព្រះបិតារបស់ខ្ញុំដែរ។ បើអ្នករាល់គ្នាស្គាល់ខ្ញុំ
អ្នករាល់គ្នាមុខជាស្គាល់ព្រះបិតារបស់ខ្ញុំមិនខាន»។20ព្រះយេស៊ូមានព្រះបន្ទូលទាំងនេះ កាលព្រះអង្គបង្រៀនបណ្ដាជនក្នុងព្រះវិហារ
ត្រង់កន្លែងដាក់ហិបប្រាក់តង្វាយ ប៉ុន្តែ គ្មាននរណាចាប់ព្រះអង្គទេ
ព្រោះពេលកំណត់របស់ព្រះអង្គមិនទាន់មកដល់នៅឡើយ។ 21ព្រះយេស៊ូមានព្រះបន្ទូលទៅគេទៀតថា៖ «ខ្ញុំនឹងចាកចេញទៅ
ហើយអ្នករាល់គ្នានឹងតាមរកខ្ញុំតែអ្នករាល់គ្នានឹងត្រូវស្លាប់ ទាំងមានបាបជាប់ក្នុងខ្លួន។ ទីណាខ្ញុំទៅ ទីនោះ
អ្នករាល់គ្នាពុំអាចនឹងទៅបានឡើយ»។ 22ជនជាតិយូដានិយាយគ្នាថា៖ «តើលោកនឹងសម្លាប់ខ្លួនឬ បានជាលោកពោលថា"ទីណាខ្ញុំទៅ
ទីនោះអ្នករាល់គ្នាពុំអាចនឹងទៅបាន"ដូច្នេះ?»។ 23ព្រះអង្គមានព្រះបន្ទូលទៅគេថា៖ «អ្នករាល់គ្នាមានកំណើតនៅស្ថាននេះ រីឯខ្ញុំវិញ
ខ្ញុំមានកំណើតមកពីស្ថានលើ។ អ្នករាល់គ្នាមានកំណើតពីនិស្ស័យលោកីយ៍នេះ រីឯខ្ញុំវិញ

ខ្ញុំពុំមែនមានកំណើតពីនិស្ស័យលោកីយ៍នេះឡើយ។ 24ហេតុនេះហើយបានជាខ្ញុំប្រាប់អ្នករាល់គ្នាថា អ្នករាល់គ្នានឹងត្រូវស្លាប់ ទាំងមានបាបជាប់ក្នុងខ្លួន។
បើអ្នករាល់គ្នាមិនព្រមទទួលស្គាល់ឋានៈរបស់ខ្ញុំ ទេ អ្នករាល់គ្នានឹងត្រូវស្លាប់
ទាំងមានបាបជាប់ក្នុងខ្លួនជាមិនខាន»។ 25គេទូលសួរព្រះអង្គថា៖«តើលោកមានឋានៈអ្វី?» ព្រះយេស៊ូមានព្រះបន្ទូលទៅគេថា៖
«ខ្ញុំបានប្រាប់អ្នករាល់គ្នាតាំងពីដើមដំបូងមកម៉្លេះ។ 26ខ្ញុំមានសេចក្ដីជាច្រើនដែលត្រូវនិយាយអំពីអ្នករាល់គ្នា ព្រមទាំងវិនិច្ឆ័យទោសអ្នករាល់គ្នាផង។ ប៉ុន្តែ
ព្រះអង្គដែលបានចាត់ខ្ញុំអោយមក ទ្រង់សំដែងសេចក្ដីពិត ហើយអ្វីៗដែលខ្ញុំបានឮពីព្រះអង្គ
ខ្ញុំក៏យកមកថ្លែងប្រាប់មនុស្សលោកដែរ»។ 27អ្នកទាំងនោះមិនយល់ថា
ព្រះអង្គកំពុងតែមានព្រះបន្ទូលអំពីព្រះបិតាប្រាប់គេឡើយ។ 28ព្រះយេស៊ូមានព្រះបន្ទូលទៅគេទៀតថា៖ «កាលណាអ្នករាល់គ្នាលើកបុត្រមនុស្សឡើង
អ្នករាល់គ្នាមុខជានឹងស្គាល់ឋានៈរបស់ខ្ញុំ ពុំខាន ហើយអ្នករាល់គ្នានឹងដឹងថា ខ្ញុំមិនធ្វើការអ្វីមួយ ដោយសំអាងលើខ្លួនខ្ញុំផ្ទាល់ឡើយ
គឺខ្ញុំថ្លែងតែសេចក្ដីណាដែលព្រះបិតាមានព្រះបន្ទូលប្រាប់មកខ្ញុំប៉ុណ្ណោះ។ 29ព្រះអង្គដែលចាត់ខ្ញុំអោយមក
ទ្រង់គង់នៅជាមួយខ្ញុំព្រះអង្គមិនចោលខ្ញុំអោយនៅតែម្នាក់ឯងឡើយ ដ្បិតខ្ញុំតែងប្រព្រឹត្តកិច្ចការណា
ដែលគាប់ព្រះហឫទ័យព្រះអង្គជានិច្ច»។ 30ពេលព្រះយេស៊ូមានព្រះបន្ទូលដូច្នេះមានមនុស្សជាច្រើនជឿលើព្រះអង្គ។ 31ពេលនោះ
ព្រះយេស៊ូមានព្រះបន្ទូលទៅកាន់ជនជាតិយូដា ដែលបានជឿលើព្រះអង្គថា៖ «ប្រសិនបើអ្នករាល់គ្នាស្ថិតនៅជាប់នឹងពាក្យរបស់ខ្ញុំ
អ្នករាល់គ្នាពិតជាសិស្សរបស់ខ្ញុំមែន។ 32អ្នករាល់គ្នានឹងស្គាល់សេចក្ដីពិត
ហើយសេចក្ដីពិតនឹងរំដោះអ្នករាល់គ្នាអោយមានសេរីភាព»។ 33គេនាំគ្នាទូលព្រះអង្គថា៖ «យើងខ្ញុំជាកូនចៅលោកអប្រាហាំ!

យើងខ្ញុំមិនដែលធ្វើខ្ញុំបំរើអ្នកណាឡើយ ម្ដេចក៏លោកគ្រូថា "អ្នករាល់គ្នានឹងមានសេរីភាព"ដូច្នេះ?»។ 34ព្រះយេស៊ូមានព្រះបន្ទូលថា៖
«ខ្ញុំសុំប្រាប់អោយអ្នករាល់គ្នាដឹងច្បាស់ថាអ្នកណាប្រព្រឹត្តអំពើបាប អ្នកនោះជាខ្ញុំបំរើរបស់អំពើបាប។ 35ធម្មតា
ខ្ញុំបំរើមិនដែលស្ថិតនៅក្នុងផ្ទះរបស់ម្ចាស់ជាប់រហូតទេ
មានតែកូនរបស់ម្ចាស់ប៉ុណ្ណោះដែលស្ថិតនៅក្នុងផ្ទះជាប់រហូតតទៅ។ 36ប្រសិនបើព្រះបុត្រារំដោះអ្នករាល់គ្នា
អ្នករាល់គ្នាពិតជាមានសេរីភាព។ 37ខ្ញុំដឹងហើយថា អ្នករាល់គ្នាជាកូនចៅរបស់លោកអប្រាហាំ ក៏ប៉ុន្តែ អ្នករាល់គ្នារកសម្លាប់ខ្ញុំ
ព្រោះពាក្យរបស់ខ្ញុំមិនស្ថិតនៅក្នុងចិត្តអ្នករាល់គ្នាឡើយ។ 38ខ្ញុំនិយាយតែអំពីអ្វីៗដែលខ្ញុំបានឃើញនៅក្បែរព្រះបិតា រីឯអ្នករាល់គ្នាវិញ
អ្នករាល់គ្នាធ្វើតាមសេចក្ដីណាដែលអ្នករាល់គ្នាបានឮពីឪពុករបស់អ្នករាល់គ្នា»។ 39គេទូលព្រះអង្គថា៖ «ឪពុករបស់យើង គឺលោកអប្រាហាំ»។
ព្រះយេស៊ូមានព្រះបន្ទូលតបវិញថា៖«បើអ្នករាល់គ្នាពិតជាកូនចៅលោកអប្រាហាំមែន អ្នករាល់គ្នាមុខជាធ្វើកិច្ចការ
ដូចលោកអប្រាហាំធ្លាប់ធ្វើនោះមិនខាន 40តែឥឡូវនេះ អ្នករាល់គ្នារកសម្លាប់ខ្ញុំមកពីខ្ញុំនិយាយសេចក្ដីពិត
ដែលខ្ញុំបានឮពីព្រះជាម្ចាស់លោកអប្រាហាំមិនបានប្រព្រឹត្តដូច្នេះទេ។ 41អ្នករាល់គ្នាធ្វើកិច្ចការដែលឪពុកអ្នករាល់គ្នាប្រព្រឹត្ត»។ គេទូលព្រះអង្គថា៖
«យើងខ្ញុំជាកូនពេញច្បាប់ យើងមានឪពុកតែមួយគត់ គឺព្រះជាម្ចាស់»។ 42ព្រះយេស៊ូមានព្រះបន្ទូលទៅគេថា៖
«ប្រសិនបើព្រះជាម្ចាស់ពិតជាឪពុកអ្នករាល់គ្នាមែនម្ល៉េះសមអ្នករាល់គ្នាស្រឡាញ់ខ្ញុំពុំខានដ្បិតខ្ញុំចេញពីព្រះជាម្ចាស់មកទីនេះ។
ខ្ញុំមិនមែនមកដោយចិត្តឯងឡើយ គឺព្រះជាម្ចាស់បានចាត់ខ្ញុំអោយមក។ 43ហេតុអ្វីបានជាអ្នករាល់គ្នាមិនយល់ពាក្យដែលខ្ញុំថ្លែងប្រាប់ដូច្នេះ?
គឺមកពីអ្នករាល់គ្នាមិនអាចស្ដាប់ពាក្យរបស់ខ្ញុំបាន។ 44អ្នករាល់គ្នាជាកូនចៅរបស់មារសាតាំង ហើយអ្នករាល់គ្នាចង់ធ្វើតាមចំណង់ចិត្តឪពុកអ្នករាល់គ្នា។

តាំងពីដើមរៀងមកវាបានសម្លាប់មនុស្សហើយមិនកាន់តាមសេចក្តីពិតទេ ព្រោះគ្មានសេចក្តីពិតនៅក្នុងខ្លួនវាសោះ។ ពេលវានិយាយកុហក
នោះវានិយាយចេញពីគំនិតវាផ្ទាល់ ព្រោះវាជាមេកុហកហើយជាឪពុកនៃអ្នកកុហក។ 45រីឯខ្ញុំវិញ
ខ្ញុំនិយាយសេចក្តីពិតតែអ្នករាល់គ្នាមិនជឿខ្ញុំទេ។ 46ក្នុងចំណោមអ្នករាល់គ្នាតើនរណាអាចចោទប្រកាន់ថាខ្ញុំប្រព្រឹត្តអំពើបាបបាន? បើខ្ញុំនិយាយសេចក្តីពិត
ហេតុដូចម្តេចបានជាអ្នករាល់គ្នាមិនជឿខ្ញុំ? 47អ្នកណាកើតមកពីព្រះជាម្ចាស់ អ្នកនោះតែងស្តាប់ព្រះបន្ទូលរបស់ព្រះអង្គ។ រីឯអ្នករាល់គ្នាវិញ
អ្នករាល់គ្នាមិនមែនកើតមកពីព្រះជាម្ចាស់ទេបានជាអ្នករាល់គ្នាមិនស្តាប់ខ្ញុំដូច្នេះ»។ 48ជនជាតិយូដាទូលព្រះអង្គថា៖
«យើងនិយាយថាលោកជាសាសន៍សាម៉ារី ហើយថាមានអារក្សចូលលោកនោះត្រូវមែន!»។49ព្រះយេស៊ូមានព្រះបន្ទូលតបថា៖
«គ្មានអារក្សណាចូលខ្ញុំឡើយ តែខ្ញុំគោរពព្រះបិតារបស់ខ្ញុំ ហើយអ្នករាល់គ្នាបែរជាបន្តុះបង្អាប់ខ្ញុំទៅវិញ។ 50ខ្ញុំមិនរកសិរីរុងរឿងសំរាប់ខ្លួនខ្ញុំឡើយ
គឺមានម្នាក់រកអោយខ្ញុំហើយវិនិច្ឆ័យទៀតផង។ 51ខ្ញុំសុំប្រាប់អោយអ្នករាល់គ្នាដឹងច្បាស់ថា អ្នកណាកាន់តាមពាក្យរបស់ខ្ញុំ
អ្នកនោះនឹងមិនស្លាប់សោះឡើយ»។ 52ជនជាតិយូដាទូលព្រះអង្គថា៖ «ឥឡូវនេះ យើងដឹងច្បាស់ហើយថាលោកពិតជាមានអារក្សចូលមែន។
លោកអប្រាហាំ និង ពួកព្យាការីបានទទួលមរណភាពទៅហើយ រីឯលោកវិញ លោកហ៊ានពោលថា អ្នកណាកាន់តាមពាក្យលោក
អ្នកនោះមិនស្លាប់សោះឡើយ។ 53តើលោកមានឋានៈធំជាងលោកអប្រាហាំជាបុព្វបុរសរបស់យើង ដែលទទួលមរណភាពទៅហើយនោះឬ?
រីឯពួកព្យាការី ក៏ទទួលមរណភាពទៅដែរ។ ចុះលោកលោកតាំងខ្លួនជាអ្វី?»។ 54ព្រះយេស៊ូមានព្រះបន្ទូលថា៖ «បើខ្ញុំលើកតម្កើងខ្លួនខ្ញុំ
សិរីរុងរឿងរបស់ខ្ញុំគ្មានតម្លៃអ្វីទាល់តែសោះ គឺព្រះបិតារបស់ខ្ញុំទេតើដែលលើកតម្កើងខ្ញុំ ព្រះអង្គនោះហើយដែលអ្នករាល់គ្នាថាជា
"ព្រះរបស់យើង"។ 55អ្នករាល់គ្នាមិនស្គាល់ព្រះអង្គទេរីឯខ្ញុំ ខ្ញុំស្គាល់ព្រះអង្គប្រសិនបើខ្ញុំថា ខ្ញុំមិនស្គាល់ព្រះអង្គទេ

ខ្ញុំមុខជានិយាយកុហកដូចអ្នករាល់គ្នាដែរ។ ប៉ុន្តែ ខ្ញុំស្គាល់ព្រះអង្គ
ហើយកាន់តាមព្រះបន្ទូលរបស់ព្រះអង្គថែមទៀតផង។ 56លោកអប្រាហាំជាឪពុករបស់អ្នករាល់គ្នាមានចិត្តត្រេកអរពន់ប្រមាណ
ដោយសង្ឃឹមថានឹងឃើញខ្ញុំមកដល់។ លោកក៏បានឃើញមែនហើយត្រេកអរសប្បាយ»។ 57ជនជាតិយូដាពោលថា៖
«លោកមានអាយុមិនទាន់ទាំងបានហាសិបឆ្នាំផង ម្ដេចក៏ថាបានឃើញលោកអប្រាហាំដូច្នេះ?»។ 58ព្រះយេស៊ូមានព្រះបន្ទូលថា៖
«ខ្ញុំសុំប្រាប់អោយអ្នករាល់គ្នាដឹងច្បាស់ថា មុនលោកអប្រាហាំកើតមក ខ្ញុំមានជីវិត រួចស្រេចទៅហើយ»។ 59ពួកគេក៏រើសដុំថ្មបំរុងនឹងគប់សម្លាប់ព្រះអង្គ
ប៉ុន្តែ ព្រះយេស៊ូគេចៀសព្រះអង្គចេញពីព្រះវិហារបាត់ទៅ។

# JOHN - យ៉ូហាន 9

1ព្រះយេស៊ូយាងតាមផ្លូវ ទ្រង់ទតឃើញមនុស្សម្នាក់ខ្វាក់តាំងពីកំណើត។2ពួកសិស្សទូលសួរព្រះអង្គថា៖ «ព្រះគ្រូ បុរសនេះកើតមកខ្វាក់ដូច្នេះ
តើបណ្ដាលមកពីបាបរបស់នរណា? បាបរបស់គាត់ផ្ទាល់ ឬបាបរបស់ឪពុកម្ដាយគាត់?»។ 3ព្រះយេស៊ូមានព្រះបន្ទូលតបថា៖ «គាត់ខ្វាក់
មិនមែនមកពីបាបរបស់ឪពុកម្ដាយគាត់ ឬ បាបរបស់គាត់ទេ គាត់ខ្វាក់ដូច្នេះ
ដើម្បីអោយព្រះជាម្ចាស់បង្ហាញកិច្ចការរបស់ព្រះអង្គនៅក្នុងគាត់។ 4យើងត្រូវធ្វើកិច្ចការរបស់ព្រះអង្គដែលបានចាត់ខ្ញុំអោយមក ទាន់នៅភ្លឺនៅឡើយ
ដ្បិតដល់ពេលយប់
គ្មាននរណាអាចធ្វើការបានឡើយ។ 5ពេលខ្ញុំស្ថិតនៅក្នុងពិភពលោកនេះខ្ញុំជាពន្លឺបំភ្លឺពិភពលោក»។ 6កាលព្រះអង្គមានព្រះបន្ទូលដូច្នេះហើយ

ព្រះអង្គស្ដោះទឹកព្រះឱស្ឋទៅលើដី ធ្វើភក់លាបភ្នែកមនុស្សខ្វាក់នោះ 7រួចទ្រង់មានព្រះបន្ទូលទៅគាត់ថា៖ «សុំអញ្ជើញទៅលុបមុខនៅស្រះស៊ីឡោម
ចុះ»(ពាក្យ"ស៊ីឡោម" នេះមានន័យថា អ្នកដែលគេចាត់អោយទៅ)។ គាត់ក៏ចេញទៅលុបមុខ ពេលត្រឡប់មកវិញ គាត់មើលឃើញ។8អ្នកជិតខាង
និង អស់អ្នកដែលធ្លាប់ឃើញគាត់សុំទានកាលពីមុន នាំគ្នាពោលថា៖ «បុរសនេះជាអ្នកដែលតែងអង្គុយសុំទានទេតើ!»។ 9អ្នកខ្លះពោលថា៖
«គាត់មែន!»។ ខ្លះទៀតថា៖ «មិនមែនទេ អ្នកនេះមានមុខដូចគាត់!»។ រីឯបុរសនោះវិញ
គាត់ពោលថា៖«គឺខ្ញុំហ្នឹងហើយ!»។ 10គេក៏នាំគ្នាសួរគាត់ថា៖ «ម្ដេចបានជាភ្នែកអ្នកភ្លឺដូច្នេះ?»។ 11គាត់ឆ្លើយថា៖
«មានលោកម្នាក់ឈ្មោះយេស៊ូបានធ្វើភក់យកមកលាបភ្នែកខ្ញុំ ហើយប្រាប់ខ្ញុំថា "សុំអញ្ជើញទៅលុបមុខនៅស្រះស៊ីឡោមចុះ!"ខ្ញុំក៏ទៅលុបមុខ
ហើយខ្ញុំមើលឃើញ»។ 12គេសួរគាត់ថា៖ «លោកនោះនៅឯណា?»។ គាត់ឆ្លើយថា៖ «ខ្ញុំមិនដឹងទេ!»។ 13គេនាំអ្នកដែលខ្វាក់ពីមុននោះ
ទៅជួបពួកខាងគណៈផារីស៊ី។ 14ថ្ងៃដែលព្រះយេស៊ូធ្វើភក់ និង
ប្រោសអ្នកខ្វាក់អោយបានភ្លឺនោះជាថ្ងៃសប្ប័ទ 15ហេតុនេះហើយបានជាពួកខាងគណៈផារីស៊ីនាំគ្នាសួរម្ដងទៀតអំពីហេតុការណ៍ដែលធ្វើអោយភ្នែកគាត់ភ្លឺ
។ គាត់ឆ្លើយថា៖ «លោកបានយកភក់ដាក់ពីលើភ្នែកខ្ញុំ ខ្ញុំទៅលុបមុខ ហើយក៏មើលឃើញ»។ 16ពួកខាងគណៈផារីស៊ីខ្លះពោលថា៖
«អ្នកនោះមិនមែនមកពីព្រះជាម្ចាស់ទេ ដ្បិតគាត់ពុំគោរពក្រឹត្យវិន័យសំរាប់ថ្ងៃឈប់សំរាក»។
ខ្លះទៀតពោលថា៖«តើមនុស្សបាបអាចធ្វើទីសំគាល់ដូចម្ដេចបាន?»ពួកគេក៏បាក់បែកគ្នា។ 17គេសួរអ្នកដែលខ្វាក់ពីមុននោះម្ដងទៀតថា៖ «ចុះអ្នកវិញ
តើអ្នកថាលោកដែលធ្វើអោយអ្នកបានភ្លឺនោះជានរណា?»។ គាត់ឆ្លើយថា៖«លោកពិតជាព្យាការីមែន!»។ 18ប៉ុន្តែ ជនជាតិយូដានៅតែមិនជឿថា
កាលពីមុនបុរសនេះខ្វាក់ ហើយឥឡូវបានមើលឃើញនោះឡើយទាល់តែហៅឪពុកម្ដាយគាត់មកសួរសិន។ 19គេសួរទៅឪពុកម្ដាយគាត់ថា៖

«អ្នកនេះពិតជាកូនរបស់អ្នកដែលអ្នកថាខ្វាក់ពីកំណើតមែនឬ
ចុះឥឡូវម្ដេចក៏ភ្នែកគាត់ភ្លឺ?»។20ឪពុកម្ដាយគាត់ឆ្លើយថា៖«យើងខ្ញុំដឹងថាវាពិតជាកូនរបស់យើងខ្ញុំមែន
ហើយកើតមកខ្វាក់!។ 21ត្រង់ឯភ្នែកវាបានភ្លឺដោយហេតុយ៉ាងណាៗនោះ យើងខ្ញុំមិនដឹងទេ ហើយនរណាបានធ្វើអោយភ្នែកវាភ្លឺនោះ
ក៏យើងមិនដឹងដែរ!។ សូមអស់លោកសួរវាទៅ វាធំហើយ វាឆ្លើយខ្លួនឯងបាន»។ 22ឪពុកម្ដាយគាត់និយាយដូច្នេះមកពីខ្លាចជនជាតិយូដា
ព្រោះជនជាតិយូដារួមគំនិតគ្នា បណ្ដេញអស់អ្នកដែលទទួលស្គាល់ថាព្រះយេស៊ូជាព្រះគ្រិស្ដ
ចេញពីសាលាប្រជុំរបស់គេ។ 23ហេតុនេះហើយបានជាគាត់ពោលថា "វាធំហើយសូមសួរវាទៅ!"។ 24ពួកខាងគណៈផារីស៊ីបានហៅបុរស
ដែលខ្វាក់ពីមុននោះ មកសួរជាលើកទីពីរ។
គេពោលទៅគាត់ថា៖«ត្រូវនិយាយការពិតនៅចំពោះព្រះភ័ក្ត្រព្រះជាម្ចាស់!យើងដឹងថាអ្នកនោះពិតជាមនុស្សបាបមែន!»។25បុរសនោះតបថា៖«លោក
នោះ ជាមនុស្សបាប ឬយ៉ាងណានោះ ខ្ញុំមិនដឹងទេ ខ្ញុំដឹងតែម្យ៉ាង គឺពីមុនខ្ញុំខ្វាក់ ឥឡូវនេះខ្ញុំមើលឃើញ»។ 26ពួកគេសួរគាត់ថា៖
«តើអ្នកនោះបានធ្វើអ្វីដល់អ្នក? គាត់បានធ្វើអោយភ្នែកអ្នកភ្លឺ ដោយវិធីណា?»។ 27គាត់ឆ្លើយទៅគេវិញថា៖
«ខ្ញុំបានជំរាបអស់លោករួចមកហើយតែអស់លោកពុំស្ដាប់ខ្ញុំទេ។ ហេតុដូចម្ដេចបានជាអស់លោកចង់អោយខ្ញុំនិយាយម្ដងទៀតដូច្នេះ?
ប្រហែលអស់លោកចង់ធ្វើជាសិស្សរបស់លោកនោះដែរហើយមើលទៅ!»។ 28ពួកខាងគណៈផារីស៊ីក៏ជេរប្រមាថគាត់ថា៖
«ឯងទេតើជាសិស្សរបស់គាត់! រីឯយើងវិញយើងជាសិស្សរបស់លោកម៉ូសេ!។ 29យើងដឹងថាព្រះជាម្ចាស់មានព្រះបន្ទូលមកកាន់លោកម៉ូសេមែន។
រីឯអ្នកនោះវិញ យើងមិនដឹងថាគាត់មកពីណាទេ!»។30បុរសនោះនិយាយតបទៅគេថា៖ «លោកនោះបានធ្វើអោយភ្នែកខ្ញុំភ្លឺ តែអស់លោកមិនដឹងថា

គាត់មកពីណាដូច្នេះ គួរអោយឆ្ងល់ណាស់។ 31យើងដឹងស្រាប់ហើយថាព្រះជាម្ចាស់មិនស្ដាប់ពាក្យរបស់មនុស្សបាបទេ
ព្រះអង្គស្ដាប់តែពាក្យរបស់អ្នកគោរពប្រណិប័តន៍ព្រះអង្គ និង ប្រព្រឹត្តតាមព្រះហឫទ័យព្រះអង្គប៉ុណ្ណោះ។ 32តាំងពីដើមរៀងមក
យើងមិនដែលឮថាមាននរណាធ្វើអោយភ្នែកមនុស្សខ្វាក់ពីកំណើតបានភ្លឺនោះឡើយ។33ប្រសិនបើលោកនោះមិនមកពីព្រះជាម្ចាស់ទេ
លោកមិនអាចធ្វើការអ្វីបានទាល់តែសោះ»។ 34ពួកគេនាំគ្នាពោលទៅគាត់ថា៖ «ឯងជាមនុស្សជាប់បាបពេញខ្លួនតាំងពីកំណើតមក
ហើយឯងហ៊ានប្រដៅយើងទៀត!»។ គេក៏បណ្ដេញគាត់ចេញទៅខាងក្រៅ។ 35ព្រះយេស៊ូជ្រាបថា គេបានបណ្ដេញគាត់ កាលព្រះអង្គជួបគាត់
ទ្រង់មានព្រះបន្ទូលសួរថា៖ «តើអ្នកជឿលើបុត្រមនុស្សឬទេ?»។ 36គាត់ទូលព្រះអង្គថា៖ «លោកម្ចាស់អើយ តើនរណាជាបុត្រមនុស្ស
សូមប្រាប់ខ្ញុំអោយដឹងផង ដើម្បីអោយខ្ញុំជឿលើព្រះអង្គ»។ 37ព្រះយេស៊ូមានព្រះបន្ទូលទៅគាត់ថា៖ «អ្នកឃើញលោកស្រាប់
គឺអ្នកដែលកំពុងតែនិយាយជាមួយអ្នកហ្នឹងហើយជាបុត្រមនុស្ស»។38គាត់ទូលព្រះយេស៊ូថា៖ «បពិត្រព្រះអម្ចាស់! ទូលបង្គំជឿលើព្រះអង្គហើយ»។
គាត់ក៏ក្រាបថ្វាយបង្គំព្រះអង្គ។ 39បន្ទាប់មក ព្រះយេស៊ូមានព្រះបន្ទូលថា៖ «ខ្ញុំមកក្នុងពិភពលោកនេះ ដើម្បីវិនិច្ឆ័យចិត្តមនុស្ស
គឺអោយមនុស្សខ្វាក់មើលឃើញ ហើយអោយមនុស្សមើលឃើញ ត្រឡប់ទៅជាខ្វាក់វិញ»។ 40ពួកខាងគណៈផារីស៊ីខ្លះដែលនៅទីនោះ ជាមួយព្រះអង្គ
បានឮដូច្នេះក៏ទូលព្រះអង្គថា៖ «ប្រហែលជាលោកចង់ថា យើងខ្ញុំនេះ
ជាមនុស្សខ្វាក់ដែរហើយមើលទៅ!»។ 41ព្រះយេស៊ូមានព្រះបន្ទូលឆ្លើយទៅគេវិញថា៖ «ប្រសិនបើអ្នករាល់គ្នាខ្វាក់មែន អ្នករាល់គ្នាគ្មានបាបទេ។
ផ្ទុយទៅវិញ មកពីអ្នករាល់គ្នាថាខ្លួនមើលឃើញដូច្នេះហើយ បានជាអ្នករាល់គ្នានៅតែជាប់បាបរហូត»។

# JOHN - យ៉ូហាន 10

1«ខ្ញុំសុំប្រាប់អោយអ្នករាល់គ្នាដឹងច្បាស់ថា អ្នកណាមិនចូលក្នុងក្រោលចៀមតាមទ្វារ តែផ្លោះចូលតាមកន្លែងផ្សេង
អ្នកនោះជាចោរលួចចោរប្លន់។ 2រីឯអ្នកដែលចូលតាមទ្វារ
ពិតជាអ្នកគង្វាលរបស់ចៀម។ 3ឆ្មាំទ្វារបើកទ្វារអោយគាត់ចូលហើយចៀមទាំងប៉ុន្មានស្ដាប់សំឡេងគាត់។ គាត់ហៅចៀមផ្ទាល់របស់គាត់តាម
ឈ្មោះរបស់វារៀងៗខ្លួន រួចនាំចេញទៅខាងក្រៅ។ 4លុះគាត់បញ្ចេញចៀមចេញពីក្រោលអស់ហើយ គាត់ដើរនាំមុខវា ហើយវាដើរតាមក្រោយគាត់
ពីព្រោះវាស្គាល់សំឡេងរបស់គាត់។5ចៀមទាំងនោះមិនដើរតាមអ្នកដទៃជាដាច់ខាត ផ្ទុយទៅវិញ វារត់គេចចេញឆ្ងាយពីគេ
ព្រោះវាមិនស្គាល់សំឡេងរបស់អ្នកដទៃឡើយ»។6ព្រះយេស៊ូមាន ព្រះបន្ទូលជាប្រស្នានេះអោយគេស្ដាប់ ប៉ុន្ដែ
គេពុំបានយល់ថាព្រះអង្គមានព្រះបន្ទូលអំពីរឿងអ្វីឡើយ។ 7ព្រះយេស៊ូមានព្រះបន្ទូលទៅគេទៀតថា៖ «ខ្ញុំសុំប្រាប់អោយអ្នករាល់គ្នាដឹងច្បាស់ថា
ខ្ញុំហ្នឹងហើយជាទ្វារ សំរាប់អោយចៀមចេញចូល។ 8អ្នកដែលមកមុនខ្ញុំទាំងប៉ុន្មាន
សុទ្ធតែជាចោរលួចចោរប្លន់ទាំងអស់ចៀមមិនបានស្ដាប់សំឡេងអ្នកទាំងនោះឡើយ។ 9ខ្ញុំហ្នឹងហើយជាទ្វារ អ្នកណាចូលតាមខ្ញុំ
ព្រះជាម្ចាស់នឹងសង្គ្រោះអ្នកនោះ អ្នកនោះនឹងចេញចូល ព្រមទាំងរកឃើញចំណីអាហារ ថែមទៀតផង។ 10ចោរវាមកគិតតែពីលួចប្លន់ គិតតែពីសម្លាប់
និង បំផ្លាញប៉ុណ្ណោះ។ រីឯខ្ញុំវិញ ខ្ញុំមកដើម្បីអោយមនុស្សលោក មានជីវិតហើយអោយគេមានជីវិតពេញបរិបូណ៌»។ 11ខ្ញុំហ្នឹងហើយជាអ្នកគង្វាលដ៏ល្អ
អ្នកគង្វាលដ៏ល្អតែងតែស៊ូប្ដូរជីវិត ដើម្បីចៀមរបស់ខ្លួន។ 12រីឯអ្នកស៊ីឈ្នួលវិញកាលគេឃើញចចកមកដល់
គេរត់ចោលចៀមទុកអោយចចកខាំអូសយកទៅ ហើយដេញកំចាត់កំចាយជាមិនខាន ពីព្រោះអ្នកនោះមិនមែនជាអ្នកគង្វាល ហើយក៏មិនមែនជាម្ចាស់

របស់ចៀមផង។ 13អ្នកនោះមិនខ្វល់ខ្វាយនឹងចៀមឡើយ ព្រោះគេគ្រាន់តែស៊ីឈ្នួលប៉ុណ្ណោះ។
ខ្ញុំហ្នឹងហើយជាអ្នកគង្វាលដ៏ល្អ។ 14ខ្ញុំស្គាល់ចៀមរបស់ខ្ញុំ ចៀមរបស់ខ្ញុំក៏ស្គាល់ខ្ញុំ 15គឺដូចព្រះបិតាស្គាល់ខ្ញុំ ហើយខ្ញុំស្គាល់ព្រះបិតាដូច្នោះដែរ។
ខ្ញុំស៊ូប្តូរជីវិត ដើម្បីចៀមរបស់ខ្ញុំ។ 16ខ្ញុំមានចៀមឯទៀតៗ ដែលមិននៅក្នុងក្រោលនេះទេ។ ខ្ញុំត្រូវតែនាំចៀមទាំងនោះមកដែរ។
ចៀមទាំងនោះនឹងស្តាប់សំឡេងខ្ញុំ ហើយនៅពេលនោះនឹងមានហ្វូងចៀមតែមួយមានអ្នកគង្វាលតែមួយ។17ព្រះបិតាស្រឡាញ់ខ្ញុំ
ព្រោះខ្ញុំសុខចិត្តស៊ូប្តូរជីវិតដើម្បីអោយបានជីវិតនោះមកវិញ។ 18គ្មាននរណាដកហូតជីវិតរបស់ខ្ញុំបានឡើយ គឺខ្ញុំស៊ូប្តូរជីវិត ដោយខ្លួនខ្ញុំផ្ទាល់តែម្តង។
ខ្ញុំមានអំណាចនឹងស៊ូប្តូរជីវិតរបស់ខ្ញុំ ហើយខ្ញុំក៏មានអំណាចនឹងយកជីវិតនោះមកវិញ
តាមបទបញ្ជាដែលខ្ញុំបានទទួលពីព្រះបិតាមក»។ 19ព្រះបន្ទូលទាំងនេះធ្វើអោយជនជាតិយូដាបាក់បែកគ្នាម្តងទៀត។ 20មានគ្នាគេជាច្រើនពោលថា៖
«អ្នកនោះមានអារក្សចូល! គាត់វង្វេងស្មារតីហើយ! ស្តាប់គាត់ធ្វើអ្វី?»។ 21អ្នកខ្លះទៀតពោលថា៖
«ពាក្យទាំងនេះមិនមែនជាពាក្យរបស់មនុស្សដែលមានអារក្សចូលទេ! តើអារក្សអាចធ្វើអោយភ្នែកមនុស្សខ្វាក់ភ្លឺកើតឬ?»។ 22ពេលនោះជារដូវរងា
គេនាំគ្នាធ្វើបុណ្យរំលឹកពិធីឆ្លងព្រះវិហារ នៅក្រុងយេរូសាឡឹម។ 23ព្រះយេស៊ូយាងចុះឡើងក្នុងថែវព្រះវិហារដែលមានឈ្មោះថា
«ថែវព្រះបាទសាឡូម៉ូន»។ 24ជនជាតិយូដានាំគ្នាចោមរោមព្រះអង្គទូលសួរថា៖ «តើលោកទុកអោយយើងខ្ញុំនៅរារែកក្នុងចិត្តដល់ណាទៀត?
ប្រសិនបើលោកពិតជាព្រះគ្រិស្តមែន សូមប្រាប់យើងខ្ញុំអោយត្រង់ៗមក»។ 25ព្រះយេស៊ូមានព្រះបន្ទូលតបទៅគេថា៖
«ខ្ញុំបានប្រាប់អ្នករាល់គ្នារួចមកហើយ តែអ្នករាល់គ្នាមិនជឿទេ។ កិច្ចការទាំងប៉ុន្មានដែលខ្ញុំបានធ្វើក្នុងព្រះនាមព្រះបិតារបស់ខ្ញុំ
ជាសក្ខីភាពបញ្ជាក់អំពីខ្ញុំស្រាប់។ 26ប៉ុន្តែ អ្នករាល់គ្នាមិនជឿសោះ

ព្រោះអ្នករាល់គ្នាមិននៅក្នុងចំណោមចៀមរបស់ខ្ញុំ។ 27ចៀមរបស់ខ្ញុំតែងស្ដាប់សំឡេងខ្ញុំ ខ្ញុំស្គាល់ចៀមទាំងនោះ
ហើយចៀមទាំងនោះមកតាមខ្ញុំ។28ខ្ញុំអោយគេមានជីវិតអស់កល្បជានិច្ច
គេមិនវិនាសអន្តរាយឡើយហើយគ្មាននរណាអាចឆក់យកគេពីដៃខ្ញុំជាដាច់ខាត។ 29ព្រះបិតាដែលបានប្រទានចៀមទាំងនោះមកអោយខ្ញុំ
ទ្រង់មានអំណាចធំលើសអ្វីៗទាំងអស់គ្មាននរណាអាចឆក់យកគេពីព្រះហស្ដព្រះបិតាបានឡើយ។ 30ខ្ញុំ និង
ព្រះបិតាជាអង្គតែមួយ»។ 31ជនជាតិយូដានាំគ្នារើសដុំថ្មម្ដងទៀត បំរុងនឹងគប់សម្លាប់ព្រះអង្គ។ 32ព្រះយេស៊ូមានព្រះបន្ទូលទៅគេថា៖
«ខ្ញុំបានបង្ហាញអោយអ្នករាល់គ្នាឃើញកិច្ចការដ៏ល្អប្រសើរជាច្រើន ដែលព្រះបិតាប្រទានអោយខ្ញុំធ្វើ។ ក្នុងបណ្ដាកិច្ចការទាំងនោះ
តើកិច្ចការណាមួយដែលនាំអោយអ្នករាល់គ្នាយកដុំថ្មបំរុងនឹងគប់សម្លាប់ខ្ញុំ?»។ 33ជនជាតិយូដាតបទៅព្រះអង្គថា៖ «យើងចង់សម្លាប់លោក
មិនមែនមកពីលោកបានធ្វើកិច្ចការដ៏ល្អប្រសើរ ណាមួយនោះឡើយ គឺមកពីលោកបានពោលពាក្យប្រមាថព្រះជាម្ចាស់ ដ្បិតលោកជាមនុស្ស
ហើយតាំងខ្លួនជាព្រះជាម្ចាស់»។34ព្រះយេស៊ូមានព្រះបន្ទូលថា៖ «ក្នុងវិន័យរបស់អ្នករាល់គ្នាមានចែងថា ព្រះជាម្ចាស់មានព្រះបន្ទូលថា
អ្នករាល់គ្នាជាព្រះ។ 35យើងមិនអាចលុបបំបាត់គម្ពីរបានឡើយ បើគម្ពីរហៅអស់អ្នកដែលទទួលព្រះបន្ទូលថាជា "ព្រះ"
ដូច្នេះ 36ចុះហេតុដូចម្ដេចបានជាពេលខ្ញុំប្រាប់អ្នករាល់គ្នាថា ខ្ញុំជាបុត្រារបស់ព្រះជាម្ចាស់ អ្នករាល់គ្នាបែរជាពោលថាខ្ញុំប្រមាថព្រះអង្គទៅវិញ?
ព្រះបិតាបានប្រោសខ្ញុំអោយវិសុទ្ធ ហើយចាត់ខ្ញុំអោយមកក្នុងពិភពលោកនេះទៀតផង។ 37ប្រសិនបើខ្ញុំមិនធ្វើការរបស់ព្រះបិតាទេនោះ
សុំកុំជឿខ្ញុំឡើយ។ 38ប៉ុន្តែ បើខ្ញុំធ្វើកិច្ចការរបស់ព្រះអង្គ ទោះបីអ្នករាល់គ្នាមិនជឿខ្ញុំក៏ដោយ ក៏សុំជឿទៅលើកិច្ចការទាំងនោះចុះ ដើម្បីអោយបានដឹង
ហើយរឹតតែដឹងទៀតថាព្រះបិតាស្ថិតនៅក្នុងខ្ញុំ ខ្ញុំស្ថិតនៅក្នុងព្រះបិតា»។ 39គេរកចាប់ព្រះយេស៊ូម្ដងទៀត

ប៉ុន្តែព្រះអង្គគេចផុតពីគេទៅ។ 40ព្រះយេស៊ូយាងទៅត្រើយខាងនាយទន្លេយ័រដាន់ជាថ្មីម្ដងទៀត ត្រង់កន្លែងដែលលោកយ៉ូហានធ្លាប់ជ្រមុជ
ទឹកអោយបណ្ដាជនកាលពីមុន រួចព្រះអង្គគង់នៅទីនោះ។ 41មានមនុស្សជាច្រើននាំគ្នាមកគាល់ព្រះអង្គ គេពោលថា៖
«លោកយ៉ូហានពុំបានធ្វើទីសំគាល់ណាមួយឡើយ ប៉ុន្តែ ពាក្យទាំងប៉ុន្មានដែលគាត់និយាយអំពីលោកនេះ
សុទ្ធតែត្រូវទាំងអស់»។ 42មនុស្សជាច្រើននៅទីនោះបានជឿលើព្រះយេស៊ូ។

# JOHN - យ៉ូហាន 11

1នៅភូមិបេតថានី មានបុរសម្នាក់ឈ្មោះ ឡាសារគាត់មានជំងឺ។ នាងម៉ាថា និង នាងម៉ារីជាបងស្រីរបស់គាត់ ក៏រស់នៅក្នុងភូមិនោះដែរ។ 2នាងម៉ារីនេះ
ជាស្ត្រីម្នាក់ដែលបានចាក់ប្រេងក្រអូបលើព្រះបាទារបស់ព្រះអម្ចាស់ព្រមទាំងបានយកសក់របស់នាងមកជូតផង។ រីឯលោកឡាសារដែលឈឺនោះ
ត្រូវជាប្អូនបង្កើតរបស់នាង។ 3នាងទាំងពីរនាក់បានចាត់គេអោយទៅទូលព្រះយេស៊ូថា៖ «លោកម្ចាស់អ្នកដែលលោកស្រឡាញ់
កំពុងតែមានជំងឺ»។4កាលព្រះយេស៊ូជ្រាបដំណឹងនេះ ព្រះអង្គមានព្រះបន្ទូលថា៖ «ជំងឺនេះកើតឡើង មិនមែនអោយគាត់បាត់បង់ជីវិតទេ
គឺដើម្បីលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ ព្រមទាំងអោយព្រះបុត្រារបស់ព្រះអង្គសំដែងសិរីរុងរឿងវិញ»។ 5ព្រះយេស៊ូស្រឡាញ់នាងម៉ាថា
ប្អូនស្រីរបស់នាង និង លោកឡាសារណាស់។ 6កាលព្រះអង្គជ្រាបដំណឹងថា លោកឡាសារមានជំងឺ
ព្រះអង្គគង់នៅកន្លែងដដែលនោះពីរថ្ងៃទៀត 7បន្ទាប់មកព្រះអង្គមានព្រះបន្ទូលទៅពួកសិស្សថា៖
«យើងនាំគ្នាត្រឡប់ទៅស្រុកយូដាវិញ»។8ពួកសិស្សទូលព្រះអង្គថា៖ «ព្រះគ្រូ ជនជាតិយូដា ទើបនឹងចង់យកដុំថ្មគប់ធ្វើគុតព្រះអង្គថ្មីៗនេះសោះ

ហេតុដូចម្ដេចបានជាព្រះអង្គចង់វិលទៅស្រុកនោះវិញ!»។ 9ព្រះយេស៊ូមានព្រះបន្ទូលតបថា៖ «ក្នុងមួយថ្ងៃមានដប់ពីរម៉ោង អ្នកណាដើរនៅពេលថ្ងៃ
អ្នកនោះមិនជំពប់ជើងដួលឡើយ ព្រោះគេឃើញពន្លឺរបស់ពិភពលោកនេះ។ 10ផ្ទុយទៅវិញ អ្នកណាដើរនៅពេលយប់
អ្នកនោះមុខតែជំពប់ជើងដួលជាមិនខានព្រោះគេគ្មានពន្លឺនៅក្នុងខ្លួនទេ»។11ក្រោយមក ព្រះអង្គមានព្រះបន្ទូលទៅគេថែមទៀតថា៖
«ឡាសារជាមិត្តសំឡាញ់របស់យើងសំរានួលក់ទៅ ហើយ ខ្ញុំត្រូវតែទៅដាស់គាត់ អោយភ្ញាក់ឡើងវិញ»។ 12ពួកសិស្សទូលព្រះអង្គថា៖
«បពិត្រព្រះអម្ចាស់ ប្រសិនបើគាត់សំរានួលក់ដូច្នេះគាត់នឹងបានជាវិញមិនខាន»។ 13តាមពិតព្រះយេស៊ូចង់មានព្រះបន្ទូលថា
លោកឡាសារស្លាប់បាត់ទៅហើយ ប៉ុន្តែ ពួកសិស្សស្មានថាព្រះអង្គមានព្រះបន្ទូលថា
គាត់សំរានួលក់ធម្មតា។ 14ហេតុនេះហើយបានជាព្រះអង្គមានព្រះបន្ទូលបញ្ជាក់យ៉ាងច្បាស់ថា៖
«ឡាសារស្លាប់ទៅហើយ 15បើគិតពីប្រយោជន៍អ្នករាល់គ្នា ខ្ញុំសប្បាយចិត្ត ដោយខ្ញុំមិនបាននៅទីនោះ ដើម្បីអោយអ្នករាល់គ្នាបានជឿ។
ឥឡូវនេះយើងនាំគ្នាទៅផ្ទះគាត់»។ 16ពេលនោះ សិស្សថូម៉ាស់ ហៅឌីឌីម ពោលទៅសិស្សឯទៀតថា៖ «មក!
យើងនាំគ្នាទៅរួមស្លាប់ជាមួយព្រះអង្គដែរ!»។ 17កាលព្រះយេស៊ូយាងទៅដល់ ព្រះអង្គក៏ជ្រាបថាគេបានដាក់សពលោកឡាសារក្នុងផ្នូរ
បួនថ្ងៃហើយ។ 18ភូមិបេថានីមានចម្ងាយប្រមាណបីគីឡូម៉ែត្រពីក្រុងយេរូសាឡឹម។ 19មានជនជាតិយូដាជាច្រើននាំគ្នាមកជួយរំលែកទុក្ខនាងម៉ាថា និង
នាងម៉ារីក្នុងពេលប្អូនស្លាប់។ 20កាលនាងម៉ាថាបានដឹងថា ព្រះយេស៊ូយាងមកដល់ នាងក៏ចេញទៅទទួលព្រះអង្គ រីឯនាងម៉ារីវិញ
នាងអង្គុយនៅក្នុងផ្ទះ។ 21នាងម៉ាថាទូលព្រះយេស៊ូថា៖ «លោកម្ចាស់ ប្រសិនបើលោកបាននៅទីនេះប្អូននាងខ្ញុំមិនស្លាប់ទេ។ 22ប៉ុន្តែ ឥឡូវនេះ
នាងខ្ញុំដឹងថាបើលោកសុំអ្វីពីព្រះជាម្ចាស់ក៏ដោយ ព្រះអង្គមុខជានឹងប្រទានអោយមិនខាន»។ 23ព្រះយេស៊ូមានព្រះបន្ទូលទៅនាងថា៖

«ប្អូននាងនឹងរស់ឡើងវិញ»។ 24នាងទូលទៅព្រះអង្គវិញថា៖ «នាងខ្ញុំដឹងហើយ នៅថ្ងៃចុងក្រោយបំផុត កាលណាមនុស្សស្លាប់នឹងរស់ឡើងវិញ
ប្អូននាងខ្ញុំក៏នឹងរស់ឡើងវិញដែរ»។ 25ព្រះយេស៊ូមានព្រះបន្ទូលទៅនាងថា៖ «ខ្ញុំហ្នឹងហើយដែលប្រោសមនុស្សអោយរស់ឡើងវិញ
ខ្ញុំនឹងផ្ដល់អោយគេមានជីវិត។ អ្នកណាជឿលើខ្ញុំ ទោះបីស្លាប់ទៅហើយក៏ដោយ ក៏នឹងបានរស់ជាមិនខាន។ 26រីឯអស់អ្នកដែលកំពុងតែមានជីវិតនៅរស់
ហើយជឿលើខ្ញុំ មិនស្លាប់សោះឡើយ តើនាងជឿសេចក្ដីនេះឬទេ?»។ 27នាងម៉ាថាទូលព្រះអង្គថា៖ «បពិត្រព្រះអម្ចាស់! ខ្ញុំម្ចាស់ជឿថា
ព្រះអង្គពិតជាព្រះគ្រិស្ដជាព្រះបុត្រារបស់ព្រះជាម្ចាស់
ហើយពិតជាព្រះអង្គដែលត្រូវយាងមកក្នុងពិភពលោកនេះមែន!»។ 28នាងម៉ាថានិយាយដូច្នេះហើយ ក៏ចេញទៅហៅនាងម៉ារីជាប្អូន ដោយស្ងាត់ៗថា៖
«ព្រះគ្រូយាងមកដល់ហើយព្រះអង្គហៅប្អូនឯង»។ 29នាងម៉ារីឮហើយក៏ស្ទុះក្រោកឡើង ទៅគាល់ព្រះយេស៊ូជាប្រញាប់។ 30ពេលនោះ
ព្រះអង្គពុំទាន់យាងចូលក្នុងភូមិនៅឡើយទេ គឺព្រះអង្គគង់នៅកន្លែងដែលនាងម៉ាថាទៅជួប។ 31ជនជាតិយូដា
ដែលមកជួយរំលែកទុក្ខក្នុងផ្ទះជាមួយនាងម៉ារី ឃើញនាងស្ទុះក្រោកឡើង ប្រញាប់ប្រញាល់ចេញទៅខាងក្រៅដូច្នេះ ក៏នាំគ្នាចេញទៅតាម
ព្រោះគេស្មានថានាងទៅយំឯផ្នូរ។ 32លុះនាងម៉ារីទៅដល់កន្លែងព្រះយេស៊ូគង់នៅហើយ នាងឃើញព្រះអង្គក៏ក្រាបទៀបព្រះបាទាទូលថា៖
«លោកម្ចាស់! ប្រសិនបើលោកបាននៅទីនេះ ប្អូនប្រុសនាងខ្ញុំមិនស្លាប់ទេ»។ 33ពេលព្រះយេស៊ូឃើញនាងម៉ារី និង
ជនជាតិយូដាដែលមកជាមួយនាងយំដូច្នេះ ព្រះអង្គរំជួលព្រះហឫទ័យ ហើយរន្ធត់ជាខ្លាំងផង។ 34ព្រះអង្គមានព្រះបន្ទូលសួរថា៖
«តើអ្នករាល់គ្នាយកសពទៅទុកនៅឯណា?»។ គេទូលព្រះអង្គថា៖ «សូមអញ្ជើញមកលោកនឹងឃើញ»។ 35ពេលនោះ
ព្រះយេស៊ូទ្រង់ព្រះកន្សែង។ 36ជនជាតិយូដានាំគ្នាពោលថា៖ «មើល៍! លោកស្រឡាញ់ឡាសារខ្លាំងណាស់!»។ 37ប៉ុន្តែ នៅក្នុងចំណោមពួកគេ

មានអ្នកខ្លះនិយាយថា៖ «លោកអាចធ្វើអោយមនុស្សខ្វាក់មើលឃើញ
ម្ដេចក៏លោកមិនធ្វើអោយឡាសារគេចផុតពីស្លាប់ផងទៅ!»។ 38ព្រះយេស៊ូរំជួលព្រះហឫទ័យម្ដងទៀត រួចយាងទៅផ្នូរ។
ផ្នូរនោះជារូងភ្នំមានថ្មបាំងនៅមាត់រូង។ 39ព្រះយេស៊ូមានព្រះបន្ទូលថា៖«សុំយកថ្មនេះចេញ!»។
នាងម៉ាថាជាបងរបស់សពទូលព្រះអង្គថា៖«បពិត្រព្រះអម្ចាស់ សពធំក្លិនហើយ ព្រោះគេបានយកមកដាក់
តាំងពីបួនថ្ងៃម៉្លេះ»។ 40ព្រះយេស៊ូមានព្រះបន្ទូលទៅនាងថា៖«ខ្ញុំបានប្រាប់នាងរួចមកហើយថាបើនាងជឿ
នាងនឹងឃើញសិរីរុងរឿងរបស់ព្រះជាម្ចាស់»។ 41គេក៏យកថ្មចេញពីមាត់ផ្នូរ។ ព្រះយេស៊ូងើបព្រះភ័ក្ត្រទតទៅលើ មានព្រះបន្ទូលថា៖ «បពិត្រព្រះបិតា
ទូលបង្គំសូមអរព្រះគុណព្រះអង្គ ដែលទ្រង់ព្រះសណ្ដាប់ទូលបង្គំ។42ចំពោះទូលបង្គំ ទូលបង្គំដឹងថា ព្រះអង្គទ្រង់ព្រះសណ្ដាប់ទូលបង្គំជានិច្ច ប៉ុន្តែ
ទូលបង្គំទូលព្រះអង្គដូច្នេះ ដើម្បីអោយបណ្ដាជនដែលនៅជុំវិញទូលបង្គំជឿថា
ព្រះអង្គពិតជាបានចាត់ទូលបង្គំអោយមកមែន»។ 43លុះព្រះអង្គមានព្រះបន្ទូលដូច្នេះហើយ ទ្រង់បន្លឺព្រះសូរសៀងខ្លាំងៗថា៖
«ឡាសារអើយ!ចេញមក!»។ 44ពេលនោះ លោកឡាសារដែលបានស្លាប់ ក៏ចេញពីផ្នូរមក មានទាំងក្រណាត់រុំដៃជើង និង កន្សែងគ្របមុខផង។
ព្រះយេស៊ូមានព្រះបន្ទូលទៅពួកគេថា៖ «សុំស្រាយក្រណាត់ចេញពីគាត់ ហើយអោយគាត់ទៅចុះ»។ 45ជនជាតិយូដាជាច្រើននាក់
ដែលមកផ្ទះនាងម៉ារីបានឃើញព្រះយេស៊ូធ្វើកិច្ចការទាំងនោះ ក៏ជឿលើព្រះអង្គ។ 46ប៉ុន្តែ មានគ្នាគេខ្លះទៅជួបពួកខាងគណៈផារីស៊ី
រៀបរាប់នូវកិច្ចការដែលព្រះយេស៊ូបានធ្វើ។ 47ពេលនោះ ពួកនាយកបូជាចារ្យ និង ពួកខាងគណៈផារីស៊ី
បានកោះហៅក្រុមប្រឹក្សាជាន់ខ្ពស់មកប្រជុំហើយពោលថា៖

«អ្នកនោះបានធ្វើទីសំគាល់ជាច្រើនតើយើងគិតធ្វើដូចម្ដេច?។ 48ប្រសិនបើយើងបណ្ដោយអោយគាត់ធ្វើដូច្នេះតទៅទៀត
ប្រជាជនមុខតែជឿទៅលើគាត់ទាំងអស់គ្នា ហើយជនជាតិរ៉ូម៉ាំងនឹងមកបំផ្លាញព្រះវិហារ និង
បំបាត់ជាតិសាសន៍របស់យើងជាមិនខាន»។ 49នៅក្នុងចំណោមពួកគេមានលោកម្នាក់ឈ្មោះ កៃផា ដែលជាមហាបូជាចារ្យនៅឆ្នាំនោះ
លោកមានប្រសាសន៍ទៅគេថា៖ «អស់លោកពុំយល់អ្វីសោះ! 50តើអស់លោកគិតមិនឃើញទេឬថា បើមនុស្សតែម្នាក់ស្លាប់
ជាប្រយោជន៍ដល់ប្រជារាស្ដ្រនោះ ប្រសើរជាងទុកអោយជាតិទាំងមូលត្រូវវិនាស!»។ 51លោកមានប្រសាសន៍ដូច្នេះ
មិនមែនផុសចេញពីគំនិតខ្លួនឯងផ្ទាល់ឡើយ គឺក្នុងឋានៈជាមហាបូជាចារ្យនៅឆ្នាំនោះ លោកបានទាយថាព្រះយេស៊ូត្រូវសោយទិវង្គត
ដើម្បីជាប្រយោជន៍ដល់សាសន៍យូដា 52មិនគ្រាន់តែជាប្រយោជន៍ដល់សាសន៍នេះប៉ុណ្ណោះទេគឺដើម្បីអោយកូនចៅរបស់ព្រះជាម្ចាស់ដែលបែកខ្ញែកគ្នា
មករួបរួមជាប្រជាជនតែមួយ។ 53តាំងពីថ្ងៃនោះមក ពួកនាយកបូជាចារ្យ និង
ពួកខាងគណៈផារីស៊ីបានសំរេចធ្វើគុតព្រះយេស៊ូ។ 54ហេតុដូច្នេះហើយបានជាព្រះអង្គមិនយាងទៅមក
ដោយចេញមុខអោយជនជាតិយូដាឃើញទៀតឡើយ គឺព្រះអង្គចាកចេញពីទីនោះ ឆ្ពោះទៅតំបន់ជិតវាលរហោស្ថាន
ត្រង់ភូមិមួយឈ្មោះអេប្រាអ៊ីមហើយទ្រង់ស្នាក់នៅ ក្នុងភូមិនោះជាមួយពួកសិស្ស។ 55ពេលនោះ ជិតដល់ថ្ងៃបុណ្យចម្លងរបស់ជនជាតិយូដាហើយ។
អ្នកស្រុកជាច្រើន នាំគ្នាឡើងទៅក្រុងយេរូសាឡឹម មុនថ្ងៃបុណ្យ ដើម្បីធ្វើពិធីជំរះកាយអោយបានបរិសុទ្ធ។ 56គេរកព្រះយេស៊ូ
ហើយនិយាយគ្នាទៅវិញទៅមកក្នុងព្រះវិហារថា៖ «អ្នកគិតដូចម្ដេច? លោកមិនហ៊ានមកចូលរួមក្នុងពិធីបុណ្យទេមើលទៅ!»។ 57ពួកនាយកបូជាចារ្យ
និង ពួកខាងគណៈផារីស៊ីបានចេញបញ្ជាថា បើអ្នកណាដឹងព្រះអង្គគង់នៅឯណា ត្រូវប្រាប់ពួកគេ ដើម្បីអោយគេចាប់ព្រះអង្គ។

# JOHN - យ៉ូហាន 12

1ប្រាំមួយថ្ងៃ មុនបុណ្យចម្លងព្រះយេស៊ូយាងមកភូមិបេតថានី ជាភូមិរបស់លោកឡាសារ ដែលព្រះអង្គបានប្រោសអោយរស់ឡើងវិញ។ 2នៅទីនោះ
គេរៀបចំជប់លៀងថ្វាយព្រះយេស៊ូ។ នាងម៉ាថាបំរើភ្ញៀវ រីឯលោកឡាសារអង្គុយរួមតុជាមួយព្រះយេស៊ូ និង
អ្នកឯទៀត។ 3នាងម៉ារីយកប្រេងក្រអូបកន្លះលីត្រ គឺប្រេងទេព្វិរូសុទ្ធដ៏មានតម្លៃលើសលប់ មកចាក់លាបព្រះបាទាព្រះយេស៊ូ
រួចយកសក់នាងជូតក្លិនប្រេងក្រអូបសាយពេញផ្ទះ។ 4ពេលនោះសិស្សម្នាក់ឈ្មោះយូដាសអ៊ីស្ការីយ៉ុត ដែលនឹងនាំគេមកចាប់ព្រះអង្គ
ពោលឡើងថា៖ 5«ម្ដេចក៏មិនយកប្រេងក្រអូប ដែលមានតម្លៃបីរយដួងទៅលក់យកប្រាក់ចែកអោយជនក្រីក្រវិញ?»។ 6គាត់និយាយដូច្នេះ
មិនមែនមកពីគាត់យកចិត្តទុកដាក់នឹងអ្នកក្រទេគឺមកពីគាត់ជាចោរ គាត់កាន់ថង់ប្រាក់ ហើយតែងលួចយកប្រាក់ដែលគេដាក់ក្នុងថង់នោះ។ 7ប៉ុន្តែ
ព្រះយេស៊ូមានព្រះបន្ទូលថា៖ «ទុកអោយនាងធ្វើតាមបំណងចិត្តនាងទៅ!
នាងចាក់ប្រេងក្រអូបនេះសំរាប់ថ្ងៃបញ្ចុះសពខ្ញុំ។ 8អ្នកក្រីក្រនៅជាមួយអ្នករាល់គ្នារហូត រីឯខ្ញុំវិញ
ខ្ញុំមិននៅជាមួយអ្នករាល់គ្នារហូតទេ»។ 9ជនជាតិយូដាច្រើនកុះករបានឮដំណឹងថា ព្រះអង្គគង់នៅភូមិបេតថានី
គេនាំគ្នាមកមិនមែនគ្រាន់តែចង់ឃើញព្រះយេស៊ូប៉ុណ្ណោះទេ
គឺចង់ឃើញលោកឡាសារដែលព្រះអង្គបានប្រោសអោយរស់ឡើងវិញនោះថែមទៀតផង។ 10ពួកនាយកបូជាចារ្យបានសំរេចចិត្តសម្លាប់លោកឡាសារដែរ
11ព្រោះតែគាត់នេះហើយ បានជាមានជនជាតិយូដាជាច្រើនបែកចេញពីពួកគេមកជឿលើព្រះយេស៊ូ។ 12នៅថ្ងៃបន្ទាប់
មានបណ្ដាជនច្រើនកុះករមកចូលរួមធ្វើបុណ្យចម្លង។ កាលគេឮដំណឹងថា ព្រះយេស៊ូយាងជិតដល់ក្រុងយេរូសាឡឹម 13គេនាំគ្នាកាច់ធាងទន្សែ

កាន់មកទទួលព្រះអង្គ ទាំងស្រែកថា៖ «ជយោ! សូមព្រះជាម្ចាស់ប្រទានពរដល់ ព្រះអង្គ ដែលយាងមក ក្នុងព្រះនាមព្រះអម្ចាស់
គឺព្រះមហាក្សត្ររបស់ជនជាតិអ៊ីស្រាអែល!»14ព្រះយេស៊ូរកបានកូនលាមួយ ហើយព្រះអង្គគង់លើខ្នងវា
ស្របតាមសេចក្ដីដែលមានចែងទុកមកថា៖ 15ប្រជាជន ក្រុងស៊ីយ៉ូនអើយ កុំភ័យខ្លាចអី! មើលហ្ន៎ ព្រះមហាក្សត្ររបស់អ្នក យាងមកដល់ហើយ
ព្រះអង្គគង់លើខ្នងកូនលា»។ 16នៅពេលនោះ ពួកសិស្សពុំបានយល់ហេតុការណ៍ទាំងនេះភ្លាមៗទេ។ លុះដល់ព្រះយេស៊ូបានសំដែងសិរីរុងរឿងហើយ
ទើបគេនឹកឃើញថាហេតុការណ៍ទាំងនេះ មានចែងទុកអំពីព្រះអង្គ ហើយមហាជនក៏បានធ្វើកិច្ចការទាំងប៉ុន្មាន
ថ្វាយព្រះអង្គស្របតាមគម្ពីរដែរ។ 17អស់អ្នកដែលនៅជាមួយព្រះយេស៊ូកាលព្រះអង្គហៅលោកឡាសារចេញពីផ្នូរ
ហើយប្រោសគាត់អោយរស់ឡើងវិញនោះនាំគ្នាផ្ដល់សក្ខីភាព អំពីកិច្ចការដែលព្រះអង្គបានធ្វើ។ 18បណ្ដាជនមកទទួលព្រះអង្គ
ដ្បិតគេបានឮថាព្រះអង្គបានធ្វើទីសំគាល់នេះ។ 19ពួកខាងគណៈផារីស៊ីនិយាយគ្នាថា៖ «ឃើញទេ យើងមិនអាចឈ្នះបានឡើយ!
មនុស្សម្នានាំគ្នាទៅតាមអ្នកនោះអស់!»។ 20ក្នុងចំណោមអស់អ្នកដែលឡើងទៅថ្វាយបង្គំព្រះជាម្ចាស់ក្នុងឱកាសបុណ្យចម្លង
មានជនជាតិក្រិកខ្លះដែរ។ 21គេចូលទៅជិតលោកភីលីពជាអ្នកភូមិបេតសៃដាក្នុងស្រុកកាលីឡេ ហើយពោលថា៖ «លោកម្ចាស់!
យើងខ្ញុំចង់ជួបលោកយេស៊ូ»។ 22លោកភីលីពទៅប្រាប់លោកអនទ្រេ ហើយលោកអនទ្រេ និង លោកភីលីព
ចូលទៅទូលព្រះយេស៊ូ។ 23ព្រះយេស៊ូមានព្រះបន្ទូលទៅគេថា៖ «ឥឡូវនេះ ដល់ពេលកំណត់ដែលបុត្រមនុស្សត្រូវសំដែង
សិរីរុងរឿងហើយ។ 24ខ្ញុំសុំប្រាប់អោយអ្នករាល់គ្នាដឹងច្បាស់ថា គ្រាប់ស្រូវធ្លាក់ដល់ដីហើយ បើមិនងាប់ទេ គ្រាប់នោះនៅតែមួយដដែល។ ផ្ទុយទៅវិញ
បើគ្រាប់ស្រូវនោះងាប់វានឹងបង្កើតផលបានច្រើន។ 25អ្នកណាស្រឡាញ់ជីវិតរបស់ខ្លួន អ្នកនោះនឹងបាត់បង់ជីវិតទៅ

រីឯអ្នកដែលមិនជំពាក់ចិត្តនឹងជីវិតរបស់ខ្លួន ក្នុងពិភពលោកនេះទេនឹងរក្សាជីវិតខ្លួនអោយនៅស្ថិតស្ថេរអស់កល្បជានិច្ច។ 26បើអ្នកណាចង់បំរើខ្ញុំ
អ្នកនោះត្រូវមកតាមខ្ញុំ ខ្ញុំនៅទីណា អ្នកបំរើរបស់ខ្ញុំក៏នឹងនៅទីនោះដែរ។ បើអ្នកណាបំរើខ្ញុំ ព្រះបិតានឹងលើកកិត្តិយសអ្នកនោះ»។27«ឥឡូវនេះ
ទូលបង្គំរន្ធត់ចិត្តណាស់ មិនដឹងជានឹងទូលថាដូចម្ដេចឡើយ។ ឱព្រះបិតាអើយ សូមសង្គ្រោះទូលបង្គំអោយរួចផុតពីទុក្ខលំបាក នៅពេលកំណត់នេះផង។
ប៉ុន្តែ ទូលបង្គំមក ដើម្បីរងទុក្ខលំបាកក្នុងពេលកំណត់នេះហើយ។ 28ព្រះបិតាអើយ សំដែងសិរីរុងរឿង ព្រះនាមរបស់ព្រះអង្គឡើង»។
ពេលនោះមានឮព្រះសូរសៀងពីលើមេឃមកថា៖
«យើងបានសំដែងសិរីរុងរឿងរបស់យើងហើយយើងក៏នឹងសំដែងសិរីរុងរឿងជាថ្មីទៀត»។ 29បណ្ដាជននៅទីនោះ បានឮព្រះសូរសៀង
ក៏ពោលថា«សន្ធឹកផ្គរលាន់» អ្នកខ្លះទៀត ពោលថា«មានទេវតានិយាយមកលោក»។30ព្រះយេស៊ូមានព្រះបន្ទូលថា៖ «សំឡេងនេះ
បន្លឺឡើងសំរាប់អ្នករាល់គ្នាមិនមែនសំរាប់ខ្ញុំទេ។ 31ឥឡូវនេះ ដល់ពេលកាត់ទោសមនុស្សលោកហើយ
ហើយចៅហ្វាយរបស់មនុស្សលោកនឹងត្រូវបណ្ដេញចេញទៅក្រៅ។32រីឯខ្ញុំវិញ កាលណាគេលើកខ្ញុំឡើងពីដី
ខ្ញុំនឹងទាញមនុស្សទាំងអស់មកឯខ្ញុំ»។ 33ព្រះអង្គមានព្រះបន្ទូលដូច្នេះ
ដើម្បីប្រាប់គេអំពីរបៀបដែលព្រះអង្គត្រូវសោយទិវង្គត។ 34បណ្ដាជននាំគ្នាទូលអង្វរព្រះអង្គថា៖ «យើងបានដឹងតាមរយៈក្រឹត្យវិន័យថា
ព្រះគ្រិស្តត្រូវស្ថិតនៅអស់កល្បជានិច្ច ចុះម្ដេចក៏លោកមានប្រសាសន៍ថា
បុត្រមនុស្សនឹងត្រូវគេលើកឡើងពីដីដូច្នេះ? 35តើនរណាជាបុត្រមនុស្សនោះ?»។ ព្រះយេស៊ូមានព្រះបន្ទូលទៅគេថា៖
«ពន្លឺនៅជាមួយអ្នករាល់គ្នាតែបន្តិច ទៀតប៉ុណ្ណោះ។ ចូរនាំគ្នាដើរ ក្នុងពេលដែលអ្នករាល់គ្នាកំពុងតែមានពន្លឺនៅឡើយ

ក្រែងលោសេចក្ដីងងឹតតាមអ្នករាល់គ្នាទាន់
ដ្បិតអ្នកដើរក្នុងសេចក្ដីងងឹតពុំដឹងថាខ្លួនធ្វើដំណើរទៅទីណាទេ។36ក្នុងពេលដែលអ្នករាល់គ្នានៅមានពន្លឺនៅឡើយ ចូរនាំគ្នាជឿលើពន្លឺ
ដើម្បីអោយបានទៅជាបុត្រធីតានៃពន្លឺ»។ កាលព្រះយេស៊ូមានព្រះបន្ទូលដូច្នេះហើយ
ទ្រង់យាងចេញទៅលាក់ខ្លួនមិនអោយបណ្ដាជនឃើញ។37ទោះបីព្រះយេស៊ូធ្វើទីសំគាល់ជាច្រើនអោយគេឃើញយ៉ាងណាក៏ដោយ
ក៏គេនៅតែពុំជឿលើព្រះអង្គដដែល 38គឺស្របតាមសេចក្ដីដែលព្យាការីអេសាយបានថ្លែងទុកមកថា៖ «បពិត្រព្រះអម្ចាស់ តើនរណាជឿសេចក្ដី
ដែលយើងនិយាយប្រាប់? តើព្រះអម្ចាស់បានសំដែងឫទ្ធិបារមី អោយនរណាឃើញ?»។ 39គេពុំអាចជឿបានឡើយ
ស្របតាមសេចក្ដីដែលព្យាការីអេសាយបានថ្លែងទៀតថា៖ 40«ព្រះអង្គបានធ្វើអោយភ្នែកគេខ្វាក់ អោយចិត្តគេរឹង មិនអោយភ្នែកគេមើលឃើញ
មិនអោយប្រាជ្ញាគេយល់ ហើយមិនអោយគេងាកមករកយើង ក្រែងលោយើងប្រោសគេអោយបានជា»។41ព្យាការីអេសាយពោលពាក្យទាំងនេះ
មកពីលោកបានឃើញសិរីរុងរឿងរបស់ព្រះយេស៊ូ ហើយលោកក៏ថ្លែងទុកអំពីព្រះអង្គ។ 42ក្នុងចំណោមអ្នកដឹកនាំ មានគ្នាច្រើននាក់ជឿលើព្រះអង្គដែរ
ប៉ុន្ដែ អ្នកទាំងនោះពុំហ៊ានប្រកាសជំនឿរបស់ខ្លួនឡើយ ព្រោះខ្លាចពួកខាងគណៈផារីស៊ី និង
ខ្លាចគេដេញចេញពីសាលាប្រជុំ 43ដ្បិតពួកគេចូលចិត្តទទួលសិរីរុងរឿងពីមនុស្សជាជាងទទួលសិរីរុងរឿងពីព្រះជាម្ចាស់។ 44ព្រះយេស៊ូបន្លឺព្រះសូរសៀ
ងខ្លាំងៗថា៖ «អ្នកណាជឿលើខ្ញុំ មិនត្រឹមតែជឿលើខ្ញុំប៉ុណ្ណោះទេ
គឺជឿលើព្រះអង្គដែលបានចាត់ខ្ញុំអោយមកនោះដែរ។ 45អ្នកណាឃើញខ្ញុំអ្នកនោះក៏ឃើញព្រះអង្គដែលបានចាត់ខ្ញុំអោយមកដែរ។ 46ខ្ញុំជាពន្លឺ
ខ្ញុំមកក្នុងពិភពលោកនេះ ដើម្បីកុំអោយអស់អ្នកដែលជឿលើខ្ញុំ ស្ថិតនៅក្នុងសេចក្ដីងងឹត។ 47បើអ្នកណាឮពាក្យខ្ញុំហើយ តែមិនប្រតិបត្ដិតាម

មិនមែនខ្ញុំទេដែលកាត់ទោសអ្នកនោះដ្បិតខ្ញុំមក មិនមែនដើម្បីកាត់ទោសមនុស្សលោកទេ គឺខ្ញុំមកសង្គ្រោះមនុស្សលោកវិញ។ 48អ្នកណាផាត់ខ្ញុំចោល
ហើយមិនទទួលពាក្យខ្ញុំ អ្នកនោះមានចៅក្រមកាត់ទោសរួចស្រេចទៅហើយ គឺពាក្យដែលខ្ញុំបាននិយាយនឹងកាត់ទោសគេ
នៅថ្ងៃចុងក្រោយបង្អស់។49ពាក្យដែលខ្ញុំបាននិយាយនេះ មិនមែនចេញមកពីខ្ញុំទេ គឺព្រះបិតាដែលបានចាត់ខ្ញុំអោយមក
ទ្រង់បង្គាប់ខ្ញុំនូវសេចក្ដីដែលខ្ញុំត្រូវនិយាយ និង ថ្លែង។50ខ្ញុំដឹងថាបទបញ្ជារបស់ព្រះអង្គផ្ដល់ជីវិតអស់កល្បជានិច្ច។ សេចក្ដីណាដែលខ្ញុំនិយាយ
ខ្ញុំនិយាយដូចព្រះបិតាមានព្រះបន្ទូលមកខ្ញុំដែរ»។

# JOHN - យ៉ូហាន 13

1នៅមុនថ្ងៃបុណ្យចម្លង ព្រះយេស៊ូជ្រាបថា ដល់ពេលកំណត់ដែលព្រះអង្គត្រូវឆ្លងពីលោកនេះ ឆ្ពោះទៅព្រះបិតាហើយ។
ដោយព្រះអង្គស្រឡាញ់សិស្សរបស់ព្រះអង្គដែលរស់នៅក្នុងលោកនេះ ទ្រង់ក៏ស្រឡាញ់គេរហូតដល់ទីបំផុត។ 2ពេលនោះ ព្រះយេស៊ូ និង
ពួកសិស្សកំពុងបរិភោគអាហារ មារសាតាំងបានធ្វើអោយយូដាសអ៊ីស្ការីយ៉ុតជាកូនលោកស៊ីម៉ូន មានគំនិតនាំគេមកចាប់ព្រះអង្គ។ 3ព្រះយេស៊ូជ្រាបថា
ព្រះបិតាបានប្រគល់អ្វីៗទាំងអស់មកក្រោមអំណាចព្រះអង្គ ហើយជ្រាបថា ព្រះអង្គយាងមកពីព្រះជាម្ចាស់ និង
យាងទៅឯព្រះជាម្ចាស់វិញ។ 4ព្រះអង្គក្រោកឡើង ដោះព្រះពស្ត្រចេញ យកក្រមាមកក្រវាត់ចង្កេះ។ 5បន្ទាប់មក ព្រះអង្គចាក់ទឹកក្នុងផើងមួយ
រួចចាប់ផ្ដើមលាងជើងពួកសិស្ស ព្រមទាំងយកក្រមាពីចង្កេះមកជូតផង។ 6ពេលព្រះអង្គហៀបនឹងលាងជើងអោយលោកស៊ីម៉ូនពេត្រុស

លោកទូលព្រះអង្គថា៖ «ព្រះអម្ចាស់អើយ មិនសមនឹងព្រះអង្គលាងជើងអោយទូលបង្គំសោះ!»។ 7ព្រះយេស៊ូមានព្រះបន្ទូលទៅគាត់ថា៖ «ពេលនេះ

អ្នកមិនទាន់ដឹងថា ខ្ញុំកំពុងធ្វើអ្វីឡើយ ថ្ងៃក្រោយអ្នកមុខ តែយល់ជាមិនខាន»។ 8លោកពេត្រុសទូលព្រះអង្គថា៖ «ទេ

ព្រះអង្គមិនត្រូវលាងជើងទូលបង្គំជាដាច់ខាត!»។ ព្រះយេស៊ូមានព្រះបន្ទូលទៅគាត់ថា៖ «ប្រសិនបើខ្ញុំមិនលាងជើងអ្នកទេ

នោះអ្នកមិនអាចរួមជាមួយខ្ញុំតទៅទៀតបានឡើយ»។ 9លោកស៊ីម៉ូនក៏ទូលព្រះអង្គថា៖ «ព្រះអម្ចាស់អើយ បើដូច្នេះសូមកុំលាងតែជើងប៉ុណ្ណោះ

សូមលាងទាំងដៃ ទាំងក្បាលផង»។10ព្រះយេស៊ូមានព្រះបន្ទូលតបថា៖ «អ្នកដែលបានងូតទឹករួច មិនបាច់លាងខ្លួនទេ គឺលាងតែជើង

ដ្បិតខ្លួនគេស្អាតបរិសុទ្ធទាំងមូលហើយ។ អ្នករាល់គ្នាបានស្អាតបរិសុទ្ធ តែមិនមែនគ្រប់គ្នាទេ»។ 11ព្រះអង្គមានព្រះបន្ទូលថា

"អ្នករាល់គ្នាមិនមែនបរិសុទ្ធគ្រប់គ្នា"ដូច្នេះ

មកពីព្រះអង្គជ្រាបអំពីអ្នកដែលហៀបនឹងនាំគេមកចាប់ព្រះអង្គ។ 12កាលព្រះយេស៊ូលាងជើងអោយគេរួចហើយ ព្រះអង្គស្លៀកពាក់ឡើងវិញ យាងមកគុ

ទាំងមានព្រះបន្ទូលសួរទៅគេថា៖ «តើអ្នករាល់គ្នាយល់អំពីកិច្ចការដែលខ្ញុំបានធ្វើ ចំពោះអ្នករាល់គ្នានេះឬទេ? 13អ្នករាល់គ្នាហៅខ្ញុំថា ព្រះគ្រូ និង

ព្រះអម្ចាស់ នោះត្រូវមែនគឺខ្ញុំហ្នឹងហើយ!។ 14បើខ្ញុំជាព្រះអម្ចាស់ និង ជាព្រះគ្រូបានលាងជើងអោយអ្នករាល់គ្នាទៅហើយ

អ្នករាល់គ្នាក៏ត្រូវតែលាងជើងអោយគ្នាទៅវិញទៅមកដែរ។ 15ខ្ញុំបានធ្វើជាគំរូអោយអ្នករាល់គ្នាប្រព្រឹត្ត

ដូចខ្ញុំបានប្រព្រឹត្តដល់អ្នករាល់គ្នា។ 16ខ្ញុំសុំប្រាប់អោយអ្នករាល់គ្នាដឹងច្បាស់ថា អ្នកបំរើមិនដែលធំជាងម្ចាស់ឡើយ

រីឯអ្នកដែលគេចាត់អោយទៅក៏មិនដែលធំជាងអ្នកចាត់ខ្លួនអោយទៅនោះដែរ។ 17ប្រសិនបើអ្នករាល់គ្នាដឹងសេចក្ដីនេះ ហើយប្រតិបត្តិតាម

អ្នករាល់គ្នាមុខជាមានសុភមង្គលមិនខាន។ 18ខ្ញុំនិយាយដូច្នេះ មិនមែនសំដៅលើអ្នកទាំងអស់គ្នាទេ ដ្បិតខ្ញុំស្គាល់អស់អ្នកដែលខ្ញុំបានជ្រើសរើស

តែខ្ញុំនិយាយនេះ ដើម្បីអោយបានស្របតាមសេចក្ដីដែលមានចែងទុកក្នុងគម្ពីរថា: "អ្នកបរិភោគអាហារជាមួយខ្ញុំ
បានប្រឆាំងនឹងខ្ញុំ"។ 19ខ្ញុំនិយាយប្រាប់អ្នករាល់គ្នា ពីឥឡូវនេះ អោយហើយមុនការណ៍ទាំងនោះកើតមាន។
កាលណាការណ៍ទាំងនោះមកដល់អ្នករាល់គ្នានឹងជឿថា ខ្ញុំពិតជាព្រះជាម្ចាស់មែន។ 20ខ្ញុំសុំប្រាប់អោយអ្នករាល់គ្នាដឹងច្បាស់ថា
អ្នកណាទទួលអ្នកដែលខ្ញុំនឹងចាត់អោយទៅ ក៏ដូចជាទទួលខ្ញុំ ហើយអ្នកណាទទួលខ្ញុំ
ក៏ដូចជាទទួលព្រះអង្គដែលបានចាត់ខ្ញុំអោយមកនោះដែរ»។ 21កាល ព្រះយេស៊ូមានព្រះបន្ទូលដូច្នេះ ហើយ ព្រះអង្គរន្ធត់ព្រះហឫទ័យក្រៃលែង
ទ្រង់មានព្រះបន្ទូលបញ្ជាក់ទៀតថា៖ «ខ្ញុំសុំប្រាប់អោយអ្នករាល់គ្នាដឹងច្បាស់ថា ក្នុងចំណោមអ្នករាល់គ្នា
មានម្នាក់នឹងនាំគេមកចាប់ខ្ញុំ»។ 22ពួកសិស្សងាកមើលមុខគ្នាទៅវិញទៅមក
មិនដឹងថាព្រះអង្គមានព្រះបន្ទូលពីនរណា។ 23សិស្សម្នាក់ដែលព្រះយេស៊ូស្រឡាញ់អង្គុយក្បែរព្រះអង្គ។ 24លោកស៊ីម៉ូនពេត្រុសធ្វើសញ្ញាអោយគាត់សួ
រព្រះយេស៊ូថា ព្រះអង្គមានព្រះបន្ទូលពីនរណា។ 25សិស្សនោះក៏អោនទៅជិតព្រះឱរាព្រះយេស៊ូទូលសួរថា៖ «បពិត្រព្រះអម្ចាស់
តើនរណាមួយ?»។ 26ព្រះយេស៊ូមានព្រះបន្ទូលតបទៅគាត់ថា៖ «ខ្ញុំជ្រលក់នំប៉័ងមួយដុំហុចទៅអោយអ្នកណា គឺអ្នកនោះហើយ»។
ព្រះអង្គជ្រលក់នំប៉័ងមួយដុំហុចទៅអោយយូដាសអ៊ីស្ការីយ៉ុតជាកូនរបស់លោកស៊ីម៉ូន។27ពេលយូដាសទទួលដុំនំប៉័ងនោះ មារសាតាំងក៏ចូលក្នុងចិត្តគាត់។
ព្រះយេស៊ូមានព្រះបន្ទូលទៅគាត់ថា៖«កិច្ចការដែលអ្នកត្រូវធ្វើ ចូរធ្វើអោយឆាប់ៗទៅ!»។ 28ក្នុងបណ្ដាអស់អ្នកដែលនៅរួមតុ គ្មាននរណាម្នាក់យល់ថា
ហេតុអ្វីបានជាព្រះអង្គមានព្រះបន្ទូលដូច្នេះឡើយ។ 29ដោយយូដាសកាន់ថង់ប្រាក់ អ្នកខ្លះនឹកស្មានថា
ព្រះយេស៊ូប្រើគាត់អោយទៅទិញរបស់របរសំរាប់ពិធីបុណ្យ ឬ អោយយកប្រាក់ទៅចែកដល់ជនក្រីក្រ។ 30យូដាសទទួលយកដុំនំប៉័ង រួចចេញទៅភ្លាម

ពេលនោះ យប់ងងឹតហើយ។ 31លុះយូដាសចេញផុតទៅ ព្រះយេស៊ូមានព្រះបន្ទូលថា៖ «ឥឡូវនេះ បុត្រមនុស្សបានសំដែងសិរីរុងរឿងហើយ
ហើយព្រះជាម្ចាស់ក៏បានសំដែងសិរីរុងរឿងក្នុងបុត្រមនុស្សដែរ។ 32បើព្រះជាម្ចាស់បានសំដែងសិរីរុងរឿងក្នុងបុត្រមនុស្ស
ព្រះអង្គក៏នឹងសំដែងសិរីរុងរឿងរបស់បុត្រមនុស្ស ក្នុងព្រះអង្គផ្ទាល់ដែរ!
ហើយព្រះអង្គនឹងសំដែងសិរីរុងរឿងរបស់បុត្រមនុស្សក្នុងពេលឆាប់ៗខាងមុខនេះ។ 33ម្នាលកូនចៅអើយ
ខ្ញុំនៅជាមួយអ្នករាល់គ្នាតែមួយរយ:ពេលដ៏ខ្លីទៀត។ អ្នករាល់គ្នានឹងតាមរកខ្ញុំ ប៉ុន្តែឥឡូវនេះ
ខ្ញុំសុំប្រាប់អ្នករាល់គ្នាដូចខ្ញុំបានប្រាប់ជនជាតិយូដាមកហើយដែរថា
អ្នករាល់គ្នាពុំអាចទៅកន្លែងដែលខ្ញុំទៅនោះបានឡើយ។ 34ខ្ញុំអោយបទបញ្ជាថ្មីដល់អ្នករាល់គ្នា គឺត្រូវស្រឡាញ់គ្នាទៅវិញទៅមក។
អ្នករាល់គ្នាត្រូវស្រឡាញ់គ្នាទៅវិញទៅមក ដូចខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ។ 35បើអ្នកស្រឡាញ់គ្នាទៅវិញទៅមកមនុស្សទាំងអស់មុខជាដឹងថា
អ្នករាល់គ្នាពិតជាសិស្សរបស់ខ្ញុំមែន»។36លោកស៊ីម៉ូនពេត្រុស ទូលសួរព្រះអង្គថា៖ «បពិត្រព្រះអម្ចាស់ តើព្រះអង្គយាងទៅណា?»។
ព្រះយេស៊ូមានព្រះបន្ទូលឆ្លើយថា៖ «កន្លែងដែលខ្ញុំទៅ អ្នកមិនអាចទៅតាមខ្ញុំនៅពេលនេះបានទេ
ថ្ងៃក្រោយទើបអ្នកទៅបាន»។37លោកពេត្រុសទូលព្រះអង្គទៀតថា៖ «បពិត្រព្រះអម្ចាស់
ហេតុដូចម្ដេចបានជាទូលបង្គំមិនអាចទៅតាមព្រះអង្គឥឡូវនេះ? ទូលបង្គំសុខចិត្តស៊ូប្ដូរជីវិតសំរាប់ព្រះអង្គ»។ 38ព្រះយេស៊ូមានព្រះបន្ទូលតបថា៖
«អ្នកសុខចិត្តស៊ូប្ដូរជីវិតសំរាប់ខ្ញុំមែន! តែខ្ញុំសុំប្រាប់អោយអ្នកដឹងច្បាស់ថា មុនមាន់រងាវ អ្នកនឹងបដិសេធបីដងថាមិនស្គាល់ខ្ញុំ»។

# JOHN - យ៉ូហាន 14

1«កុំរន្ធត់ចិត្តធ្វើអ្វី អ្នករាល់គ្នាជឿលើព្រះជាម្ចាស់ហើយ សុំជឿលើខ្ញុំផង។2ក្នុងដំណាក់របស់ព្រះបិតាខ្ញុំ មានលំនៅជាច្រើន។ បើពុំដូច្នោះទេ
ខ្ញុំមិនបានប្រាប់អ្នករាល់គ្នាថា ខ្ញុំទៅរៀបចំកន្លែងទុកអោយអ្នករាល់គ្នាឡើយ។3ពេលខ្ញុំទៅរៀបចំកន្លែងទុកអោយអ្នករាល់គ្នារួចហើយខ្ញុំនឹងត្រឡប់មកវិញ
យកអ្នករាល់គ្នាទៅជាមួយខ្ញុំ ដើម្បីអោយអ្នករាល់គ្នាបាននៅកន្លែងដែលខ្ញុំនៅ។ 4ឯកន្លែងដែលខ្ញុំទៅនោះ
អ្នករាល់គ្នាក៏ស្គាល់ផ្លូវទៅដែរ»។5លោកថូម៉ាសទូលព្រះអង្គថា៖ «បពិត្រព្រះអម្ចាស់ ធ្វើដូចម្ដេចអោយយើងខ្ញុំអាចស្គាល់ផ្លូវទៅបាន
បើយើងខ្ញុំមិនដឹងថាព្រះអង្គយាងទៅទីណាផងនោះ»។ 6ព្រះយេស៊ូមានព្រះបន្ទូលទៅគាត់ថា៖ «ខ្ញុំហ្នឹងហើយជាផ្លូវ ជាសេចក្ដីពិត និង ជាជីវិត។
គ្មាននរណាម្នាក់អាចទៅកាន់ព្រះបិតាបានឡើយ លើកលែងតែទៅតាមរយៈខ្ញុំ។ 7បើអ្នករាល់គ្នាស្គាល់ខ្ញុំ អ្នករាល់គ្នាក៏ស្គាល់ព្រះបិតារបស់ខ្ញុំដែរ។ ឥឡូវនេះ
អ្នករាល់គ្នាស្គាល់ព្រះអង្គហើយ ព្រមទាំងបានឃើញព្រះអង្គថែមទៀតផង»។ 8លោកភីលីពទូលព្រះអង្គថា៖ «ព្រះអម្ចាស់អើយ!
សូមបង្ហាញព្រះបិតាអោយយើងខ្ញុំឃើញផង នោះយើងខ្ញុំអស់ចិត្តហើយ»។ 9ព្រះយេស៊ូមានព្រះបន្ទូលទៅគាត់ថា៖ «ភីលីពអើយ
ខ្ញុំនៅជាមួយអ្នករាល់គ្នាតាំងពីយូរមកហើយ ម្ដេចអ្នកនៅតែមិនស្គាល់ខ្ញុំ!។ អ្នកណាបានឃើញខ្ញុំ ក៏បានឃើញព្រះបិតាដែរ។
ហេតុដូចម្ដេចបានជាអ្នកថាសូមបង្ហាញព្រះបិតាអោយ យើងខ្ញុំឃើញផងដូច្នេះ? 10តើអ្នកមិនជឿថា ខ្ញុំនៅក្នុងព្រះបិតា ហើយព្រះបិតាគង់នៅក្នុងខ្ញុំទេឬ?
សេចក្ដីដែលខ្ញុំនិយាយប្រាប់អ្នករាល់គ្នា មិនមែនចេញមកពីខ្ញុំផ្ទាល់ទេ គឺព្រះបិតាដែលស្ថិតនៅជាប់នឹងខ្ញុំ
ទ្រង់បំពេញកិច្ចការរបស់ព្រះអង្គ។ 11ពេលខ្ញុំនិយាយថា ខ្ញុំនៅក្នុងព្រះបិតាហើយព្រះបិតានៅក្នុងខ្ញុំ ចូរជឿខ្ញុំចុះ បើមិនជឿសេចក្ដីដែលខ្ញុំនិយាយនេះទេ
ចូរជឿដោយឃើញកិច្ចការទាំងនោះទៅ។ 12ខ្ញុំសុំប្រាប់អោយអ្នករាល់គ្នាដឹងច្បាស់ថា អ្នកណាជឿលើខ្ញុំ អ្នកនោះនឹងធ្វើកិច្ចការដែលខ្ញុំធ្វើដែរ

ហើយនឹងធ្វើកិច្ចការធំជាងនេះទៅទៀត ពីព្រោះខ្ញុំទៅឯព្រះបិតា។ 13អ្វីៗដែលអ្នករាល់គ្នាទូលសូមក្នុងនាមខ្ញុំ ខ្ញុំនឹងធ្វើកិច្ចការនោះជាមិនខាន
ដើម្បីអោយព្រះបិតាសំដែងសិរីរុងរឿងក្នុងព្រះបុត្រា។ 14បើអ្នករាល់គ្នាសូមអ្វីក្នុងនាមខ្ញុំ
ខ្ញុំនឹងធ្វើកិច្ចការនោះ»។ 15«ប្រសិនបើអ្នករាល់គ្នាស្រឡាញ់ខ្ញុំ អ្នករាល់គ្នាពិតជាកាន់តាមបទបញ្ជារបស់ខ្ញុំ 16ខ្ញុំនឹងទូលអង្វរព្រះបិតា
ហើយទ្រង់ប្រទានព្រះដ៏ជួយការពារ មួយអង្គទៀត អោយគង់នៅជាមួយអ្នករាល់គ្នាជាដរាបតរៀងទៅ 17ព្រះអង្គជាព្រះវិញ្ញាណដែលសំដែងសេចក្ដីពិត។
មនុស្សលោកពុំអាចទទួលព្រះអង្គបានទេ ព្រោះគេមើលព្រះអង្គមិនឃើញ ហើយក៏មិនស្គាល់ព្រះអង្គផង។
រីឯអ្នករាល់គ្នាវិញអ្នករាល់គ្នាស្គាល់ព្រះអង្គព្រោះព្រះអង្គស្ថិតនៅជាប់នឹងអ្នករាល់គ្នា
ហើយព្រះអង្គនឹងគង់ក្នុងអ្នករាល់គ្នា។ 18ខ្ញុំមិនចោលអ្នករាល់គ្នាអោយនៅកំព្រាឡើយ ខ្ញុំនឹងមករកអ្នករាល់គ្នាវិញ។ 19បន្តិចទៀត
មនុស្សលោកនឹងលែងឃើញខ្ញុំទៀតហើយ។ រីឯអ្នករាល់គ្នាវិញ អ្នករាល់គ្នានឹងឃើញខ្ញុំព្រោះខ្ញុំមានជីវិតរស់
ហើយអ្នករាល់គ្នាក៏នឹងមានជីវិតរស់ដែរ។ 20នៅថ្ងៃនោះ អ្នករាល់គ្នានឹងដឹងថា ខ្ញុំនៅក្នុងព្រះបិតារបស់ខ្ញុំ ហើយអ្នករាល់គ្នានៅក្នុងខ្ញុំ
ខ្ញុំក៏នៅក្នុងអ្នករាល់គ្នាដែរ។ 21អ្នកណាមានបទបញ្ជារបស់ខ្ញុំ និង ប្រតិបត្តិតាម គឺអ្នកនោះហើយដែលស្រឡាញ់ខ្ញុំ។
ព្រះបិតារបស់ខ្ញុំស្រឡាញ់អ្នកដែលស្រឡាញ់ខ្ញុំ ហើយខ្ញុំក៏ស្រឡាញ់អ្នកនោះដែរ ខ្ញុំនឹងបង្ហាញអោយអ្នកនោះស្គាល់ខ្ញុំថែមទៀតផង»។ 22លោកយូដាស
(មិនមែនយូដាសអ៊ីស្ការីយ៉ុតទេ) ទូលព្រះអង្គថា៖ «បពិត្រព្រះអម្ចាស់ ហេតុដូចម្ដេចបានជាព្រះអង្គបង្ហាញអោយតែយើងខ្ញុំស្គាល់ព្រះអង្គ
មិនអោយមនុស្សលោកស្គាល់ផងដូច្នេះ?»។23ព្រះយេស៊ូមានព្រះបន្ទូលទៅគាត់ថា៖ «អ្នកណាស្រឡាញ់ខ្ញុំអ្នកនោះនឹងប្រតិបត្តិតាមពាក្យខ្ញុំ។
ព្រះបិតាខ្ញុំនឹងស្រឡាញ់អ្នកនោះ ហើយព្រះបិតា និង ខ្ញុំក៏នឹងមកតាំងលំនៅ នៅក្នុងអ្នកនោះដែរ។ 24អ្នកណាមិនស្រឡាញ់ខ្ញុំ

អ្នកនោះមិនប្រតិបត្តិតាមពាក្យខ្ញុំឡើយ។ ពាក្យដែលអ្នករាល់គ្នាឮខ្ញុំនិយាយ មិនមែនជាពាក្យរបស់ខ្ញុំទេ
គឺជាព្រះបន្ទូលរបស់ព្រះបិតាដែលបានចាត់ខ្ញុំអោយមក។ 25ខ្ញុំបានប្រាប់សេចក្ដីទាំងនេះអោយអ្នករាល់គ្នាដឹងក្នុងពេលដែលខ្ញុំស្ថិតនៅជាមួយអ្នករាល់គ្នា
នៅឡើយ 26ប៉ុន្តែ ព្រះដ៏ជួយការពារ គឺព្រះវិញ្ញាណដ៏វិសុទ្ធដែលព្រះបិតាចាត់អោយមកក្នុងនាមខ្ញុំនឹងបង្រៀនសេចក្ដីទាំងអស់ដល់អ្នករាល់គ្នា
ព្រមទាំងរំលឹកអ្វីៗដែលខ្ញុំបានប្រាប់អ្នករាល់គ្នាផង។ 27ខ្ញុំទុកសេចក្ដីសុខសាន្ដអោយអ្នករាល់គ្នា ខ្ញុំផ្ដល់សេចក្ដីសុខសាន្ដរបស់ខ្ញុំអោយអ្នករាល់គ្នា។
សេចក្ដីសុខសាន្ដដែលខ្ញុំផ្ដល់អោយនេះ មិនដូចសេចក្ដីសុខសាន្ដដែលមនុស្សលោកអោយទេ។ ចូរកុំរន្ធត់ចិត្ត
កុំភ័យខ្លាចអោយសោះ។ 28អ្នករាល់គ្នាបានឮខ្ញុំនិយាយរួចមកហើយថា ខ្ញុំនឹងចាកចេញទៅ រួចខ្ញុំមករកអ្នករាល់គ្នាវិញ។ ប្រសិនបើអ្នករាល់គ្នាស្រឡាញ់ខ្ញុំ
អ្នករាល់គ្នាមុខតែសប្បាយចិត្តដោយខ្ញុំទៅឯព្រះបិតា ដ្បិតព្រះបិតាមានឋានៈធំជាងខ្ញុំ។ 29ខ្ញុំប្រាប់អោយអ្នករាល់គ្នាដឹងឥឡូវនេះ
មុនហេតុការណ៍ទាំងនោះកើតឡើង។ លុះដល់ហេតុការណ៍ទាំងនោះកើតឡើង អ្នករាល់គ្នានឹងជឿ។ 30ខ្ញុំនិយាយជាមួយអ្នករាល់គ្នាមិនបានច្រើនទៀតទេ
ព្រោះចៅហ្វាយរបស់លោកីយ៍កំពុងតែមកវាគ្មានអំណាចអ្វីលើខ្ញុំសោះ។31វាមកដូច្នេះ ជាឱកាសអោយមនុស្សលោកដឹងថា
ខ្ញុំស្រឡាញ់ព្រះបិតាហើយខ្ញុំសុខចិត្តធ្វើតាមបង្គាប់របស់ព្រះអង្គ។ ចូរក្រោកឡើង យើងនាំគ្នាចេញពីទីនេះ»។

# JOHN - យ៉ូហាន 15

1«ខ្ញុំហ្នឹងហើយជាដើមទំពាំងបាយជូរដ៏ពិតប្រាកដ រីឯព្រះបិតាខ្ញុំ ជាម្ចាស់ចំការ។ 2មែកណានៅជាប់នឹងខ្ញុំ តែឥតមានផ្លែព្រះបិតាកាត់មែកនោះចោល។
រីឯមែកណាមានផ្លែព្រះអង្គលួសមែកនោះ ដើម្បីអោយមានផ្លែកាន់តែច្រើនឡើងទៀត។ 3ពាក្យដែលខ្ញុំបានប្រាប់

ធ្វើអោយអ្នករាល់គ្នាបរិសុទ្ធរួចទៅហើយ។ 4ចូរស្ថិតនៅជាប់នឹងខ្ញុំ ដូចខ្ញុំស្ថិតនៅជាប់នឹងអ្នករាល់គ្នាដែរ។ ប្រសិនបើមែកមិនស្ថិតនៅជាប់នឹងដើមទេ
វាពុំអាចបង្កើតផលដោយឯកឯងបានឡើយ។ រីឯអ្នករាល់គ្នាក៏ដូច្នោះដែរ បើមិនស្ថិតនៅជាប់នឹងខ្ញុំទេ
អ្នករាល់គ្នាពុំអាចបង្កើតផលបានទាល់តែសោះ។ 5ខ្ញុំនេះហើយជាដើមទំពាំងបាយជូរ អ្នករាល់គ្នាជាមែក អ្នកណាស្ថិតនៅជាប់នឹងខ្ញុំ
ហើយខ្ញុំនៅជាប់នឹងអ្នកនោះ ទើបអ្នកនោះបង្កើតផលបានច្រើន។ បើដាច់ពីខ្ញុំ អ្នករាល់គ្នាពុំអាចធ្វើអ្វីកើតឡើយ។ 6អ្នកណាមិនស្ថិតនៅជាប់នឹងខ្ញុំ
អ្នកនោះប្រៀបដូចជាមែកដែលគេបោះចោលទៅខាងក្រៅ ហើយស្វិតក្រៀម។ បន្ទាប់មក
គេរើសមែកទាំងនោះបោះទៅក្នុងភ្លើងឆេះអស់ទៅ។ 7បើអ្នករាល់គ្នាស្ថិតនៅជាប់នឹងខ្ញុំ
ហើយបើពាក្យខ្ញុំស្ថិតនៅជាប់នឹងអ្នករាល់គ្នាចូរទូលសុំអ្វីៗតាមតែអ្នករាល់គ្នា ប្រាថ្នាចង់បានចុះ
នោះអ្នករាល់គ្នាមុខតែបានទទួលជាមិនខាន។ 8ព្រះបិតារបស់ខ្ញុំសំដែងសិរីរុងរឿង ដោយអ្នករាល់គ្នាបង្កើតផលផ្លែបានច្រើន និង
ដោយអ្នករាល់គ្នាជាសិស្សរបស់ខ្ញុំមែន។9ខ្ញុំបានស្រឡាញ់អ្នករាល់គ្នា ដូចព្រះបិតាស្រឡាញ់ខ្ញុំដែរ។
ចូរទុកសេចក្ដីស្រឡាញ់របស់ខ្ញុំអោយស្ថិតនៅជាប់នឹងអ្នករាល់គ្នាចុះ។ 10បើអ្នករាល់គ្នាប្រតិបត្តិតាមបទបញ្ជាទាំងប៉ុន្មានរបស់ខ្ញុំ
អ្នករាល់គ្នាពិតជាទុកសេចក្ដីស្រឡាញ់របស់ខ្ញុំ អោយស្ថិតនៅជាប់នឹងអ្នករាល់គ្នាមែន ដូចខ្ញុំប្រតិបត្តិតាមបទបញ្ជាទាំងប៉ុន្មានរបស់ព្រះបិតា
ហើយទុកអោយសេចក្ដីស្រឡាញ់របស់ព្រះអង្គស្ថិតនៅជាប់នឹងខ្ញុំដែរ។ 11ខ្ញុំបាននិយាយសេចក្ដីទាំងនេះប្រាប់អ្នករាល់គ្នា
ដើម្បីអោយអំណររបស់ខ្ញុំស្ថិតនៅក្នុងអ្នករាល់គ្នា ហើយដើម្បីអោយអ្នករាល់គ្នាមានអំណរពេញលក្ខណៈ។ 12នេះជាបទបញ្ជារបស់ខ្ញុំ
ចូរអ្នករាល់គ្នាស្រឡាញ់គ្នាទៅវិញទៅមក ដូចខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ។13គ្មាននរណាមានសេចក្ដីស្រឡាញ់ខ្លាំងជាងអ្នកដែលស៊ូប្ដូរជីវិត

ដើម្បីមិត្តសំឡាញ់របស់ខ្លួននោះឡើយ។ 14បើអ្នករាល់គ្នាប្រព្រឹត្តតាមសេចក្តីដែលខ្ញុំបានបង្គាប់មក
អ្នករាល់គ្នាពិតជាមិត្តសំឡាញ់របស់ខ្ញុំមែន។ 15ខ្ញុំមិនចាត់ទុកអ្នករាល់គ្នាជាអ្នកបំរើទៀតទេ
ព្រោះអ្នកបំរើមិនយល់កិច្ចការដែលម្ចាស់របស់ខ្លួនប្រព្រឹត្តនោះឡើយ។ ខ្ញុំចាត់ទុកអ្នករាល់គ្នាជាមិត្តសំឡាញ់ ដ្បិតអ្វីៗដែលខ្ញុំបានឮពីព្រះបិតាមក
ខ្ញុំក៏បានប្រាប់អោយអ្នករាល់គ្នាដឹងហើយដែរ។16មិនមែនអ្នករាល់គ្នាទេដែលបានជ្រើសរើសខ្ញុំ គឺខ្ញុំទេតើដែលបានជ្រើសរើសអ្នករាល់គ្នា
ហើយបានតែងតាំងអ្នករាល់គ្នាអោយទៅ និង បង្កើតផល ព្រមទាំងអោយផលរបស់អ្នករាល់គ្នានៅស្ថិតស្ថេរ។
ដូច្នេះអ្វីៗដែលអ្នករាល់គ្នាទូលសូមពីព្រះបិតាក្នុងនាមខ្ញុំ
ព្រះអង្គនឹងប្រទានអោយអ្នករាល់គ្នាពុំខាន។ 17រីឯសេចក្តីដែលខ្ញុំបង្គាប់អ្នករាល់គ្នានោះគឺត្រូវស្រឡាញ់គ្នាទៅវិញទៅមក»។ 18«ប្រសិនបើមនុស្ស
លោកស្អប់អ្នករាល់គ្នា ចូរដឹងថា គេបានស្អប់ខ្ញុំមុនស្អប់អ្នករាល់គ្នាទៅទៀត។ 19ប្រសិនបើអ្នករាល់គ្នាកើតមកពីលោកីយ៍
នោះលោកីយ៍មុខជាស្រឡាញ់អ្នករាល់គ្នា ព្រោះអ្នករាល់គ្នានៅខាងគេ។ ប៉ុន្តែ ខ្ញុំបានយកអ្នករាល់គ្នាចេញពីចំណោមលោកីយ៍មក
ហើយអ្នករាល់គ្នាមិនកើតពីលោកីយ៍ទេ ហេតុនេះហើយបានជាលោកីយ៍ស្អប់អ្នករាល់គ្នា។ 20ចូរនឹកចាំពាក្យដែលខ្ញុំបាននិយាយប្រាប់អ្នករាល់គ្នាថា
"អ្នកបំរើមិនធំជាងម្ចាស់ឡើយ"។ ប្រសិនបើគេបៀតបៀនខ្ញុំ គេមុខជាបៀតបៀនអ្នករាល់គ្នា ប្រសិនបើគេប្រតិបត្តិតាមពាក្យខ្ញុំ
គេមុខជាប្រតិបត្តិតាមពាក្យរបស់អ្នករាល់គ្នាដែរ។ 21ប៉ុន្តែ គេប្រព្រឹត្តអំពើទាំងនោះចំពោះអ្នករាល់គ្នា ព្រោះតែនាមខ្ញុំ
ហើយគេពុំបានស្គាល់ព្រះអង្គដែលបានចាត់ខ្ញុំអោយមកទេ។ 22ប្រសិនបើខ្ញុំមិនបានមកក្នុងលោកនេះ ហើយមិនបាននិយាយប្រាប់គេទេ
គេគ្មានជាប់បាបអ្វីសោះ។ ប៉ុន្តែ ឥឡូវនេះគេគ្មានអ្វីដោះសារអំពីបាបរបស់ខ្លួនឡើយ។ 23អ្នកណាស្អប់ខ្ញុំ

អ្នកនោះក៏ស្អប់ព្រះបិតារបស់ខ្ញុំដែរ។ 24ប្រសិនបើខ្ញុំមិនបានធ្វើកិច្ចការ ក្នុងចំណោមពួកគេជាកិច្ចការដែលគ្មាននរណាម្នាក់បានធ្វើទេនោះ
គេមុខជាមិនជាប់បាបអ្វីឡើយ តែឥឡូវនេះគេបានឃើញ
ហើយស្អប់ទាំងខ្ញុំស្អប់ទាំងព្រះបិតាខ្ញុំទៀតផង25គឺស្របតាមសេចក្ដីដែលមានចែងទុកក្នុងវិន័យរបស់គេថា
"គេបានស្អប់ខ្ញុំដោយគ្មានមូលហេតុអ្វីឡើយ"។ 26រីឯព្រះដ៏ជួយការពារ ដែលខ្ញុំនឹងចាត់ពីព្រះបិតាអោយមករកអ្នករាល់គ្នា
គឺជាព្រះវិញ្ញាណដែលសំដែងសេចក្ដីពិត ព្រះអង្គចេញពីព្រះបិតាមក។ កាលណាព្រះអង្គយាងមកដល់
ទ្រង់នឹងធ្វើជាបន្ទាល់អំពីខ្ញុំ 27ហើយអ្នករាល់គ្នាក៏ធ្វើជាបន្ទាល់អំពីខ្ញុំដែរ ពីព្រោះអ្នករាល់គ្នានៅជាមួយខ្ញុំ តាំងពីដើមរៀងមក។

# JOHN - យ៉ូហាន 16

1ខ្ញុំនិយាយសេចក្ដីទាំងនេះ ប្រាប់អ្នករាល់គ្នា ដើម្បីកុំអោយអ្នករាល់គ្នារវាតចិត្តងាកចេញពីជំនឿ។ 2គេនឹងបណ្ដេញអ្នករាល់គ្នាចេញពីសាលាប្រជុំ
ហើយនៅថ្ងៃក្រោយ អស់អ្នកដែលសម្លាប់អ្នករាល់គ្នានឹកស្មានថាខ្លួនគោរពបំរើព្រះជាម្ចាស់។ 3គេធ្វើដូច្នេះ មកពីគេមិនបានស្គាល់ព្រះបិតា
ហើយក៏មិនស្គាល់ខ្ញុំផង។ 4ខ្ញុំនិយាយសេចក្ដីនេះប្រាប់អ្នករាល់គ្នា លុះដល់ពេលកំណត់ អ្នករាល់គ្នានឹងនឹកឃើញថា ខ្ញុំបានប្រាប់អ្នករាល់
គ្នារួចស្រេចហើយ។ កាលពីមុន ខ្ញុំមិនបាននិយាយប្រាប់អ្នករាល់គ្នាទេ ពីព្រោះកាលណោះខ្ញុំនៅជាមួយអ្នករាល់ គ្នានៅឡើយ»។ 5«ឥឡូវនេះ
ខ្ញុំទៅឯព្រះអង្គដែលបានចាត់ខ្ញុំអោយមក ហើយក្នុងចំណោមអ្នករាល់គ្នា គ្មាននរណាសួរខ្ញុំថា"តើលោកអញ្ជើញទៅណា"ឡើយ។ 6ពេលឮខ្ញុំនិយាយដូច្នេះ
អ្នករាល់គ្នាព្រួយចិត្តខ្លាំងណាស់។ 7ប៉ុន្តែ ខ្ញុំសូមប្រាប់អ្នករាល់គ្នាតាមត្រង់ថា បើខ្ញុំទៅ ទើបមានប្រយោជន៍ដល់អ្នករាល់គ្នា។

បើខ្ញុំមិនទៅទេព្រះដ៏ជួយការពារមិនយាងមករកអ្នករាល់គ្នាឡើយ។ ផ្ទុយទៅវិញ បើខ្ញុំទៅ
ខ្ញុំនឹងចាត់ព្រះអង្គអោយមករកអ្នករាល់គ្នា។ 8កាលណាព្រះអង្គយាងមកដល់ ព្រះអង្គនឹងបញ្ជាក់អោយមនុស្សលោកដឹងថា គេយល់ខុសអំពីបាប
អំពីសេចក្ដីសុចរិត និង អំពីការកាត់ទោស។ 9គេយល់ខុសអំពីបាប ព្រោះគេមិនជឿលើខ្ញុំ 10អំពីសេចក្ដីសុចរិតព្រោះខ្ញុំទៅឯព្រះបិតា
ហើយអ្នករាល់គ្នានឹងមិនឃើញខ្ញុំទៀតទេ 11អំពីការកាត់ទោស
ព្រោះចៅហ្វាយរបស់មនុស្សលោកនេះបានទទួលទោសរួចហើយ។ 12ខ្ញុំមានសេចក្ដីឯទៀតៗជាច្រើន ដែលត្រូវនិយាយប្រាប់អ្នករាល់គ្នា
តែអ្នករាល់គ្នាពុំអាចទទួលនៅពេលនេះបានទេ។ 13កាលណាព្រះវិញ្ញាណនៃសេចក្ដីពិតយាងមកដល់
ព្រះអង្គនឹងណែនាំអ្នករាល់គ្នាអោយស្គាល់សេចក្ដីពិតគ្រប់ជំពូក ដ្បិតសេចក្ដីផ្សេងៗដែលព្រះអង្គថ្លែង មិនចេញមកពីព្រះអង្គផ្ទាល់ទេ
គឺព្រះអង្គថ្លែងតែសេចក្ដីណាដែលទ្រង់ព្រះសណ្ដាប់ឮ ព្រមទាំងមានព្រះបន្ទូលប្រាប់អោយអ្នករាល់គ្នាដឹង
អំពីហេតុការណ៍ដែលត្រូវកើតមាននៅថ្ងៃមុខផង។14ព្រះអង្គនឹងសំដែងសិរីរុងរឿងរបស់ខ្ញុំ ព្រោះព្រះអង្គទទួលសេចក្ដីទាំងអស់ពីខ្ញុំ
យកមកប្រាប់អ្នករាល់គ្នា។ 15អ្វីៗដែលព្រះបិតាមានទាំងប៉ុន្មានសុទ្ធតែជារបស់ខ្ញុំទាំងអស់។ ហេតុនេះហើយបានជាខ្ញុំពោលថា
ព្រះអង្គទទួលសេចក្ដីទាំងអស់ពីខ្ញុំយកមកប្រាប់អ្នករាល់គ្នា»។ 16«បន្ដិចទៀត អ្នករាល់គ្នាលែងឃើញខ្ញុំហើយ តែបន្ដិចក្រោយមកទៀត
អ្នករាល់គ្នានឹងឃើញខ្ញុំវិញ»។ 17សិស្សខ្លះសួរគ្នាថា៖ «ព្រះអង្គមានព្រះបន្ទូលថា "បន្ដិចទៀត អ្នករាល់គ្នាលែងឃើញខ្ញុំ តែបន្ដិចក្រោយមកទៀត
អ្នករាល់គ្នានឹងឃើញខ្ញុំវិញ" ហើយថា "ខ្ញុំនឹងទៅឯព្រះបិតា" តើព្រះអង្គចង់មានព្រះបន្ទូលអំពីអ្វី?»។18គេសួរគ្នាទៀតថា៖
«ព្រះអង្គមានព្រះបន្ទូលថា "បន្ដិចទៀត"នោះ តើព្រះអង្គចង់មានព្រះបន្ទូលអំពីអ្វីយើងមិនយល់សោះ!»។ 19ព្រះយេស៊ូជ្រាបថាគេចង់សួរព្រះអង្គ

ទើបទ្រង់មានព្រះបន្ទូលទៅគេថា៖ «អ្នករាល់គ្នាសួរគ្នាទៅវិញទៅមក ចង់ដឹងអំពីពាក្យដែលខ្ញុំប្រាប់អ្នករាល់គ្នាថាបន្ដិចទៀត អ្នករាល់គ្នាលែងឃើញខ្ញុំ
តែបន្ដិចក្រោយមកទៀត អ្នករាល់គ្នានឹងឃើញខ្ញុំវិញ"។ 20ខ្ញុំសុំប្រាប់អោយអ្នករាល់គ្នាដឹងច្បាស់ថា អ្នករាល់គ្នានឹងទ្រហោយំសោកសង្រេង
តែមនុស្សលោកនឹងអរសប្បាយ អ្នករាល់គ្នានឹងកើតទុក្ខព្រួយ ប៉ុន្តែ
ទុក្ខព្រួយរបស់អ្នករាល់គ្នានឹងប្រែទៅជាអំណរសប្បាយវិញ។21ពេលស្ដ្រីម្នាក់ហៀបឆ្លងទន្លេ នាងតែងព្រួយចិត្តណាស់
ព្រោះដល់ពេលដែលនាងត្រូវឈឺចាប់ លុះដល់សំរាលកូនរួចហើយ នាងក៏ភ្លេចការឈឺចាប់ទាំងប៉ុន្មានអស់រលីង នាងសប្បាយចិត្ត
ព្រោះមានមនុស្សម្នាក់កើតមកក្នុងលោកនេះ។ 22អ្នករាល់គ្នាក៏ដូច្នោះដែរ ឥឡូវនេះអ្នករាល់គ្នាព្រួយចិត្ត ប៉ុន្តែ ខ្ញុំនឹងជួបអ្នករាល់គ្នាសាជាថ្មី
អ្នករាល់គ្នានឹងសប្បាយចិត្ត ហើយគ្មាននរណាដកយកអំណរសប្បាយចេញពីចិត្តអ្នករាល់គ្នាបានឡើយ។ 23នៅពេលនោះ
អ្នករាល់គ្នាលែងសួរអ្វីពីខ្ញុំទៀតហើយ។ ខ្ញុំសុំប្រាប់អោយអ្នករាល់គ្នាដឹងច្បាស់ថា អ្វីៗដែលអ្នករាល់គ្នាទូលសូមព្រះបិតាក្នុងនាមខ្ញុំ
ព្រះអង្គមុខជាប្រទានអោយអ្នករាល់គ្នាមិនខាន។ 24មកទល់ពេលនេះ អ្នករាល់គ្នាពុំទាន់បានទូលសូមអ្វីក្នុងនាមខ្ញុំទេ ចូរទូលសូមទៅ
អ្នករាល់គ្នានឹងបានទទួល ហើយអ្នករាល់គ្នានឹងមានអំណរពេញលក្ខណៈ»។ 25«ខ្ញុំបាននិយាយប្រាប់អ្នករាល់គ្នា អំពីសេចក្ដីទាំងនេះ ដោយប្រើប្រស្នា។
បន្ដិចទៀត ខ្ញុំនឹងនិយាយប្រាប់អ្នករាល់គ្នាយ៉ាងច្បាស់ៗអំពីព្រះបិតា ខ្ញុំមិនប្រើប្រស្នាទៀតទេ។26នៅគ្រានោះ កាលណាអ្នករាល់គ្នាទូលសូមអ្វីៗពីព្រះបិតា
ក្នុងនាមខ្ញុំ ខ្ញុំមិនប្រាប់អ្នករាល់គ្នាថា ខ្ញុំនឹងអង្វរព្រះអង្គអោយអ្នករាល់គ្នាឡើយ 27ដ្បិតព្រះបិតាមានព្រះហឫទ័យស្រឡាញ់អ្នករាល់គ្នា
ព្រោះអ្នករាល់គ្នាបានស្រឡាញ់ខ្ញុំ ហើយជឿថាខ្ញុំចេញពីព្រះជាម្ចាស់មក។ 28ខ្ញុំបានចេញពីព្រះបិតាមកក្នុងលោកនេះ ហើយឥឡូវ
ខ្ញុំចេញពីលោកនេះទៅឯព្រះបិតាវិញ»។29ពួកសិស្សទូលព្រះអង្គថា៖ «ឥឡូវនេះ ព្រះអង្គមានព្រះបន្ទូលយ៉ាងច្បាស់ៗមកយើងខ្ញុំ

ហើយព្រះអង្គមិនប្រើប្រស្នាទៀតទេ។ 30ឥឡូវនេះ យើងខ្ញុំដឹងថាព្រះអង្គឈ្វេងយល់គ្រប់សេចក្ដីទាំងអស់ មិនបាច់មាននរណាទូលសួរព្រះអង្គឡើយ។
ហេតុនេះហើយបានជាយើងខ្ញុំជឿថា ព្រះអង្គចេញមកពីព្រះជាម្ចាស់មែន»។ 31ព្រះយេស៊ូមានព្រះបន្ទូលតបទៅគេថា៖
«ឥឡូវនេះអ្នករាល់គ្នាជឿមែនឬ! 32ប៉ុន្ដែពេលកំណត់មកដល់គឺពេលនេះហើយ អ្នករាល់គ្នានឹងត្រូវខ្ចាត់ខ្ចាយ ម្នាក់ៗទៅតាមផ្លូវរៀងៗខ្លួន
បោះបង់ចោលខ្ញុំអោយនៅម្នាក់ឯង។ តាមពិត ខ្ញុំមិននៅម្នាក់ឯងទេ មានព្រះបិតាគង់នៅជាមួយខ្ញុំ។ 33ខ្ញុំនិយាយប្រាប់ដូច្នេះ
ដើម្បីអោយអ្នករាល់គ្នាបានប្រកបដោយសេចក្ដីសុខសាន្ដរួមជាមួយខ្ញុំ។ អ្នករាល់គ្នាជួបនឹងទុក្ខវេទនានៅក្នុងលោក ប៉ុន្ដែចូរមានសង្ឃឹមឡើង!
ខ្ញុំបានឈ្នះលោកនេះហើយ»។

# JOHN - យ៉ូហាន 17

1កាលព្រះយេស៊ូមានព្រះបន្ទូលដូច្នោះហើយ ព្រះអង្គងើបព្រះភ័ក្ត្រទតទៅលើមេឃមានព្រះបន្ទូលថា៖ «បពិត្រព្រះបិតា ឥឡូវនេះដល់ពេលកំណត់ហើយ
សូមសំដែងសិរីរុងរឿងរបស់បុត្រឡើង ដើម្បីអោយបុត្រសំដែង សិរីរុងរឿងរបស់ព្រះបិតាដែរ។ 2ព្រះអង្គបានប្រទានអោយបុត្រមានអំណាច
លើមនុស្សទាំងអស់ ដើម្បីអោយបុត្រផ្ដល់ជីវិតអស់កល្បជានិច្ច ដល់អស់អ្នកដែលព្រះអង្គប្រទានមកបុត្រ។ 3រីឯជីវិតអស់កល្បជានិច្ចនោះ
គឺអោយគេស្គាល់ព្រះអង្គ ដែលជាព្រះជាម្ចាស់ ដ៏ពិតតែមួយគត់ និង អោយគេស្គាល់ព្រះយេស៊ូគ្រិស្ដ
ដែលព្រះអង្គចាត់អោយមក។ 4ទូលបង្គំបានសំដែងសិរីរុងរឿងរបស់ព្រះអង្គនៅលើផែនដី
ហើយទូលបង្គំក៏បានបង្ហើយកិច្ចការដែលព្រះអង្គបញ្ជាអោយទូលបង្គំធ្វើនោះចប់សព្វគ្រប់ដែរ។ 5ព្រះបិតាអើយ ឥឡូវនេះ

សូមលើកតម្កើងទូលបង្គំអោយមានសិរីរុងរឿងនៅជិតព្រះអង្គ គឺសិរីរុងរឿងដែល ទូលបង្គំធ្លាប់មាននៅជិតព្រះអង្គ
តាំងពីមុនកំណើតពិភពលោកមក។ 6ទូលបង្គំបានសំដែងព្រះនាមរបស់ព្រះអង្គអោយអស់អ្នក
ដែលព្រះអង្គញែកចេញពីលោកនេះប្រទានមកទូលបង្គំស្គាល់ហើយ។ អ្នកទាំងនោះនៅក្រោមការគ្រប់គ្រងរបស់ព្រះអង្គ ព្រះអង្គប្រទានគេមកអោយទូលបង្គំ
ហើយគេបានប្រតិបត្តិតាមព្រះបន្ទូលរបស់ព្រះអង្គ។ 7ឥឡូវនេះ អ្នកទាំងនោះដឹងថា អ្វីៗដែលព្រះអង្គប្រទានមកទូលបង្គំ
សុទ្ធតែមកពីព្រះអង្គទាំងអស់ 8ដ្បិតទូលបង្គំបានប្រគល់ព្រះបន្ទូលដែលព្រះអង្គប្រទានមកទូលបង្គំទៅអោយគេ គេបានទទួលព្រះបន្ទូលទាំងនោះ
ហើយទទួលស្គាល់យ៉ាងច្បាស់ថា ទូលបង្គំបានចេញមកពីព្រះអង្គមែន
ព្រមទាំងជឿថាព្រះអង្គបានចាត់ទូលបង្គំអោយមកទៀតផង។ 9ទូលបង្គំសូមអង្វរព្រះអង្គ អោយអ្នកទាំងនោះ
ទូលបង្គំមិនអង្វរព្រះអង្គអោយមនុស្សលោកឡើយ គឺអង្វរអោយតែអស់អ្នកដែលព្រះអង្គប្រទានមកទូលបង្គំប៉ុណ្ណោះ
ព្រោះអ្នកទាំងនោះនៅក្រោមការគ្រប់គ្រងរបស់ព្រះអង្គ។ 10អ្វីៗជារបស់ព្រះអង្គក៏ជារបស់ទូលបង្គំ ហើយអ្វីៗជារបស់ទូលបង្គំក៏ជារបស់ព្រះអង្គដែរ។
ទូលបង្គំសំដែងសិរីរុងរឿងក្នុងអ្នកទាំងនោះ។ 11ទូលបង្គំមិននៅក្នុងលោកនេះទៀតទេ រីឯអ្នកទាំងនោះស្ថិតនៅក្នុងលោកនៅឡើយ
ហើយទូលបង្គំទៅឯព្រះអង្គវិញ។ ឱព្រះបិតាដ៏វិសុទ្ធអើយ! សូមថែរក្សាអ្នកទាំងនោះ ដោយព្រះនាមព្រះអង្គផង
គឺព្រះនាមនេះហើយដែលព្រះអង្គបានប្រទានមកទូលបង្គំ ដើម្បីអោយគេរួមគ្នាជាអង្គតែមួយ
ដូចយើងជាអង្គតែមួយដែរ។ 12កាលទូលបង្គំនៅជាមួយអ្នកទាំងនោះ ទូលបង្គំបានថែរក្សាគេ ដោយព្រះនាមដែលព្រះអង្គបានប្រទានមកទូលបង្គំ។
ទូលបង្គំបានការពារគេ ហើយគ្មាននរណាត្រូវវិនាសបាត់បង់ឡើយ លើកលែងតែម្នាក់ដែលត្រូវវិនាស
ស្របតាមសេចក្ដីដែលមានចែងទុកក្នុងគម្ពីរប៉ុណ្ណោះ។13ឥឡូវនេះ ទូលបង្គំទៅឯព្រះអង្គហើយទូលបង្គំនិយាយដូច្នេះ

ពេលទូលបង្គំនៅក្នុងលោកនេះនៅឡើយ
ដើម្បីអោយគេមានអំណររបស់ទូលបង្គំជាអំណរដ៏ពេញលក្ខណៈ។ 14ទូលបង្គំបានប្រទានព្រះបន្ទូលរបស់ព្រះអង្គអោយគេ
តែមនុស្សលោកស្អប់គេពីព្រោះគេមិនកើតពីនិស្ស័យ លោកីយ៍ទេដូចជាទូលបង្គំមិនកើតពីនិស្ស័យលោកីយ៍នេះដែរ។ 15ទូលបង្គំមិនអង្វរព្រះអង្គ
អោយយកគេចេញពីលោកនេះឡើយគឺសូមទ្រង់មេត្តាការពារគេពីអំណាចមារកំណាចវិញ។ 16គេមិនកើតពីនិស្ស័យលោកីយ៍ទេ
ដូចទូលបង្គំមិនកើតពីនិស្ស័យលោកីយ៍នេះដែរ។ 17សូមប្រោសគេអោយវិសុទ្ធ ដោយសារសេចក្ដីពិត
គឺព្រះបន្ទូលរបស់ព្រះអង្គនោះហើយជាសេចក្ដីពិត។18ទូលបង្គំចាត់គេអោយទៅក្នុងលោក
ដូចព្រះអង្គបានចាត់ទូលបង្គំអោយមកក្នុងលោកដែរ។ 19រីឯទូលបង្គំវិញ ទូលបង្គំបូជាជីវិត
ថ្វាយព្រះអង្គជាប្រយោជន៍ដល់គេដើម្បីអោយគេបានវិសុទ្ធដោយសារសេចក្ដីពិត។ 20ទូលបង្គំមិនអង្វរព្រះអង្គអោយតែអ្នកទាំងនេះប៉ុណ្ណោះទេ
គឺអង្វរអោយអស់អ្នកជឿលើទូលបង្គំ តាមរយៈពាក្យដែលអ្នកទាំងនេះថ្លែងប្រាប់ផងដែរ 21សូមអោយគេទាំងអស់គ្នារួមជាអង្គតែមួយ។ ឱព្រះបិតាអើយ!
ព្រះអង្គស្ថិតនៅជាប់នឹងទូលបង្គំ ហើយទូលបង្គំស្ថិតនៅជាប់នឹងព្រះអង្គយ៉ាងណា សូមអោយគេរួមគ្នាជាអង្គតែមួយនៅក្នុងយើងយ៉ាងនោះដែរ
ដើម្បីអោយមនុស្សលោកជឿថា ព្រះអង្គបានចាត់ទូលបង្គំអោយមកមែន។22រីឯសិរីរុងរឿងដែលព្រះអង្គប្រទានមកទូលបង្គំ
ទូលបង្គំបានប្រគល់ទៅអោយគេហើយ ដើម្បីអោយគេរួមគ្នាជាអង្គតែមួយ ដូចយើងជាអង្គតែមួយដែរ 23គឺអោយទូលបង្គំនៅក្នុងគេ
ព្រះអង្គនៅក្នុងទូលបង្គំ ដើម្បីអោយគេរួមគ្នាជាអង្គតែមួយពិតប្រាកដមែន ហើយមនុស្សលោកទទួលស្គាល់ថា ព្រះអង្គបានចាត់ទូលបង្គំអោយមក
ព្រមទាំងទទួលស្គាល់ថា ព្រះអង្គស្រឡាញ់គេ ដូចព្រះអង្គស្រឡាញ់ទូលបង្គំដែរ។ 24ឱព្រះបិតាអើយ!

ទូលបង្គំចង់អោយអស់អ្នកដែលព្រះអង្គប្រទានមកទូលបង្គំ បាននៅជាមួយទូលបង្គំ ឯកន្លែងដែលទូលបង្គំនៅនោះដែរ
ដើម្បីអោយគេឃើញសិរីរុងរឿងដែលព្រះអង្គប្រទានមកទូលបង្គំ ព្រោះព្រះអង្គបានស្រឡាញ់ទូលបង្គំ
តាំងពីមុនកំណើតពិភពលោកមកម៉្លេះ។ 25ឱព្រះបិតាដ៏សុចរិតអើយ! មនុស្សលោកពុំបានស្គាល់ព្រះអង្គទេ រីឯទូលបង្គំវិញ ទូលបង្គំស្គាល់ព្រះអង្គ
ហើយអ្នកទាំងនេះក៏ទទួលស្គាល់ថាព្រះអង្គបានចាត់ទូលបង្គំអោយមកមែន។26ទូលបង្គំបានសំដែងព្រះនាមព្រះអង្គអោយគេស្គាល់
ហើយទូលបង្គំនឹងសំដែងអោយគេរឹតតែស្គាល់ថែមទៀត ដើម្បីអោយសេចក្ដីស្រឡាញ់របស់ព្រះអង្គចំពោះទូលបង្គំស្ថិតនៅក្នុងគេ
ហើយទូលបង្គំក៏ស្ថិតនៅក្នុងគេដែរ»។

# JOHN - យ៉ូហាន 18

1កាលព្រះយេស៊ូមានព្រះបន្ទូលដូច្នោះរួចហើយ ព្រះអង្គយាងទៅខាងនាយជ្រោះកេដ្រូន ជាមួយពួកសិស្ស។ នៅទីនោះ មានសួនឧទ្យានមួយ
ព្រះអង្គយាងចូលទៅក្នុងសួនឧទ្យាននោះជាមួយពួកសិស្ស។ 2រីឯយូដាសជាអ្នកក្បត់ព្រះអង្គក៏ស្គាល់កន្លែងនោះដែរ ព្រោះជាកន្លែងដែលព្រះយេស៊ូ និង
ពួកសិស្សធ្លាប់ជួបជុំគ្នាជាញឹកញាប់។ 3ដូច្នេះយូដាសនាំកងទាហាន និង កងរក្សាព្រះវិហារចូលមក ទាំងកាន់ចន្លុះកាន់គោមកាន់អាវុធផង។
ពួកនាយកបូជាចារ្យ និង ពួកខាងគណៈផារីស៊ី បានចាត់អ្នកទាំងនោះអោយមក។ 4ព្រះយេស៊ូឈ្វេងយល់ហេតុការណ៍ទាំងប៉ុន្មានដែលត្រូវកើតដល់ព្រះអង្គ
ព្រះអង្គក៏យាងទៅមុខ មានព្រះបន្ទូលសួរគេថា៖ «អ្នករាល់គ្នាមករកនរណា?»។ 5គេទូលព្រះអង្គថា៖ «រកឈ្មោះយេស៊ូជាអ្នកភូមិណាសារ៉ែត»។
ព្រះអង្គមានព្រះបន្ទូលទៅគេថា៖ «គឺខ្ញុំហ្នឹងហើយ»។ រីឯយូដាសជាអ្នកក្បត់ព្រះអង្គក៏នៅជាមួយពួកគេដែរ។ 6កាលព្រះយេស៊ូមានព្រះបន្ទូលទៅគេថា

"គឺខ្ញុំហ្នឹងហើយ" ដូច្នេះគេថយក្រោយ ហើយដួលដាច់ផ្ងារទាំងអស់គ្នា។ 7ព្រះយេស៊ូមានព្រះបន្ទូលសួរគេម្ដងទៀតថា៖ «អ្នករាល់គ្នាមករកនរណា?»
គេទូលថា៖ «រកឈ្មោះយេស៊ូ ជាអ្នកភូមិណាសារ៉ែត»។8ព្រះយេស៊ូមានព្រះបន្ទូលទៅគេថា៖ «ខ្ញុំបានប្រាប់អ្នករាល់គ្នាថា ខ្ញុំហ្នឹងហើយ
បើអ្នករាល់គ្នាមករកខ្ញុំ ទុកអោយអ្នកទាំងនេះចេញទៅចុះ»។9ព្រះអង្គមានព្រះបន្ទូលដូច្នេះ ស្របតាមសេចក្ដីដែលព្រះអង្គបានថ្លែងទុកមកថា
"អស់អ្នកដែលព្រះអង្គប្រទានមកទូលបង្គំ ឥតមាននរណាម្នាក់ត្រូវវិនាសឡើយ"
»។ 10លោកស៊ីម៉ូនពេត្រុសមានដាវមួយគាត់ហូតកាប់អ្នកបំរើម្នាក់របស់លោកមហាបូជាចារ្យដាច់ស្លឹកត្រចៀកស្ដាំ
អ្នកបំរើនោះឈ្មោះម៉ាលកុស។ 11ព្រះយេស៊ូមាន ព្រះបន្ទូលទៅលោកពេត្រុសថា៖ «ស៊កដាវទៅក្នុងស្រោមវិញទៅ
តើអ្នកមិនចង់អោយខ្ញុំផឹកពីពែងនៃទុក្ខលំបាក ដែលព្រះបិតាប្រទានមកខ្ញុំទេឬ?»។ 12ពួកទាហាន និង មេបញ្ជាការរបស់គេ
ព្រមទាំងកងរក្សាព្រះវិហាររបស់ជនជាតិយូដា នាំគ្នាចាប់ព្រះយេស៊ូហើយចងព្រះអង្គ។ 13គេនាំព្រះអង្គទៅជួបលោកអាណាមុនគេ
ព្រោះលោកត្រូវជាឪពុកក្មេករបស់លោកកៃផាស ដែលកាន់តំណែងជាមហាបូជាចារ្យនៅឆ្នាំនោះ 14គឺលោកកៃផាសនេះហើយ
ដែលបានអោយយោបល់ទៅជនជាតិយូដាថា "គួរអោយមនុស្សតែម្នាក់ស្លាប់
ជាប្រយោជន៍ដល់ប្រជារាស្ដ្រ"។ 15លោកស៊ីម៉ូនពេត្រុសដើរតាមព្រះយេស៊ូជាមួយសិស្សម្នាក់ទៀត លោកមហាបូជាចារ្យស្គាល់សិស្សម្នាក់នោះ
ហេតុនេះហើយបានជាគាត់អាចចូលជាមួយព្រះយេស៊ូ ទៅទីធ្លាខាងក្នុងដំណាក់របស់លោកមហាបូជាចារ្យ។ 16រីឯលោកពេត្រុសវិញ
គាត់ឈរនៅខាងក្រៅក្បែរមាត់ទ្វារ។ សិស្សដែលលោកមហាបូជាចារ្យស្គាល់នោះ ក៏ចេញមកនិយាយជាមួយស្ដ្រីម្នាក់ជាអ្នកយាមទ្វារ
ហើយនាំលោកពេត្រុសចូលទៅខាងក្នុងដែរ។ 17ស្ដ្រីបំរើជាអ្នកយាមទ្វារនិយាយទៅកាន់លោកពេត្រុសថា៖

«អ្នកឯងជាសិស្សរបស់អ្នកនោះដែរមែនឬ?»។ លោកពេត្រុសតបថា៖ «ទេ! មិនមែនទេ!»។ 18ពួកអ្នកបំរើរបស់លោកមហាបូជាចារ្យ និង
កងរក្សាព្រះវិហារនាំគ្នាបង្កាត់ភ្លើងអាំងព្រោះពេលនោះរងាណាស់។
លោកពេត្រុសក៏នៅអាំងភ្លើងជាមួយពួកគេដែរ។ 19លោកមហាបូជាចារ្យសួរព្រះយេស៊ូអំពីពួកសិស្សរបស់ព្រះអង្គ និង
អំពីសេចក្ដីដែលព្រះអង្គបង្រៀន។20ព្រះយេស៊ូមានព្រះបន្ទូលតបទៅលោកវិញថា៖ «ខ្ញុំបាននិយាយ ដោយចេញមុខប្រាប់មនុស្សលោក
ខ្ញុំតែងបង្រៀននៅក្នុងសាលាប្រជុំ និង នៅក្នុងព្រះវិហារ ជាកន្លែងដែលជនជាតិយូដាទាំងអស់ជួបជុំគ្នា
គឺឥតនិយាយក្នុងទីលាក់កំបាំងទេ។ 21ហេតុដូចម្ដេចបានជាលោកសួរខ្ញុំ? សូមលោកសួរអស់អ្នកដែលបានឮសេចក្ដីខ្ញុំនិយាយនោះទៅ
ដ្បិតគេសុទ្ធតែដឹងអំពីអ្វីៗដែលខ្ញុំបាននិយាយ»។ 22ពេលឮព្រះយេស៊ូមានព្រះបន្ទូលដូច្នោះ ទាហានម្នាក់ក្នុងកងរក្សាព្រះវិហារដែលឈរនៅក្បែរនោះ
ទះកំផ្លៀងព្រះអង្គទាំងពោលថា៖
«ម្ដេចក៏អ្នកឯងហ៊ានឆ្លើយរបៀបនេះទៅលោកមហាបូជាចារ្យ!»។23ព្រះយេស៊ូមានព្រះបន្ទូលតបទៅទាហាននោះវិញថា៖ «បើខ្ញុំនិយាយខុសឆ្គង
សុំប្រាប់មើល៍! តើមានឆ្គងត្រង់ណា! តែបើខ្ញុំនិយាយត្រឹមត្រូវ ម្ដេចក៏អ្នកវាយខ្ញុំ?»។ 24ពេលនោះលោកអាណបញ្ជូនព្រះអង្គ
ទាំងជាប់ចំណងទៅលោកកៃផាសជាមហាបូជាចារ្យ។ 25លោកស៊ីម៉ូនពេត្រុសអាំងភ្លើងនៅទីនោះ។ មានគេសួរលោកថា៖
«អ្នកឯងជាសិស្សរបស់អ្នកនោះដែរមែនឬ?»។ លោកពេត្រុសប្រកែកថា៖ «ទេ!
មិនមែនទេ!»។ 26មានអ្នកបំរើរបស់មហាបូជាចារ្យម្នាក់ត្រូវជាបងប្អូននឹងអ្នក ដែលលោកពេត្រុសកាប់ដាច់ស្លឹកត្រចៀក ពោលថា៖
«ខ្ញុំក៏បានឃើញអ្នកឯងនៅក្នុងសួនជាមួយគាត់ដែរ!»។ 27លោកពេត្រុសប្រកែកសាជាថ្មីម្ដងទៀត។ រំពេចនោះ

ស្រាប់តែមាន់រងាវឡើង។ 28បន្ទាប់មក គេបណ្ដើរព្រះយេស៊ូចេញពីដំណាក់លោកកៃផាស ទៅបន្ទាយរបស់លោកទេសាភិបាល។ ពេលនោះ
ភ្លឺស្រាងៗហើយ។ ជនជាតិយូដាពុំបានចូលក្នុងបន្ទាយទេ ព្រោះគេខ្លាចមានបាប
នាំអោយធ្វើពិធីជប់លៀងក្នុងឱកាសបុណ្យចម្លងមិនបាន។ 29ដូច្នេះលោកពីឡាតចេញមកជួបពួកគេសួរថា៖
«តើអ្នករាល់គ្នាចោទប្រកាន់អ្នកនេះអំពីរឿងអ្វី?»។ 30គេជំរាបលោកថា៖ «ប្រសិនបើគាត់មិនបានប្រព្រឹត្តអំពើទុច្ចរិតទេ
យើងខ្ញុំនាំគាត់មកជូនលោកធ្វើអ្វី!»។ 31លោកពីឡាតមានប្រសាសន៍ទៅគេថា៖ «ចូរអ្នករាល់គ្នាយកគាត់ទៅវិនិច្ឆ័យទោស
តាមវិន័យរបស់អ្នករាល់គ្នាទៅ»។ ជនជាតិយូដាជំរាបទៅលោកវិញថា៖ «យើងខ្ញុំគ្មានសិទ្ធិប្រហារជីវិតអ្នកណាសោះឡើយ»។ 32គេនិយាយដូច្នេះ
ស្របតាមសេចក្ដីដែលព្រះយេស៊ូមានព្រះបន្ទូលអំពីរបៀបព្រះអង្គត្រូវសោយទិវង្គត។33លោកពីឡាតចូលទៅក្នុងបន្ទាយវិញ រួចហៅព្រះយេស៊ូមកសួរថា៖
«តើអ្នកជាស្ដេចរបស់ជនជាតិយូដាមែនឬ?»។ 34ព្រះយេស៊ូមានព្រះបន្ទូលតបថា៖ «លោកមានប្រសាសន៍ដូច្នេះ តើមកពីគំនិតរបស់លោកផ្ទាល់ ឬ
មានអ្នកផ្សេងទៀតជំរាបលោក?»។ 35លោកពីឡាតតបវិញថា៖ «ខ្ញុំមិនមែនជាជនជាតិយូដាទេ! គឺជនជាតិរបស់អ្នក និង ពួកនាយកបូជាចារ្យទេតើ
ដែលបានបញ្ជូនអ្នកមកខ្ញុំ តើអ្នកបានធ្វើអ្វី?»។ 36ព្រះយេស៊ូមានព្រះបន្ទូលតបថា៖ «រាជ្យរបស់ខ្ញុំមិនមែននៅក្នុងលោកនេះទេ។
ប្រសិនបើរាជ្យរបស់ខ្ញុំនៅក្នុងលោកនេះមែន ពួកបំរើរបស់ខ្ញុំមុខជានាំគ្នាតយុទ្ធមិនអោយគេបញ្ជូនខ្ញុំទៅក្នុងកណ្ដាប់ដៃរបស់សាសន៍យូដាបានឡើយ។ ប៉ុន្តែ
រាជ្យរបស់ខ្ញុំ មិនមែននៅលោកនេះទេ»។ 37លោកពីឡាតទូលសួរព្រះអង្គថា៖ «បើដូច្នេះ តើអ្នកជាស្ដេចមែនឬ?»។
ព្រះយេស៊ូមានព្រះបន្ទូលតបថា៖«លោកទេតើ ដែលមានប្រសាសន៍ថា ខ្ញុំជាស្ដេច។ ខ្ញុំកើតមក ហើយខ្ញុំមកក្នុងលោកនេះ ដើម្បីផ្ដល់សក្ខីភាពអំពីសេចក្ដីពិត
អ្នកណាកើតពីសេចក្ដីពិត អ្នកនោះនឹងស្ដាប់សំឡេងខ្ញុំ»។ 38លោកពីឡាតទូលព្រះអង្គថា៖ «អ្វីទៅសេចក្ដីពិតនោះ?»។

លោកពីឡាតមានប្រសាសន៍ដូច្នោះហើយ ក៏ចេញទៅជួបជនជាតិយូដាជាថ្មីម្ដងទៀត
ប្រាប់ថា៖«ខ្ញុំពុំឃើញអ្នកនេះមានទោសអ្វីសោះឡើយ។39តាមទំនៀមទម្លាប់របស់អ្នករាល់គ្នា ខ្ញុំត្រូវដោះលែងអ្នកទោសម្នាក់ក្នុងឱកាសបុណ្យចម្លង។
តើអ្នករាល់គ្នាចង់អោយខ្ញុំដោះលែងស្ដេចយូដាឬទេ?»។ 40ពេលនោះគេនាំគ្នាស្រែកឡើងសាជាថ្មីថា៖ «កុំដោះលែងអ្នកនេះឡើយ
សូមដោះលែងបារ៉ាបាសវិញ»។ រីឯឈ្មោះបារ៉ាបាសនេះជាចោរព្រៃ។

# JOHN - យ៉ូហាន 19

1ពេលនោះ
លោកពីឡាតបង្គាប់អោយទាហានយកព្រះយេស៊ូទៅវាយនឹងរំពាត់។ 2ពួកទាហានយកបន្លាមកក្រងធ្វើជាមកុដបំពាក់ព្រះសិរសាព្រះអង្គហើយយកអាវពណ៌
ក្រហមទុំមកពាក់អោយព្រះអង្គដែរ។ 3បន្ទាប់មក គេនាំគ្នាចូលទៅជិតព្រះអង្គ ទាំងពោលថា៖ «ស្ដេចយូដាអើយ!សូមថ្វាយបង្គំ»
ហើយក៏ទះកំផ្លៀងព្រះអង្គ។ 4លោកពីឡាត ចេញទៅជួបជនជាតិយូដា សាជាថ្មីមានប្រសាសន៍ទៅគេថា៖ «មើល៍ខ្ញុំនាំគាត់មកខាងក្រៅ
ដើម្បីអោយអ្នករាល់គ្នាដឹងថា ខ្ញុំពុំឃើញអ្នកនេះមានទោសអ្វីសោះ»។ 5ពេលនោះ ព្រះយេស៊ូយាងចេញមក ទាំងពាក់ភួងបន្លាជាមកុដ និង
ពាក់អាវពណ៌ក្រហមទុំផង។ លោកពីឡាតមានប្រសាសន៍ទៅគេថា៖ «មើល៍ មនុស្សហ្នឹងហើយ!»។ 6កាលពួកនាយកបូជាចារ្យ និង
កងរក្សាព្រះវិហារឃើញព្រះអង្គគេនាំគ្នាស្រែកឡើងថា៖ «ឆ្កាងទៅ! ឆ្កាងទៅ!»។ លោកពីឡាតមានប្រសាសន៍ថា៖
«ចូរអ្នករាល់គ្នាយកគាត់ទៅឆ្កាងខ្លួនឯងទៅ ដ្បិតខ្ញុំពុំឃើញអ្នកនេះមានទោសអ្វីសោះ»។ 7ជនជាតិយូដាជំរាបលោកពីឡាតថា៖

«យើងខ្ញុំមានក្រឹត្យវិន័យហើយតាមក្រឹត្យវិន័យនោះ ជននេះត្រូវតែស្លាប់ ព្រោះគាត់តាំងខ្លួនជាព្រះបុត្រារបស់ព្រះជាម្ចាស់
»។ 8កាលលោកពីឡាតឮដូច្នេះ លោករឹតតែភ័យខ្លាចថែមទៀត។ 9លោកចូលទៅក្នុងបន្ទាយវិញ សួរព្រះយេស៊ូថា៖ «អ្នកមកពីណា?»។
ព្រះយេស៊ូពុំបានឆ្លើយតបទៅលោកវិញសោះ។ 10ហេតុនេះលោកពីឡាតសួរព្រះអង្គថា៖
«ម្ដេចក៏អ្នកមិននិយាយមកខ្ញុំដូច្នេះ?អ្នកមិនដឹងថាខ្ញុំមានអំណាចដោះលែងអ្នកក៏បានឬឆ្កាងអ្នកក៏បានទេឬ?»។ 11ព្រះយេស៊ូមានព្រះបន្ទូលតបទៅគាត់
ថា៖ «ប្រសិនបើមិនបានទទួលអំណាចពីស្ថានលើមកទេលោកគ្មានអំណាចលើខ្ញុំឡើយ ហេតុនេះហើយបានជាអ្នកដែលចាប់បញ្ជូនខ្ញុំមកលោក
មានបាបធ្ងន់ជាងលោកទៅទៀត»។ 12តាំងពីពេលនោះមក លោកពីឡាតរកមធ្យោបាយដោះលែងព្រះយេស៊ូ ប៉ុន្តែ ជនជាតិយូដានាំគ្នាស្រែកឡើងថា៖
«បើលោកដោះលែងជននេះ លោកមិនមែនជាមិត្តសំឡាញ់របស់ព្រះចៅអធិរាជឡើយ ដ្បិតអ្នកណាតាំងខ្លួនជាស្ដេច
អ្នកនោះប្រឆាំងនឹងព្រះចៅអធិរាជ!»។ 13កាលលោកពីឡាតឮពាក្យនេះ លោកនាំព្រះយេស៊ូទៅខាងក្រៅ អោយគង់លើវេទិកាសំរាប់កាត់ក្ដី
នៅត្រង់កន្លែងមួយ ឈ្មោះ"លានក្រាលថ្ម" ដែលគេហៅជាភាសាហេប្រឺថា "កាប្បាថា" 14ពេលនោះ ជាថ្ងៃដែលគេរៀបចំបុណ្យចម្លង
ហើយប្រមាណជាពេលថ្ងៃត្រង់។ លោកពីឡាតមានប្រសាសន៍ទៅកាន់ជនជាតិយូដាថា៖ «នេះន៏! ស្ដេចរបស់អ្នករាល់គ្នា»។15ប៉ុន្តែ
ជនជាតិយូដាស្រែកឡើងថា៖ «សម្លាប់ចោលទៅ! ឆ្កាងទៅ!»។ លោកពីឡាតសួរពួកគេថា៖ «អោយខ្ញុំឆ្កាងស្ដេចរបស់អ្នករាល់គ្នាឬ?»។
ពួកនាយកបូជាចារ្យឆ្លើយឡើងថា៖ «ក្រៅពីព្រះចៅអធិរាជ យើងខ្ញុំគ្មានស្ដេចឯណាទៀតឡើយ»។ 16ពេលនោះ
លោកពីឡាតប្រគល់ព្រះយេស៊ូទៅអោយគេឆ្កាង។ គេនាំគ្នាចាប់ព្រះយេស៊ូយកទៅ។ 17ព្រះយេស៊ូលីឈើឆ្កាងដោយផ្ទាល់ព្រះអង្គចេញពីទីក្រុង
ឆ្ពោះទៅកន្លែងមួយឈ្មោះ "ទួលលលាដ៍ក្បាល"ដែលគេហៅជាភាសាហេប្រឺថា "គាល់កូថា" 18គេឆ្កាងព្រះអង្គនៅទីនោះ។

គេឆ្កាងអ្នកទោសពីរនាក់ទៀតនៅសងខាងព្រះអង្គដែរ ព្រះយេស៊ូនៅកណ្ដាល។ 19លោកពីឡាតអោយគេសរសេរប្រកាសបោះភ្ជាប់នឹងឈើឆ្កាង។
នៅលើប្រកាសនោះ មានសរសេរថា «យេស៊ូអ្នកភូមិណាសារ៉ែតជាស្ដេចយូដា»។ 20ជនជាតិយូដាជាច្រើនបានមើលប្រកាសនោះ
ដ្បិតកន្លែងដែលគេឆ្កាងព្រះយេស៊ូនៅក្បែរទីក្រុង ហើយប្រកាសនោះសរសេរជាអក្សរហេប្រឺ ឡាតាំង និង
ក្រិក។ 21ពួកនាយកបូជាចារ្យរបស់ជនជាតិយូដាជំរាបលោកពីឡាតថា៖ «សូមកុំសរសេរថា "ស្ដេចយូដា" ដូច្នេះ តែសរសេរថា"អ្នកនេះនិយាយថា
ខ្ញុំជាស្ដេចយូដា"វិញ»។ 22លោកពីឡាតមានប្រសាសន៍តបថា៖ «ខ្ញុំសរសេរយ៉ាងណាហើយ
ត្រូវទុកយ៉ាងនោះទៅ!»។ 23ក្រោយពីបានឆ្កាងព្រះយេស៊ូរួចហើយពួកទាហានយកសម្លៀកបំពាក់របស់ព្រះអង្គ
មកធ្វើជាបួនចំណែកចែកគ្នាម្នាក់មួយចំណែកៗ។ រីឯអាវវែងរបស់ព្រះអង្គវិញ ជាអាវធ្វើពីក្រណាត់តែមួយផ្ទាំង គ្មានថ្នេរសោះតាំងពីលើដល់ក្រោម។
ដូច្នេះគេនិយាយគ្នាថា៖ 24«កុំហែកអាវនេះ ធ្វើអ្វី យើងចាប់ឆ្នោតវិញ ដើម្បីអោយដឹងថាអាវនេះនឹងបានទៅលើអ្នកណា»។ ពួកទាហានធ្វើដូច្នេះ
ស្របតាមសេចក្ដី ដែលមានចែងទុកក្នុងគម្ពីរមកថា៖
«គេបានយកសម្លៀកបំពាក់របស់ទូលបង្គំចែកគ្នាហើយចាប់ឆ្នោតយកអាវវែងរបស់ទូលបង្គំ»។ 25មាតាព្រះយេស៊ូ ប្អូនស្រីមាតាព្រះអង្គ
នាងម៉ារីជាភរិយាលោកក្លូប៉ាស និង នាងម៉ារីជាអ្នកស្រុកម៉ាដាឡា ឈរក្បែរឈើឆ្កាងរបស់ព្រះអង្គ។ 26ព្រះយេស៊ូ ឃើញមាតា
ព្រមទាំងសិស្សដែលព្រះអង្គស្រឡាញ់នោះឈរនៅជិត ទ្រង់មានព្រះបន្ទូលទៅមាតាថា៖ «អ្នកអើយ! នេះហើយកូនរបស់អ្នក»។27បន្ទាប់មក
ព្រះអង្គមានព្រះបន្ទូលទៅសិស្សថា៖ «នេះហើយម្ដាយរបស់អ្នក»។ តាំងពីពេលនោះមក សិស្សនោះយកគាត់មកនៅជាមួយ។28បន្ទាប់មក
ព្រះយេស៊ូជ្រាបថា ព្រះអង្គបានបង្ហើយកិច្ចការទាំងអស់ចប់សព្វគ្រប់ ព្រះអង្គមានព្រះបន្ទូលថា៖ «ខ្ញុំស្រេកទឹក»

ដើម្បីអោយបានស្របតាមសេចក្តីគ្រប់ប្រការ ដែលមានចែងទុកក្នុងគម្ពីរ។ 29នៅទីនោះ មានក្រឡមួយមានទឹកខ្មេះពេញ។ ពួកទាហានយកសារាយស្ងួត
ជ្រលក់ទឹកខ្មេះជោក រួចរុំនៅចុងត្រែងមួយដើម រុញទៅដល់ព្រះឱស្ឋរបស់ព្រះអង្គ។30កាលព្រះយេស៊ូសោយទឹកខ្មេះហើយ ព្រះអង្គមានព្រះបន្ទូលថា៖
«ខ្ញុំបានសំរេចសព្វគ្រប់អស់ហើយ!»។ ព្រះអង្គក៏ឱនព្រះសិរសាចុះ ហើយប្រគល់វិញ្ញាណទៅ។ 31ថ្ងៃនោះជាថ្ងៃរៀបចំបុណ្យចម្លង
ជនជាតិយូដាមិនចង់អោយមានសាកសពជាប់នឹងឈើឆ្កាងនៅថ្ងៃសប្ប័ទឡើយ ព្រោះថ្ងៃសប្ប័ទនោះ ជាថ្ងៃបុណ្យធំ។
ហេតុនេះហើយបានជាគេសុំលោកពីឡាតចេញបញ្ជាទៅទាហានអោយបំបាក់ជើងអ្នកជាប់ឆ្កាងហើយយកសាកសពចុះមក។32ពួកទាហាននាំគ្នាមកវាយបំ
បាក់ជើង អ្នកទោសទីមួយ និង អ្នកទោសទីពីរ
ដែលជាប់លើឈើឆ្កាងជាមួយព្រះអង្គ។ 33លុះមកដល់ព្រះយេស៊ូគេឃើញព្រះអង្គសោយទិវង្គតផុតទៅហើយ
គេមិនបំបាក់ព្រះបាទាព្រះអង្គទេ34ប៉ុន្តែទាហានម្នាក់យកលំពែងចាក់ត្រង់ចន្លោះឆ្អឹងជំនីរព្រះអង្គ ស្រាប់តែមានទឹក និង
លោហិតហូរចេញមកមួយរំពេច។ 35សិស្សម្នាក់ដែលបានឃើញ ធ្វើជាបន្ទាល់អំពីហេតុការណ៍នេះ ហើយសក្ខីភាពរបស់គាត់ពិតប្រាកដមែន។
ព្រះអង្គដឹងថាសិស្សនោះនិយាយសេចក្តីពិត
ដើម្បីអោយអ្នករាល់គ្នាជឿដែរ។ 36ហេតុការណ៍នេះកើតឡើងស្របតាមសេចក្តីដែលមានចែងទុកក្នុងគម្ពីរមកថា៖
«គ្មានឆ្អឹងណាមួយរបស់លោកត្រូវបាក់បែកឡើយ»។ 37មានអត្ថបទគម្ពីរមួយទៀត ចែងថា៖«គេនាំគ្នាមើលអ្នកដែលគេចាក់ទម្លុះ»។ 38បន្ទាប់មក
លោកយ៉ូសែប ជាអ្នកស្រុកអើរីម៉ាថេបានទៅសុំច្បាប់លោកពីឡាត យកព្រះសពព្រះយេស៊ូ។
លោកយ៉ូសែបនេះក៏ជាសិស្សរបស់ព្រះយេស៊ូដែរតែមិនហ៊ានចេញមុខទេ ព្រោះខ្លាចជនជាតិយូដា។ លោកពីឡាតអនុញ្ញាតអោយ
ហើយលោកយ៉ូសែបក៏មកដោះព្រះសពយកទៅ។ 39រីលោកនីកូដេម ដែលមកគាល់ព្រះយេស៊ូទាំងយប់កាលពីមុន ក៏បានមកដែរ។

លោកយកជ័រល្វីងទេស លាយនឹងគ្រឿងក្រអូបប្រមាណជាកន្លះហាបមកផង។ 40លោកទាំងពីរយកព្រះសពព្រះយេស៊ូមករុំនឹងសំពត់ស្ដើង
អប់គ្រឿងក្រអូបតាមទំនៀមទម្លាប់ពិធីបញ្ចុះសពរបស់ជនជាតិយូដា។ 41នៅកន្លែងគេឆ្កាងព្រះយេស៊ូមានសួនឧទ្យានមួយ ក្នុងសួននោះមានផ្នូរមួយថ្មី
ពុំទាន់ដែលដាក់សពណានៅឡើយ។ 42គេដាក់ព្រះយេស៊ូនៅក្នុងផ្នូរនោះព្រោះនៅជិតស្រាប់ ដ្បិតថ្ងៃនោះជាថ្ងៃរៀបចំបុណ្យចម្លង។

# JOHN - យ៉ូហាន 20

1នៅព្រឹកថ្ងៃអាទិត្យ កាលនៅងងឹតនៅឡើយ នាងម៉ារីជាអ្នកស្រុកម៉ាដាឡាចេញដំណើរឆ្ពោះទៅផ្នូរ ហើយឃើញថា
មានគេយកថ្មចេញពីមាត់ផ្នូរផុតទៅហើយ។ 2នាងក៏រត់មកជំរាបលោកស៊ីម៉ូនពេត្រុស និង សិស្សម្នាក់ទៀត ដែលព្រះយេស៊ូស្រឡាញ់ថា៖
«គេយកព្រះអម្ចាស់ចេញពីផ្នូរបាត់ហើយ យើងមិនដឹងជាគេយកទៅដាក់នៅឯណាទេ!»។ 3លោកពេត្រុស និង សិស្សម្នាក់ទៀតនោះ
ក៏ចេញទៅផ្នូរ។ 4សិស្សទាំងពីររត់ទៅជាមួយគ្នាតែសិស្សម្នាក់នោះរត់លឿនជាងលោកពេត្រុស ទៅដល់ផ្នូរមុន។ 5គាត់ឈ្ងោកមើលទៅ ឃើញសំពត់ស្ដើង
តែគាត់មិនចូលទៅក្នុងផ្នូរឡើយ។6លោកស៊ីម៉ូនពេត្រុសរត់តាមក្រោយមកដល់ គាត់ចូលទៅក្នុងផ្នូរ
ហើយសម្លឹងមើលសំពត់ស្ដើងនៅទីនោះ 7ព្រមទាំងក្រណាត់ដែលគេគ្របព្រះសិរសាព្រះអង្គ មូរទុកដោយឡែក
គឺមិននៅជាមួយសំពត់ស្ដើងទេ។ 8ពេលនោះ សិស្សដែលទៅដល់ផ្នូរមុន ក៏ចូលទៅខាងក្នុងដែរ គាត់បានឃើញ ហើយជឿ។ 9កាលណោះ
ពួកសិស្សពុំទាន់យល់អត្ថន័យគម្ពីរ ដែលចែងទុកមកថា

ព្រះយេស៊ូត្រូវមានព្រះជន្មរស់ឡើងវិញនៅឡើយទេ។10បន្ទាប់មកសិស្សទាំងពីរក៏នាំគ្នាវិលត្រឡប់ទៅផ្ទះ។ 11នាងម៉ារីឈរយំនៅខាងក្រៅ
ក្បែរមាត់ផ្នូរ។ នាងឈ្ងោកមើលទៅខាងក្នុងផ្នូរ ទាំងយំ12ឃើញទេវតាពីររូបស្លៀកពាក់ស អង្គុយនៅត្រង់កន្លែង ដែលគេដាក់ព្រះសពព្រះយេស៊ូ
ម្នាក់អង្គុយនៅខាងព្រះសិរសា ម្នាក់ទៀតនៅខាងចុងព្រះបាទា។ 13ទេវតាពោលមកកាន់នាងថា៖ «នាងអើយ! ម្ដេចក៏នាងយំ?»។
នាងឆ្លើយទៅទេវតាវិញថា៖ «មានគេយកសពព្រះអម្ចាស់របស់នាងខ្ញុំទៅបាត់
មិនដឹងជាគេយកទៅដាក់នៅឯណាឡើយ»។ 14ពេលនាងកំពុងតែនិយាយដូច្នេះ នាងបែរទៅក្រោយ ឃើញព្រះយេស៊ូឈរនៅទីនោះ តែនាងមិនដឹងថា
ជាព្រះអង្គទេ។ 15ព្រះយេស៊ូសួរនាងថា៖ «នាងអើយ!ម្ដេចក៏នាងយំ? នាងរកអ្នកណា?»។ នាងស្មានថាជាអ្នកថែរក្សាសួនច្បារ
នាងក៏ទូលព្រះអង្គថា៖ «លោកម្ចាស់! ប្រសិនបើលោកបានយកសពទៅ
សូមប្រាប់អោយនាងខ្ញុំដឹងផងលោកដាក់នៅឯណានាងខ្ញុំនឹងទៅយក»។16ព្រះយេស៊ូមានព្រះបន្ទូលហៅនាងថា៖ «ម៉ារី!»។
នាងម៉ារីក៏បែរទៅរកព្រះអង្គ ហើយទូលព្រះអង្គជាភាសាហេប្រឺថា៖ «រ៉ាប៊ូនី!» ប្រែថា"ព្រះគ្រូ!"។17ព្រះយេស៊ូមានព្រះបន្ទូលថា៖ «កុំឃាត់ខ្ញុំទុកអី
ដ្បិតខ្ញុំមិនទាន់បានឡើងទៅឯព្រះបិតាខ្ញុំនៅឡើយ។ សុំទៅប្រាប់ពួកបងប្អូនខ្ញុំផងថា ខ្ញុំឡើងទៅឯព្រះបិតាខ្ញុំ ដែលជាព្រះបិតារបស់អ្នករាល់គ្នា
ខ្ញុំឡើងទៅឯព្រះរបស់ខ្ញុំដែលជាព្រះរបស់អ្នករាល់គ្នាដែរ»។ 18នាងម៉ារីជាអ្នកស្រុកម៉ាដាឡាចេញទៅ ជំរាបពួកសិស្សថា នាងបានឃើញព្រះអម្ចាស់
ព្រមទាំងជំរាបអំពីសេចក្ដីដែលព្រះអង្គមានព្រះបន្ទូលមកនាង។ 19នៅល្ងាចថ្ងៃអាទិត្យនោះ ពួកសិស្សនៅក្នុងផ្ទះខ្ទាស់ទ្វារយ៉ាងជាប់
ព្រោះខ្លាចជនជាតិយូដា។ ស្រាប់តែព្រះយេស៊ូយាងមកឈរនៅកណ្ដាលចំណោមពួកគេមានព្រះបន្ទូលថា៖
«សូមអោយអ្នករាល់គ្នាបានប្រកបដោយសេចក្ដីសុខសាន្ត!»។ 20ព្រះអង្គមានព្រះបន្ទូលដូច្នេះ ទាំងបង្ហាញស្នាមរបួសនៅព្រះហស្ត និង

នៅត្រង់ឆ្អឹងជំនីរអោយគេឃើញផង។ ពួកសិស្សសប្បាយចិត្តជាខ្លាំងដោយបានឃើញព្រះអម្ចាស់។ 21ព្រះយេស៊ូមានព្រះបន្ទូលទៅគេសាជាថ្មីថា៖
«សូមអោយអ្នករាល់គ្នាបានប្រកបដោយសេចក្ដីសុខសាន្ត!
ដូចព្រះបិតាបានចាត់ខ្ញុំអោយមកយ៉ាងណាខ្ញុំចាត់អ្នករាល់គ្នាអោយទៅយ៉ាងនោះដែរ»។22បន្ទាប់ពីមានព្រះបន្ទូលហើយ ព្រះអង្គផ្លុំលើពួកគេ
ទាំងមានព្រះបន្ទូលថា៖«ចូរទទួលព្រះវិញ្ញាណ!។ 23បើអ្នករាល់គ្នាលើកលែងទោសអ្នកណាអោយរួចពីបាបព្រះជាម្ចាស់ក៏នឹងលើកលែងទោសអ្នកនោះ
អោយរួចពីបាបដែរ។ ផ្ទុយទៅវិញ បើអ្នករាល់គ្នាប្រកាន់ទោសអ្នកណាអ្នកនោះមុខជាត្រូវជាប់ទោសមិនខាន»។ 24កាលព្រះយេស៊ូយាងមកនោះ
លោកថូម៉ាស ហៅឌីឌីម ជាសិស្សម្នាក់ ក្នុងចំណោមសិស្សទាំងដប់ពីរមិនបាននៅជាមួយពួកគេទេ។ 25សិស្សឯទៀតៗប្រាប់គាត់ថា៖
«យើងបានឃើញព្រះអម្ចាស់»។ ប៉ុន្ដែ គាត់និយាយទៅពួកគេវិញថា៖ «បើខ្ញុំមិនឃើញស្នាមដែកគោលនៅបាតដៃ
មិនបានដាក់ម្រាមដៃក្នុងស្នាមដែកគោល ហើយបើខ្ញុំមិនបានដាក់ដៃត្រង់ឆ្អឹងជំនីររបស់លោកទេ
ខ្ញុំមិនជឿជាដាច់ខាត»។26ប្រាំបីថ្ងៃក្រោយមកពួកសិស្សជួបជុំគ្នានៅក្នុងផ្ទះសាជាថ្មីលោកថូម៉ាស ក៏នៅជាមួយដែរ។ ពេលនោះទ្វារ
ផ្ទះនៅខ្ទាស់ជាប់ព្រះយេស៊ូយាងមកឈរនៅកណ្ដាលចំណោមពួកគេ ទាំងមានព្រះបន្ទូលថា៖
«សូមអោយអ្នករាល់គ្នាបានប្រកបដោយសេចក្ដីសុខសាន្ត!»។ 27បន្ទាប់មក ព្រះអង្គមានព្រះបន្ទូលទៅលោកថូម៉ាសថា៖ «មើលដៃខ្ញុំនេះ
ចូរដាក់ម្រាមដៃអ្នកមក ហើយដាក់ដៃអ្នកត្រង់ឆ្អឹងជំនីរខ្ញុំ។ ចូរជឿទៅ! កុំរឹងរូសមិនព្រមជឿដូច្នេះ!»។28លោកថូម៉ាសទូលព្រះអង្គថា៖
«ព្រះអង្គពិតជាព្រះអម្ចាស់ និង ជាព្រះរបស់ទូលបង្គំមែន!»។ 29ព្រះយេស៊ូមានព្រះបន្ទូលទៅគាត់ថា៖ «អ្នកជឿមកពីអ្នកបានឃើញខ្ញុំ អ្នកណាជឿ
ដោយឥតបានឃើញសោះ អ្នកនោះមានសុភមង្គលហើយ!»។ 30ព្រះយេស៊ូបានធ្វើទីសំគាល់ជាច្រើនទៀតអោយពួកសិស្សឃើញ

តែគ្មានកត់ត្រាទុកក្នុងសៀវភៅនេះទេ។ 31រីឯសេចក្ដីដែលមានកត់ត្រាមកនេះ គឺក្នុងគោលបំណងអោយអ្នករាល់គ្នាជឿថា ព្រះយេស៊ូពិតជាព្រះគ្រិស្ដ និង
ពិតជាព្រះបុត្រារបស់ព្រះជាម្ចាស់ ហើយអោយអ្នករាល់គ្នាដែលជឿមានជីវិត ដោយរួមជាមួយព្រះអង្គ។

# JOHN - យ៉ូហាន 21

1ក្រោយមក ព្រះយេស៊ូបង្ហាញខ្លួនអោយពួកសិស្សឃើញម្ដងទៀត នៅមាត់សមុទ្រទីបេរាស
គឺព្រះអង្គបង្ហាញអោយគេឃើញដូចតទៅ៖ 2លោកស៊ីម៉ូនពេត្រុស លោកថូម៉ាសហៅឌីឌីម លោកណាថាណែល ពីភូមិកាណាក្នុងស្រុកកាលីឡេ
កូនទាំងពីររបស់លោកសេបេដេ និង សិស្សរបស់ព្រះយេស៊ូពីរនាក់ទៀតនៅជុំគ្នា។ 3លោកស៊ីម៉ូនពេត្រុសនិយាយទៅកាន់សិស្សឯទៀតៗថា៖
«ខ្ញុំទៅរកត្រី»។ គេពោលតបមកគាត់វិញថា៖ «យើងទៅជាមួយដែរ»។ គេក៏នាំគ្នាចេញទៅ ហើយចុះទូកទាំងអស់គ្នា ប៉ុន្តែនៅយប់នោះ
គេឥតបានត្រីសោះ។ 4ព្រលឹមឡើង ព្រះយេស៊ូឈរនៅមាត់ច្រាំង ប៉ុន្តែ ពួកសិស្សមិនដឹងថាជាព្រះអង្គទេ។ 5ព្រះយេស៊ូមានព្រះបន្ទូលទៅគេថា៖
«កូនចៅអើយ!មានអ្វីបរិភោគឬទេ?»។ គេទូលព្រះអង្គថា៖ «គ្មានទេ»។ 6ព្រះអង្គមានព្រះបន្ទូលទៅគេថា៖
«ចូរទម្លាក់អួនខាងស្ដាំទូកទៅមុខជាបានត្រីមិនខាន»។ គេក៏ទម្លាក់អួន ហើយពុំអាចលើកអួនឡើងវិញបានឡើយ ព្រោះមានត្រីច្រើនពេក។ 7ពេលនោះ
សិស្សដែលព្រះយេស៊ូស្រឡាញ់ និយាយទៅលោកពេត្រុសថា៖ «ព្រះអម្ចាស់ទេតើ!»។ កាលលោកស៊ីម៉ូនពេត្រុសឮថា ព្រះអម្ចាស់ដូច្នេះ
គាត់ក៏ស្លៀកពាក់ ដ្បិតគាត់នៅខ្លួនទទេ រួចលោតទៅក្នុងទឹក។ 8សិស្សឯទៀតៗនាំគ្នាចូលទូកទៅមាត់ច្រាំង ទាំងទាញអួនដែលមានត្រីពេញទៅជាមួយផង

ព្រោះគេមិននៅឆ្ងាយពីច្រាំងប៉ុន្មានទេ គឺប្រមាណជាពីររយហត្ថប៉ុណ្ណោះ។ 9គេឡើងទៅលើគោកឃើញរងើកភ្លើង មានដាក់ត្រី និង នំប៉័ង
អាំងពីលើផង។ 10ព្រះយេស៊ូមានព្រះបន្ទូលទៅគេថា៖
«សុំយកត្រីដែលអ្នករាល់គ្នាទើបនឹងចាប់បានមកណោះ!»។ 11លោកស៊ីម៉ូនពេត្រុសចុះទៅក្នុងទូក ទាញអួនដែលមានត្រីពេញមកដាក់លើគោក
គឺមានត្រីធំៗចំនួនមួយរយហាសិបបី។ ទោះបីមានត្រីច្រើនយ៉ាងនេះក៏ដោយ ក៏អួនមិនធ្លាយដែរ។ 12ព្រះយេស៊ូមានព្រះបន្ទូលទៅគេថា៖
«នាំគ្នាមកបរិភោគទៅ»។ គ្មានសិស្សណាម្នាក់ហ៊ានសួរព្រះអង្គថា "លោកជានរណា"ឡើយ
ដ្បិតគេដឹងថាជាព្រះអម្ចាស់ទាំងអស់គ្នា។ 13ព្រះយេស៊ូយាងទៅជិតពួកគេ ទ្រង់យកនំប៉័ងមកប្រទានអោយគេ
ហើយយកត្រីមកប្រទានអោយគេដែរ។ 14តាំងពីព្រះអង្គមានព្រះជន្មរស់ឡើងវិញមក នេះជាលើកទីបីហើយ
ដែលព្រះយេស៊ូសំដែងព្រះអង្គអោយពួកសិស្សឃើញ។ 15លុះគេបានបរិភោគរួចរាល់ហើយ ព្រះយេស៊ូមានព្រះបន្ទូលសួរលោកស៊ីម៉ូនពេត្រុសថា៖
«ស៊ីម៉ូនកូនលោកយ៉ូហានអើយ! តើអ្នកស្រឡាញ់ខ្ញុំ ជាងអ្នកទាំងនេះស្រឡាញ់ខ្ញុំឬ?»។ គាត់ទូលព្រះអង្គថា៖ «ក្រាបទូលព្រះអម្ចាស់!
ព្រះអង្គជ្រាបស្រាប់ហើយថា ទូលបង្គំស្រឡាញ់ព្រះអង្គ»។ ព្រះយេស៊ូមានព្រះបន្ទូលទៅគាត់ថា៖
«សុំថែរក្សាកូនចៀមរបស់ខ្ញុំផង!»។ 16ព្រះអង្គមានព្រះបន្ទូលសួរគាត់ ជាលើកទីពីរថា៖ «ស៊ីម៉ូនកូនលោកយ៉ូហានអើយ!
តើអ្នកស្រឡាញ់ខ្ញុំឬទេ?»។ លោកពេត្រុសទូលថា៖ «ក្រាបទូលព្រះអម្ចាស់! ព្រះអង្គជ្រាបស្រាប់ហើយថាទូលបង្គំស្រឡាញ់ព្រះអង្គ»។
ព្រះយេស៊ូមានព្រះបន្ទូលទៅគាត់ថា៖ «សុំឃ្វាលហ្វូងចៀមរបស់ខ្ញុំផង!»។ 17ព្រះអង្គមានព្រះបន្ទូលសួរគាត់ជាលើកទីបីថា៖ «ស៊ីម៉ូន
កូនលោកយ៉ូហានអើយ! តើអ្នកស្រឡាញ់ខ្ញុំឬទេ»។ លោកពេត្រុសព្រួយចិត្តណាស់ ព្រោះព្រះអង្គសួរគាត់ដល់ទៅបីលើកថា

"អ្នកស្រឡាញ់ខ្ញុំឬទេ"ដូច្នេះ។ លោកទូលតបទៅព្រះអង្គថា៖ «បពិត្រព្រះអម្ចាស់! ព្រះអង្គជ្រាបអ្វីៗសព្វគ្រប់ទាំងអស់ ព្រះអង្គជ្រាបស្រាប់ហើយថា
ទូលបង្គំស្រឡាញ់ព្រះអង្គ»។ ព្រះយេស៊ូមានព្រះបន្ទូលទៅគាត់ថា៖ «សុំថែរក្សាហ្វូងចៀមរបស់ខ្ញុំផង។ 18ខ្ញុំសុំប្រាប់អោយអ្នកដឹងច្បាស់ថា
កាលអ្នកនៅក្មេង អ្នកក្រវាត់ចង្កេះខ្លួនឯង ហើយអ្នកទៅណាតាមតែចិត្តអ្នកចង់។ លុះដល់អ្នកចាស់ អ្នកនឹងលើកដៃឡើង
ហើយមានម្នាក់ទៀតក្រវាត់ចង្កេះអោយអ្នកទាំងនាំអ្នកទៅកន្លែងដែលអ្នកមិនចង់ទៅថែមទៀតផង»។ 19ព្រះអង្គមានព្រះបន្ទូលដូច្នេះ
បង្ហាញអំពីរបៀបដែលលោកពេត្រុសស្លាប់ ដើម្បីសំដែងសិរីរុងរឿងរបស់ព្រះជាម្ចាស់។ បន្ទាប់មក ព្រះអង្គមានព្រះបន្ទូលទៅគាត់ថា៖
«សុំអញ្ជើញមកតាមខ្ញុំ!»។ 20លោកពេត្រុសងាកមើលក្រោយឃើញសិស្ស ដែលព្រះយេស៊ូស្រឡាញ់ ដើរតាមមកដែរ។ សិស្សនោះហើយ
ដែលបានអោនទៅជិតព្រះឱរារបស់ព្រះយេស៊ូនៅពេលជប់លៀង ហើយទូលសួរព្រះអង្គថា "បពិត្រព្រះអម្ចាស់!
តើនរណានាំគេមកចាប់ព្រះអង្គ?"។21កាលលោកពេត្រុសឃើញគាត់ លោកទូលសួរព្រះយេស៊ូថា៖ «ព្រះអម្ចាស់អើយ! រីឯអ្នកនោះវិញ
តើនឹងមានកើតអ្វីដល់គាត់?»។ 22ព្រះយេស៊ូមានព្រះបន្ទូលតបទៅគាត់ថា៖ «ប្រសិនបើខ្ញុំចង់អោយគាត់មានជីវិតរស់រហូតដល់ខ្ញុំត្រឡប់មកវិញ
តើនឹងកើតអំពល់អ្វីដល់អ្នក?។ 23ឯអ្នក សុំអញ្ជើញមកតាមខ្ញុំ!»។ តាំងពីពេលនោះមក មានលេចឮពាក្យក្នុងចំណោមពួកបងប្អូនថា
សិស្សនោះមិនត្រូវស្លាប់ទេ។ តាមពិត ព្រះយេស៊ូពុំបានប្រាប់លោកពេត្រុសថា សិស្សនោះមិនត្រូវស្លាប់ឡើយ ព្រះអង្គគ្រាន់តែមានព្រះបន្ទូលថា
"ប្រសិនបើខ្ញុំចង់អោយគាត់មានជីវិតរស់រហូតដល់ខ្ញុំត្រឡប់មកវិញ តើនឹងកើតអំពល់អ្វីដល់អ្នក?"។ 24សិស្សនោះហើយ ដែលបានផ្ដល់សក្ខីភាព
អំពីហេតុការណ៍ទាំងអស់នេះ ព្រមទាំងបានកត់ត្រាទុកមកផង។
យើងដឹងថាសក្ខីភាពរបស់គាត់ពិតជាត្រឹមត្រូវមែន។25ព្រះយេស៊ូបានធ្វើកិច្ចការឯទៀតៗជាច្រើន។

ប្រសិនបើមានគេកត់ត្រាហេតុការណ៍ទាំងនោះអោយបានល្អិតល្អន់ ខ្ញុំយល់ថា ពិភពលោកនេះពុំអាចនឹងមានកន្លែងល្មម សំរាប់ទុកសៀវភៅដែលគេកត់ត្រានោះបានឡើយ។